ក្រសួងអប់រំ យុវជន និងកីឡា

# ការសិក្សាបែបស្ថាបនានិយម & ការគិតបែបគណនា

## ផែនការបង្រៀន និងសម្ភារៈបណ្តុះបណ្តាល






រាជធានីភ្នំពេញ
ខែតុលា ឆ្នាំ២០២៣

ឯកសារបោះពុម្ពនេះ ចងក្រងដោយការិយាល័យកណ្តាលកម្មវិធីសាលារៀនជំនាន់ថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា គម្រោងអភិវឌ្ឍន៍វិស័យអប់រំ - មធ្យមសិក្សា ២ ក្រោមកិច្ចសហការជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដើម្បីផ្តល់ជាក្របខ័ណ្ឌអនុវត្តតាមសាលារៀនសាធារណៈរបស់រដ្ឋបង្កើនការស្វែងយល់ និងអនុវត្តគោលការណ៍បង្រៀនបែបស្ថាបនានិយម និងការគិតបែបគណនា។

**សូមបញ្ជាក់ការដកស្រង់ពីឯកសារបោះពុម្ពនេះថា ៖**

ក្រសួង អ.យ.ក(២០២៣). ការសិក្សាបែបស្ថាបនានិយម និងការគិតបែបគណនា៖ ផែនការបង្រៀនសម្រាប់អ្នកសម្របសម្រួល, រាជធានីភ្នំពេញ: អ្នកនិពន្ធ។

រចនាក្រប៖ រចនាដោយលោក អឿ សារីន អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

© ក្រសួង អ.យ.ក ២០២៣

អ្នកអានអាចថតចម្លង ឬបោះពុម្ពឯកសារនេះបានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនដូចជា៖ ការបោះពុម្ពឡើងវិញ ប្លក់ វេបសាយ និងសម្ភារៈឧបទេស ដរាបណាមានការទទួលស្គាល់ត្រឹមត្រូវពីក្រសួងអប់រំ យុវជន និងកីឡា ជាប្រភពឯកសារ និងម្ចាស់កម្មសិទ្ធិបញ្ញា។

**Printed by:**
Kampuchea Action to Promote Education, PO Box 1621, Phnom Penh, Tel: 042-941-481, Fax: 042-941-918, email: kape@kapekh.org, website: www.kapekh.org.

# មាតិកា


បុព្វកថា

១ សេចក្តីណែនាំ ៣

១.១ ទិដ្ឋភាពទូទៅ ៣

១.២ គោលបំណង និងខ្លឹមសារឯកសារនេះ ៤

១.៣ ការអនុវត្តការសិក្សាបែបស្ថាបនានិយមនៅកម្ពុជា ៥

១.៤ ការគិតបែបគណនា៖ និយមន័យ និងការអនុវត្ត

២ របៀបប្រើប្រាស់ឯកសារនេះ ៨

៣ ផែនការមេរៀនសម្រាប់អ្នកសម្របសម្រួល ១០

*ផ្នែកទី១៖ ទ្រឹស្តីសិក្សាបែបស្ថាបនានិយម*

មេរៀនទី៣.១ តើការសិក្សាបែបស្ថាបនានិយមគឺជាអ្វី? ១១

មេរៀនទី៣.២ ការអនុវត្តការសិក្សាបែបស្ថាបនានិយមក្នុងថ្នាក់រៀន ១៩

មេរៀនទី៣.៣ ការបង្កើតបរិបទស្ថាប័នដើម្បីលើកកម្ពស់ការសិក្សាបែបស្ថាបនានិយម ៣០

មេរៀនទី៣.៤ ការវាយតម្លៃសិស្សក្នុងថ្នាក់រៀនដែលអនុវត្តស្ថាបនានិយម ៣៧

*ផ្នែកទី២៖ ការគិតបែបគណនា*

៣.៥ តើយើងកំណត់និយមន័យបែបណាសម្រាប់ ការគិតបែបគណនា?

៣.៦ ការអនុវត្តជាក់ស្តែងនៃការគិតបែបគណនា

៤ ឯកសារចែកសម្រាប់សិក្ខាកាម ៤២

**ឯកសារចែកទី ១៖** ការភ្ជាប់ការសិក្សាស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗ ៤៣

**ឯកសារចែកទី ២ក៖** និយមន័យការសិក្សាបែបស្ថាបនានិយម ៤៤

**ឯកសារចែកទី ២ខ៖** គោលការណ៍សំខាន់ៗក្នុងការសិក្សាបែបស្ថាបនានិយម ៤៦

**ឯកសារចែកទី ៣៖** ហេតុអ្វីការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាព? ៤៨

**ឯកសារចែកទី ៤៖** ការផ្សារភ្ជាប់ការសិក្សាបែបស្ថាបនានិយម និង Bloom's Taxonomy ៥០

**ឯកសារចែកទី ៥ក៖** ការបង្កើតបញ្ញត្តិ និងការសិក្សាបែបស្ថាបនានិយម ៥២

**ឯកសារចែកទី ៥ខ៖** ការបង្កើតបញ្ញត្តិពីរផ្ទុយគ្នា ៥៤

**ឯកសារចែកទី ៦៖** វិធីសាស្ត្របង្រៀនល្អៗមួយចំនួន ក្នុងការសិក្សាបែបស្ថាបនានិយម ៥៦

**ឯកសារចែកទី ៧៖** វិធីសាស្ត្រការសិក្សាអាស្រ័យលើបញ្ហាដើម្បីលើកកម្ពស់ការសិក្សាបែបស្ថាបនានិយម ៦៣

**ឯកសារចែកទី ៨៖** ដំណើរការ និង ផលិតផល នៃការសិក្សាបែបស្ថាបនានិយម ៦៥

**ឯកសារចែកទី ៩៖** ទ្រឹស្តីសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា ៦៨

**ឯកសារចែកទី ១០៖** ភាពផ្ទុយគ្នានៃការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម ៧០

**ឯកសារចែកទី ១១៖** យុទ្ធសាស្ត្រវាយតម្លៃក្នុងបរិស្ថានសិក្សាបែបស្ថាបនានិយម ៧១

**ឯកសារចែកទី១២៖** ឧទាហរណ៍ជាក់ស្តែងនៃវិធីសាស្ត្រវាយតម្លៃដែលប្រើប្រាស់សម្រាប់វាយតម្លៃការសិក្សាបែបស្ថាបនានិយម ៧៣

**ឯកសារចែកទី១៣៖** ការកំណត់និយមន័យនៃ ការគិតបែបគណនា និងការយល់ដឹងពីប្រភពដើមរបស់វា

**ឯកសារចែកទី១៤ក៖** ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ

**ឯកសារចែកទី១៤ខ៖** ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ (ដំណោះស្រាយណែនាំ)

**ឯកសារចែកទី១៥៖** តើបុគ្គលគ្រប់គ្នាចូលចិត្តការគិតបែបគណនាដែរឬទេ?

**ឯកសារចែកទី១៦ក៖** ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា (លំហាត់ទី១)

**ឯកសារចែកទី១៦ខ៖** ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា (លំហាត់ទី២)

**ឯកសារចែកទី១៧៖** បច្ចេកទេសទូទៅមួយចំនួនដើម្បីអនុវត្តការគិតបែបគណនាទៅក្នុងមុខវិជ្ជាផ្សេងៗ

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡា មានសេចក្តីរីករាយក្នុងការចេញផ្សាយឯកសារបណ្តុះបណ្តាលស្តីពី ការសិក្សាបែបស្ថាបនានិយម និងការគិតបែបគណនា ដែលជាឧបករណ៍សំខាន់មួយ ជួយអ្នកអប់រំក្នុងការធ្វើទំនើបកម្មការអនុវត្តការបង្រៀននៅកម្ពុជានៅគ្រប់កម្រិតទាំងអស់ (ទាំងបឋមសិក្សា និងមធ្យមសិក្សា)។ ឯកសារនេះបានឆ្លងកាត់ការកែសម្រួលសំខាន់ៗមួយចំនួន ចាប់តាំងពីត្រូវបានចេញផ្សាយជាលើកដំបូងជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលមូលដ្ឋានសម្រាប់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មី។ ឯកសារបណ្តុះបណ្តាលនេះត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឱ្យកាន់តែសមស្របទៅនឹងការបោះពុម្ពផ្សាយថ្មីៗរបស់ក្រសួងបន្ថែមទៀត រួមមាន *ក្របខ័ណ្ឌគរុកោសល្យសតវត្សរ៍ទី ២១ សម្រាប់ប្រទេសកម្ពុជា (ឆ្នាំ២០២១)*[1] និង *ឯកសារស្តីពីការអនុវត្តការសិក្សាបែបគម្រោង (ឆ្នាំ ២០២៣)*[2]។ គោលបំណងនៃឯកសារនេះគឺសម្រាប់ប្រើប្រាស់នៅក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មី ប៉ុន្តែអាចប្រើប្រាស់បានផងដែរនៅក្នុងសាលាគំរូដែលទើបតែបានកំណត់នាពេលថ្មីៗនេះ សាលាធនធាន ក៏ដូចជាសាលារៀនធម្មតា។ ក្រសួងមើលឃើញថា ការសិក្សាបែបស្ថាបនានិយម ជាទស្សនវិជ្ជាទូលំទូលាយមួយនៃការអប់រំ រួមបញ្ចូលនូវវិធីសាស្ត្របង្រៀនសំខាន់ៗជាច្រើន ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរប្រព័ន្ធអប់រំឱ្យចេញផុតពីការរៀនទន្ទេញចាំមាត់។ វិធីសាស្ត្រទាំងនេះរួមមានការសិក្សាបែបគម្រោង ការសិក្សាផ្អែកលើបញ្ហា និងការសិក្សាតាមបែបរិះរក។ វិធីសាស្ត្របង្រៀននីមួយៗទាំងនេះជាគោលការណ៍សំខាន់ៗមានចែងនៅក្នុងទស្សនវិជ្ជាសិក្សាបែបស្ថាបនានិយម ដូច្នេះឯកសារនេះមានសារៈសំខាន់ណាស់។

ក្នុងអំឡុងពេលនៃការកែសម្រួលឯកសារនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់បញ្ចូលផ្នែកថ្មីមួយស្តីពីការគិតបែបគណនាផងដែរ។ ទោះបីជាការគិតបែបគណនា មានដើមកំណើតមកពីបច្ចេកទេសដែលត្រូវបានប្រើក្នុងវិទ្យាសាស្ត្រកុំព្យូទ័រក៏ដោយ ឥឡូវនេះ អ្នកអប់រំតែងតែអនុវត្តវិធីសាស្ត្រគិតបែបនេះដូចជា ការដោះស្រាយបញ្ហា ការគិតបែបត្រិះរិះពិចារណា និងការវិភាគបែបតក្កទូទៅចំពោះមុខវិជ្ជាទាំងអស់ រួមទាំងមុខវិជ្ជាភាសាផងដែរ។ ទាំងនេះគឺជាបំណិនទន់សំខាន់ៗ ដែលចាំបាច់សម្រាប់បុគ្គលម្នាក់ៗ ដើម្បីធ្វើកិច្ចការប្រកបដោយប្រសិទ្ធភាពនៅក្នុងបរិបទសេដ្ឋកិច្ចនាសតវត្សរ៍ទី ២១។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡា មានសេចក្តីរីករាយដែលបានបញ្ចូលមេរៀនផ្លូវការមួយស្តីពីការគិតបែបគណនា ទៅក្នុងឯកសារបណ្តុះបណ្តាលនេះ។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រាជធានីភ្នំពេញ
ខែកញ្ញា ឆ្នាំ ២០២៣

[1] https://www.kapekh.org/files/report_file/179-en.pdf

[2] https://www.kapekh.org/files/report_file/371-en.pdf

# សេចក្ដីផ្ដើម

# ១. សេចក្តីផ្តើម

## ១.១ ទិដ្ឋភាពទូទៅ



**ទូទៅ៖** ឯកសារនេះមានគោលបំណងជួយអ្នកអប់រំនៅកម្ពុជាឱ្យប្តូរវិធីសាស្ត្របង្រៀនពីគំរូ "ការសិក្សាបែបអកម្ម" ដែលសិស្សត្រូវបានគេគិតថាចាំតែទទួលចំណេះដឹងពីគ្រូមកវិធីសាស្ត្រថ្មីមួយដែលសិស្សជាអ្នករៀនបង្កើតចំណេះដឹងថ្មីៗដោយខ្លួនឯង។ ទ្រឹស្តីនៃការសិក្សានេះត្រូវបានគេស្គាល់ថា *"ការសិក្សាបែបស្ថាបនានិយម"* ដែលវាជាគំនិតថ្មីមួយជួយឱ្យមានការផ្លាស់ប្តូរ។ នៅពេលប្រទេសកម្ពុជាឈានចូលដល់សតវត្សរ៍ទី ២១ មានតម្រូវការកើនឡើងជាច្រើនសម្រាប់ប្រព័ន្ធអប់រំ ដើម្បីផលិតកម្លាំងការងារដែលមានការគិតបែបស៊ីជម្រៅ អាចដោះស្រាយបញ្ហា និងចេះសហការគ្នាធ្វើការ។ យន្តការនៃវិធីសាស្ត្របង្រៀនពីអតីតកាលដែលបានផ្តោតតែលើការសិក្សាបែបទន្ទេញ ឬសូត្រតាមតែមួយមុខមិនអាចឆ្លើយតបទៅនឹងតម្រូវការទាំងអស់ខាងលើនេះបានទេ។ **ការសិក្សាបែបស្ថាបនានិយម** គឺគេបង្កើតឡើងក្នុងគោលបំណងដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនោះ។

ដើម្បីបំពេញបន្ថែមទៅលើការពិភាក្សាអំពី ការសិក្សាបែបស្ថាបនានិយម ឯកសារនេះក៏ផ្តល់នូវសេចក្តីណែនាំខ្លីៗសម្រាប់អ្នកអប់រំស្តីពី 'ការគិតបែបគណនា' ដែលសំដៅលើវិធីនៃការគិតដែលលើកកម្ពស់ការប្រើប្រាស់តក្កវិជ្ជា និងជំនាញដោះស្រាយបញ្ហានៅក្នុងបរិបទជាច្រើន។ ដោយសារតែវាផ្តោតសំខាន់លើជំនាញនៃការគិតកម្រិតខ្ពស់ ការគិតបែបគណនាបានបំពេញបន្ថែមយ៉ាងច្រើនទៅលើការពិភាក្សាអំពី ការសិក្សាបែបស្ថាបនានិយម។

**ទ្រឹស្តីការសិក្សាបែបស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗទៀត៖** ការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្តីមួយទូលំទូលាយដែលពាក់ព័ន្ធជាមួយទស្សនទានផ្សេងៗទៀត។ ក្រៅពីជាតុស្នូលសំខាន់ៗនៃទ្រឹស្តីនេះ ដែល*សិស្សមានសមត្ថភាពក្នុងការបង្កើតបញ្ញត្តិ* នៅមាន



ធាតុសំខាន់ៗផ្សេងទៀតពាក់ព័ន្ធរួមមាន ការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា ការសិក្សាបែបសហការ និងការប្រើប្រាស់បច្ចេកវិទ្យាជាដើម។ *ការសិក្សាបែបស្ថាបនានិយម* ក៏បានដាក់បញ្ចូលផងដែរនូវវិធីសាស្ត្របង្រៀនផ្សេងៗ មានគោលដៅដូចគ្នាដូចជា ការសិក្សាអាស្រ័យលើបញ្ហា ការសិក្សាស្រាវជ្រាវ ការសិក្សាតាមបែបរិះរក ជាដើម។ ហេតុដូច្នេះ ហើយការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្ដីជម្រើសមួយដែលមានវិធីសាស្ត្របង្រៀនជាច្រើនបញ្ចូលគ្នា។

**ការសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា៖**



ទោះបីជាការសិក្សាបែបស្ថាបនានិយមកើតមានយូរហើយក៏ដោយ ការប្រើប្រាស់វាទើបតែបានកើនឡើងនៅពេលពិភពលោកឈានចូលក្នុងយុគសម័យបច្ចេកវិទ្យាប៉ុណ្ណោះ។ បច្ចេកវិទ្យាព័ត៌មានវិទ្យា បានបង្កើនប្រសិទ្ធភាពនៃវិធីសាស្ត្រសិក្សាបែបស្ថាបនានិយម ក្នុងការលើកកម្ពស់ការសិក្សាបែបសហការ (ដូចជា៖ តាមរយៈបណ្ដាញកុំព្យូទ័រ) ដើម្បីរៀបចំ និងសំយោគព័ត៌មានថ្មីៗ (ដូចជា៖ តាមរយៈការប្រើប្រាស់ Power Point) និងដើម្បីដោះស្រាយបញ្ហា (ឧ. តាមរយៈកម្មវិធីគ្រប់គ្រងនិងរៀបចំទិន្នន័យ ជាដើម)។ ដូច្នេះហើយការប្រើប្រាស់បច្ចេកវិទ្យា ជាឧបករណ៍ដ៏សំខាន់មួយដើម្បីជួយសិស្សឱ្យអាចបង្កើតបញ្ញត្តិថ្មីៗបាន ដែលចំណុចនេះ ជាធាតុស្នូលសំខាន់នៃវិធីសាស្ត្រការសិក្សាបែបស្ថាបនានិយម។ ការបង្កើតបញ្ញត្តិនេះ គឺសំខាន់ណាស់ដើម្បីជំរុញឱ្យមាន*ការគិតបែបស៊ីជម្រៅ*ដែលជាបំណិនចាំបាច់មួយសម្រាប់ទីផ្សារការងារក្នុងយុគសម័យថ្មីនេះ។ ដូច្នេះហើយ វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាង **ការសិក្សាបែបស្ថាបនានិយម បច្ចេកវិទ្យា** និង**តម្រូវការនៃទីផ្សារការងារនៅសតវត្សរ៍ទី ២១** នេះ ។

**ក្រុមគោលដៅ៖** ក្រុមគោលដៅសម្រាប់កម្មវិធីបណ្ដុះបណ្ដាលដែលបរិយាយក្នុងឯកសារនេះ គឺសម្រាប់គ្រូនៅកម្រិតមធ្យមសិក្សាបង្រៀនសិស្សថ្នាក់ទី៧ ដល់ថ្នាក់ទី១២។ តែទោះជាយ៉ាងនេះក្ដី ខ្លឹមសារនៃកម្មវិធីបណ្ដុះបណ្ដាលនេះក៏អាចយកទៅប្រើប្រាស់សម្រាប់គ្រូបង្រៀននៅកម្រិតណាក៏បានដែរ។ ឯកសារនេះមានបំណងជួយគ្រូឱ្យមានស្តង់ដាបង្រៀនតាមតម្រូវការនៃការអប់រំនៅសតវត្សរ៍ទី ២១ ដោយផ្លាស់ប្ដូរការបង្រៀនបែបវិធីសាស្ត្រឧទ្ទេសមកជាអ្នកសម្របសម្រួលការសិក្សាវិញ។

## ១.២ គោលបំណង និងខ្លឹមសារឯកសារនេះ

ឯកសារបណ្ដុះបណ្ដាលនេះ ត្រូវបានបង្កើតឡើងជាឯកសារបំប៉នគ្រូបង្គោល (Training of

Trainers -ToT ) ដើម្បីជួយគ្រូនៅកម្រិតមធ្យមសិក្សាឱ្យអាចប្រើប្រាស់វិធីសាស្ត្រការសិក្សាបែបស្ថាបនានិយម និងការគិតបែបគណនា នៅក្នុងថ្នាក់រៀនរបស់ពួកគេបាន។ ជាពិសេស ឯកសារនេះគឺជាតម្រូវការដើម្បីជួយគ្រូឱ្យផ្តោតលើការលើកកម្ពស់បំណិនការគិតកម្រិតខ្ពស់ដែលមានបំណិនវិភាគ វាយតម្លៃ និងបង្កើតថ្មីនៅពេលបង្រៀនគ្រប់មុខវិជ្ជាទាំងអស់។

ឯកសារនេះមានផែនការបង្រៀនតាមផ្នែក សម្រាប់គ្រូឧទ្ទេសងាយស្រួលប្រើប្រាស់ក្នុងការធ្វើការបង្ហាញណែនាំគ្រូបង្រៀននូវបញ្ញត្តិមូលដ្ឋានពីការសិក្សាបែបស្ថាបនានិយម និង ការគិតបែបគណនា។ ផ្នែកនីមួយៗនៃផែនការបង្រៀនមានបញ្ជាក់ពីពេលវេលា ឈ្មោះសំខាន់ៗ ឯកសារ សម្ភារៈចាំបាច់ត្រូវត្រៀម និងគោលបំណងនៃការសិក្សា។ ឯកសារនេះក៏មានភ្ជាប់មកជាមួយផងដែរនូវឯកសារសម្រាប់សិក្ខាកាមចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលនេះ ដូច្នេះហើយ ពួកគាត់អាចប្រើប្រាស់ឯកសារទាំងនេះជាឯកសារយោង បន្ទាប់ពីបញ្ចប់វគ្គសិក្ខាសាលាបណ្តុះបណ្តាលនេះផងដែរ។

**ខ្លឹមសារពាក់ព័ន្ធ៖** ខ្លឹមសារនៃឯកសារនេះត្រូវបានរៀបចំដោយមានលទ្ធផលរំពឹងទុកដូចខាងក្រោម៖

- សិក្ខាកាមអាចកំណត់និយមន័យការសិក្សាបែបស្ថាបនានិយម និងគោលការណ៍សំខាន់ៗ
- សិក្ខាកាមអាចបង្ហាញថាពួកគេយល់ពីរបៀបប្រើប្រាស់សកម្មភាពជាក់ស្តែងក្នុងការអនុវត្តគោលវិធីការសិក្សាបែបស្ថាបនានិយមនេះ ។
- សិក្ខាកាមអាចពន្យល់ពីវិធីកាន់តែងាយស្រួលក្នុងការអនុវត្តសកម្មភាពផ្សេងៗតាំងពីដើម ដល់បញ្ចប់មេរៀនដោយប្រើការសិក្សាបែបស្ថាបនានិយម និងពីភាពចាំបាច់ដើម្បីវាយតម្លៃចំណេះដឹងសិស្សដោយប្រើប្រាស់ការវាយតម្លៃស្តង់ដា។
- សិក្ខាកាមអាចពន្យល់បានពីរបៀបរៀបចំបរិបទស្ថាប័ននៅតាមសាលារៀនរបស់ពួកគេដើម្បីជំរុញការសិក្សាតាមបែបស្ថាបនានិយម។
- សិក្ខាកាមអាចកំណត់និយមន័យនៃការគិតបែបគណនា និងបញ្ចូលវាជាវិធីសាស្ត្រមួយក្នុងការបង្រៀនរបស់ពួកគេ ដើម្បីលើកកម្ពស់ការគិតបែបវិភាគ និងការដោះស្រាយបញ្ហា។

## ១.៣ ការអនុវត្តការសិក្សាបែបស្ថាបនានិយមក្នុងប្រទេសកម្ពុជា



ឯកសារនេះ រៀបចំឡើងជាពិសេសសម្រាប់គ្រូបង្រៀនក្នុង *កម្មវិធីសាលារៀនជំនាន់ថ្មី* ដែលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាមាននៅសាលា និងអ្នកចូលចិត្តធ្វើការពិសោធនូវរបៀបបង្រៀនថ្មីៗ។ ទោះបីជាបច្ចេកវិទ្យាមិនត្រូវបានប្រើប្រាស់គ្រប់ពេលសម្រាប់ថ្នាក់រៀនតាមបែបស្ថាបនានិយមក៏ដោយ ក៏វាអាចជួយពង្រីកការអនុវត្តការបង្រៀនបែបស្ថាបនានិយមឱ្យកាន់តែមានប្រសិទ្ធភាពដូចបានរៀបរាប់ខាងលើ។ ការប្រើប្រាស់បច្ចេកវិទ្យា គឺសំដៅលើការសិក្សាស្រាវជ្រាវមេរៀន ការប្រើប្រាស់ម៉ាស៊ីន LCD បញ្ចាំងស្លាយ ឧបករណ៍សិក្សាចល័ត និងកម្មវិធីអប់រំថ្មីៗដែលសមស្របទៅនឹងការសិក្សាបែបសកម្ម។ ស្រដៀងគ្នានេះដែរ គ្រូបង្រៀនក្នុងសាលារៀនរដ្ឋដែលមិនស្ថិតនៅក្នុង កម្មវិធីសាលារៀនជំនាន់ថ្មី ក៏អាចយកទៅអនុវត្តបានដែរចំពោះការសិក្សាបែបស្ថាបនានិយមនេះសម្រាប់ថ្នាក់រៀនរបស់ពួកគេ ទោះបីជាមិនទាន់មានបច្ចេកវិទ្យាប្រើប្រាស់គ្រប់គ្រាន់ក៏ដោយ។ គ្រូត្រូវពិភាក្សាជាមួយ នាយកសាលា និងសហការីផ្សេងទៀត នូវរបៀបអនុវត្តគោលវិធីបង្រៀនបែបស្ថានានិយមនេះដោយផ្អែកទៅលើសេចក្ដីណែនាំបានបង្ហាញនៅក្នុងឯកសារនេះ។

ជាចុងក្រោយ សូមចងចាំថា ឯកសារនេះគ្រាន់តែជាការណែនាំខ្លីមួយ សម្រាប់គោលការណ៍អនុវត្តការសិក្សាបែបស្ថាបនានិយមប៉ុណ្ណោះ។ គ្រូបង្រៀនជាច្រើនចំណាយពេលច្រើនខែ និងឆ្នាំក្នុងការកែលម្អសមត្ថភាពរបស់គេក្នុងការអនុវត្តគោលការណ៍ទាំងនេះឱ្យមានប្រសិទ្ធភាពក្នុងថ្នាក់រៀន។ ហេតុដូច្នេះហើយ អ្នកត្រូវចងចាំថា ឯកសារនេះអាចជួយគ្រូបង្រៀនស្គាល់ត្រួសៗ ពីគោលការណ៍សិក្សាបែបស្ថាបនានិយមប៉ុននោះ វាទាមទាឱ្យមានការអនុវត្ត និងសិក្សាស្វែងយល់បន្ថែមច្រើនឆ្នាំទៀតដើម្បីឱ្យមានភាពស្ទាត់ជំនាញលើបច្ចេកទេសបានបង្ហាញ។

## ១.៤ ការគិតបែបគណនា៖ និយមន័យ និងការអនុវត្ត




ថ្មីៗនេះ មេរៀនថ្មីមួយស្តីពីការគិតបែបគណនាត្រូវបានបញ្ចូលទៅក្នុងឯកសារនេះ ដែលផ្តល់និយមន័យមូលដ្ឋានមួយចំនួនស្តីការគិតប្រភេទនេះ ព្រមទាំងឧទាហរណ៍នៃការអនុវត្តជាក់ស្តែងផងដែរ។ ថ្វីត្បិតតែការគិតបែបគណនាបានចាប់ផ្តើមដំបូងក្នុងនាមជាក្របខ័ណ្ឌគំនិតដែលត្រូវបានប្រើក្នុងវិទ្យាសាស្ត្រកុំព្យូទ័រក៏ដោយ ក៏វាបានវិវត្តយ៉ាងឆាប់រហ័សដែលអាចយកមកអនុវត្តលើគ្រប់មុខវិជ្ជាទាំងអស់។ ការគិតបែបគណនាពាក់ព័ន្ធនឹងការអភិវឌ្ឍនៃសមត្ថភាពក្នុងការគិតត្រិះរិះពិចារណា និងសមត្ថភាពផ្លូវអារម្មណ៍ជាច្រើន ដែលធ្វើឱ្យសិស្សទទួលបានជោគជ័យរយៈពេលយូរអង្វែង។ នៅពេលកុមារសិក្សាពីជំនាញគិតបែបគណនា វាជួយពួកគេឱ្យអភិវឌ្ឍជំនាញផ្សេងៗដែលមានសារៈសំខាន់មិនត្រឹមតែសម្រាប់មុខវិជ្ជា STEM ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់វិទ្យាសាស្ត្រសង្គម សិល្បៈ និងភាសាផងដែរ។ ដោយសារជំនាញគិតនេះផ្តោតសំខាន់ទៅលើ 'ការបំបែក' ព័ត៌មាន និងការប្រមូលផ្តុំឡើងវិញដើម្បីរកដំណោះស្រាយ ឬទស្សនៈថ្មីលើបញ្ហាជាក់លាក់ណាមួយ ហើយប្រភេទនៃការគិតនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទស្សនៈសិក្សាបែបស្ថាបនានិយមដែលផ្តោតលើ 'ការស្ថាបនា' ឬ 'ការស្ថាបនាឡើងវិញ' នៃចំណេះដឹង។

*ទំនាក់ទំនងរវាងវិទ្យាសាស្ត្រកុំព្យូទ័រ/ការសរសេរកូដ និងការគិតបែបគណនា ដែលមានប្រភពចេញពីបញ្ញត្តិទីមួយ។*




* * * * * * * * * * * * * * * * *

# របៀបប្រើប្រាស់ ឯកសារនេះ

# ២. របៀបប្រើប្រាស់ឯកសារនេះ

ឯកសារនេះប្រើប្រាស់និមិត្តសញ្ញាស្តង់ដាមួយចំនួនដូចខាងក្រោមដើម្បីងាយស្រួលប្រើប្រាស់តាមដែលអាចធ្វើទៅបានសម្រាប់គ្រូឧទ្ទេស។ និមិត្តសញ្ញាទាំងនេះ បង្ហាញពីសកម្មភាពផ្សេងៗដើម្បីប្រើប្រាស់ជាមួយសិក្ខាកាមសម្រាប់ជំហាននីមួយៗនៃផែនការមេរៀន។

**រយៈពេលបង្រៀន**

**ការរៀបចំមុនពេលបណ្តុះបណ្តាល៖** មានព័ត៌មានពីការរៀបចំផ្នែកផ្សេងៗដែលត្រូវបំប៉ន ហើយវាបង្ហាញផងដែរពីសម្ភារៈ និងការប្រើប្រាស់សម្រាប់សកម្មភាពផ្សេងៗ។

**សម្ភារៈឧបទ្ទេស៖** ផ្នែកនេះបង្ហាញពីសម្ភារៈចាំបាច់សម្រាប់ការបំប៉ន។ សម្ភារៈដែលយើងត្រូវការជាងគេនោះភាគច្រើនគឺហ្វឺត និងក្រដាសផ្ទាំងធំ។ សម្ភារៈផ្សេងទៀត គឺមាននៅក្នុងមេរៀនបំប៉នសម្រាប់សិក្ខាកាមភ្ជាប់ក្នុងឯកសារនេះស្រាប់។

**លទ្ធផលរំពឹងទុក៖** បង្ហាញពីអ្វីដែលរំពឹងថាសិក្ខាកាមនឹងទទួលបាន និងការវាយតម្លៃនៅពេលបញ្ចប់ការបំប៉ននេះ។

## និមិត្តសញ្ញាបង្ហាញពីជំហាន និងដំណើរការ

ផ្នែកទី៣ នៃឯកសារនេះ ផ្តល់ជាលំដាប់លំដោយនៃមេរៀនស្តីពីរបៀបបំប៉នគ្រូបង្រៀន ដែលរំពឹងប្រើប្រាស់បច្ចេកទេសការសិក្សាបែបស្ថាបនានិយមនៅក្នុងថ្នាក់រៀន។ និមិត្តសញ្ញាខាងក្រោមនឹងអាចឱ្យអ្នកសម្របសម្រួលដឹងភ្លាមៗ ពីសកម្មភាពជាក់ស្តែងដែលត្រូវរៀបចំផែនការបំប៉ននេះ។ ផ្នែកនៃឯកសារនេះរួមបញ្ចូលទាំងសកម្មភាពត្រូវធ្វើ សំណួរត្រិះរិះ ឧទាហរណ៍ដើម្បីបញ្ជាក់ពីការអនុវត្តលំហាត់ និងកិច្ចការផ្សេងៗទៀត។ ទោះបីជា វាជាការចាំបាច់ដែលអ្នកត្រូវអានមេរៀនទាំងមូលឱ្យបានយល់ច្បាស់ ពិសេសគឺការបំប៉នលើកទី ១ គ្រូឧទ្ទេសអាចដឹងយ៉ាងងាយស្រួលនូវអ្វីដែលគាត់ត្រូវធ្វើដោយមើលនិមិត្តសញ្ញាដែលប្រើប្រាស់ក្នុងឯកសារនេះ។

**សកម្មភាពត្រូវធ្វើ៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវធ្វើសកម្មភាពដូចជាការចែកឯកសារឱ្យសិក្ខាកាម រៀបចំតុកៅអី និងការបែងចែកក្រុមពិភាក្សាជាដើម។

**ការសួរសំណួរ៖** នេះបង្ហាញថាអ្នកសម្របសម្រួលត្រូវសួរសំណួរសំខាន់ៗទៅសិក្ខាកាមដូចជាការផ្ដើមសកម្មភាព ឬពិភាក្សា។

**ការពិភាក្សា៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវដឹកនាំការពិភាក្សា ឬអនុញ្ញាតឱ្យអ្នកចូលរួមពិភាក្សាអ្វីមួយក្នុងក្រុមរបស់ពួកគេ។

**កិច្ចការសរសេរ៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកចូលរួមត្រូវសរសេរអ្វីមួយនៅលើក្រដាសផ្ទាំងធំ បំពេញលំហាត់ ឬកិច្ចការសរសេរផ្សេងទៀត។

**ការពន្យល់៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវពន្យល់ដល់សិក្ខាកាម។

* * * * * * * * * * * * * * * * *

# ផែនការមេរៀន
# សម្រាប់
# អ្នកសម្របសម្រួល
## ផ្នែកទី១៖ ទ្រឹស្តីសិក្សាបែបស្ថាបនានិយម

# មេរៀនទី៣.១ តើការសិក្សាបែបស្ថាបនានិយមគឺជាអ្វី?

**រយៈពេលបង្រៀន៖** ២ម៉ោង និង៣០នាទី

**ការត្រៀមលក្ខណៈរបស់គ្រូឧទ្ទេស៖**

- សរសេរលទ្ធផលសិក្សានៃមេរៀននេះនៅលើក្រដាសផ្ទាំងធំណែនាំមេរៀន។
- ថតចម្លង**ឯកសារទី ១៖** *ការផ្សាភ្ជាប់ការសិក្សាបែបស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗ*
- ថតចម្លង**ឯកសារទី ២ក៖** *និយមន័យការសិក្សាបែបស្ថាបនានិយម*
- ថតចម្លង**ឯកសារទី ២ខ៖** *គោលការណ៍សំខាន់ៗក្នុងការសិក្សាបែបស្ថាបនានិយម*
- ថតចម្លង**ឯកសារទី ៣៖** *ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាព?*
- សរសេរគោលការណ៍សិក្សាបែបស្ថាបនានិយមនីមួយៗ (បង្ហាញក្នុងឯកសារទី ២ខ) ចូលក្នុងក្រដាសផ្ទាំងធំ (ពាក់កណ្តាលខាងលើ) ដោយទុកកន្លែងទំនេរខាងក្រោមនៃក្រដាសនីមួយៗសម្រាប់សិក្ខាកាមសរសេរឧទាហរណ៍។

**សម្ភារឧបទ្ទេសត្រូវការ៖**

- ក្រដាសផ្ទាំងធំ ហ្វឺតសរសេរ
- ក្រដាសផ្ទាំងធំដែលសង្ខេបពីលទ្ធផលរំពឹងទុករបស់មេរៀន។
- **ឯកសារទី១៖** ការផ្សាភ្ជាប់ទ្រឹស្តីការសិក្សាបែបស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗ
- **ឯកសារទី២ក៖** និយមន័យការសិក្សាបែបស្ថាបនានិយម
- **ឯកសារទី២ខ៖** គោលការណ៍សំខាន់ៗក្នុងការសិក្សាបែបស្ថាបនានិយម
- **ឯកសារទី៣៖** ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាព
- ក្រដាសផ្ទាំងធំដែលបានសរសេរគោលការណ៍សំខាន់ៗនៃស្ថាបនានិយម

## លទ្ធផលសិក្សា៖

- អ្នកចូលរួមអាច**ពន្យល់**គោលការណ៍សំខាន់ៗនៃការសិក្សាបែបស្ថាបនានិយម ពិសេសទំនាក់ទំនងរវាងទ្រឹស្តីស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងទៀត
- អ្នកចូលរួមអាច**ផ្តល់ឧទាហរណ៍**ពីសកម្មភាពជាក់ស្តែងពីគោលការណ៍សំខាន់ៗ នៃការសិក្សាបែបស្ថាបនានិយម។
- អ្នកចូលរួមអាច**បង្កើតដ្យាក្រាម**ដែលបកស្រាយពីទំនាក់ទំនងរវាងគោលការណ៍សំខាន់ៗ នៅក្នុងការសិក្សាបែបស្ថាបនានិយម
- អ្នកចូលរួមអាច**ពន្យល់**ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាពចំពោះការបង្កើនការចងចាំ និងយល់ដឹងបានល្អ។
- អ្នកចូលរួមអាច**កំណត់**បាននូវសកម្មភាព "ការចូលរួមសកម្ម" ដែលនឹងជំរុញការកាត់បន្ថយសកម្មភាពអកម្មបានច្រើន។

* * * * * * * * * * * * * * * * *

## ផែនការមេរៀន

### វត្ថុបំណងមេរៀន

បិទក្រដាសផ្ទាំងធំនៅលើក្តារខៀនដែលសង្ខេបពីវត្ថុបំណង ឬការរំពឹងទុករបស់មេរៀន។ ពន្យល់ពីលទ្ធផលរំពឹងទុក និងអ្វីដែលអ្នកចូលរួមអាចធ្វើបាននៅពេលបញ្ចប់មេរៀន។

### ការណែនាំទ្រឹស្តីស្ថាបនានិយមជាទ្រឹស្តីដែលបញ្ចូលគ្នារវាងទ្រឹស្តីសិក្សាផ្សេងៗជាច្រើន

អ្នកសម្របសម្រួលត្រូវតែចាប់ផ្តើមផ្នែកនេះជាមួយការពន្យល់ពីគំនិតសំខាន់ៗ នៃការសិក្សាបែបស្ថាបនានិយម ដោយចេញពីពាក្យ "ស្ថាបនា"។ នោះមានន័យថា **ស្ថាបនានិយម គឺការសិក្សាផ្តោតទៅលើការស្ថាបនា ឬបង្កើតបញ្ញត្តិ។**

**ការសិក្សាបែបស្ថាបនានិយម** គឺជាទ្រឹស្តីមួយបូកបញ្ចូលទ្រឹស្តីសិក្សាផ្សេងៗទៀតជាច្រើន។ នេះរួមបញ្ចូលការបង្កើតបញ្ញត្តិ (គោលការណ៍ស្នូល) ការសហការក្នុងក្រុម ការឆ្លុះបញ្ចាំងពីបទពិសោធន៍ពីមុន តួនាទីរបស់បច្ចេកវិទ្យា ការស្រមើស្រមៃ និងកត្តាផ្សេងៗទៀតជាច្រើន។

ចែក **ឯកសារទី១៖** "ការផ្សាភ្ជាប់ទ្រឹស្តីស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗទៀតដើម្បីបង្ហាញពីទំនាក់ទំនងរបស់វា។




បន្ទាប់មក គ្រូឧទ្ទេសត្រូវដឹកនាំការពិភាក្សាពីគោលការណ៍សំខាន់ៗបង្ហាញក្នុងដ្យាក្រាមខាងលើ សួរថាតើទ្រឹស្តីទាំងនេះពាក់ព័ន្ធទៅនឹងគោលការណ៍នៃការសិក្សាបែបស្ថាបនានិយមដូចម្តេច? សូមកុំព្យាយាមបង្ហាញព័ត៌មាននេះដោយផ្ទាល់ដល់អ្នកចូលរួម ប៉ុន្តែត្រូវធ្វើការសំយោគចម្លើយរបស់អ្នកចូលរួម។ អ្នកសម្របសម្រួលត្រូវតែពិនិត្យមើលថាតើអ្នកចូលរួមបានយល់ដឹងពីទ្រឹស្តីផ្សេងៗទៀតកម្រិតណាដែរ (១. ការសិក្សាតាមបែបរិះ

រក ការសិក្សាអាស្រ័យលើបញ្ហា។ល។) សំណួរគន្លឹះខ្លះត្រូវបានផ្តល់ឱ្យខាងក្រោមនៃ **ឯកសារទី១**។

អំឡុងពេលធ្វើសកម្មភាព *សួរ និងឆ្លើយសំណួរ* សូមប្រើប្រាស់ព័ត៌មានខាងក្រោមដើម្បីជួយអ្នកចូលរួមឆ្លើយសំណួរបានត្រឹមត្រូវដោយមិនចាំបាច់ប្រាប់ត្រង់ៗ៖

- ***ការសិក្សាអាស្រ័យលើបញ្ហា៖*** ការដោះស្រាយបញ្ហាទាមទារឱ្យយើងត្រូវឆ្លុះបញ្ចាំងបទពិសោធន៍ធ្លាប់ដឹង និងបរិបទថ្មីដើម្បីស្វែងរក ឬ "ស្ថាបនា" គំនិតថ្មីមួយដែលអាចដោះស្រាយបញ្ហានោះបាន។ ការឆ្លុះបញ្ចាំងបទពិសោធន៍ធ្លាប់ជួបរបស់នរណាម្នាក់ពីមុនដើម្បីស្វែងរកគំនិតថ្មីៗ គឺជាគោលការណ៍ស្នូលនៃទ្រឹស្តីការសិក្សាបែបស្ថាបនានិយម។
- ***ការសិក្សាតាមបែបរិះរក៖*** ការសិក្សាបែបស្ថាបនានិយមលើកកម្ពស់គំនិតដែលថាយើងអាចចងចាំអ្វីៗ កាន់តែល្អ ប្រសិនបើយើងរិះរកវាដោយខ្លួនឯងតាមរយៈការពិភាក្សា ការពិសោធ និងយុទ្ធវិធីសិក្សាបែបសកម្មផ្សេងៗទៀត។
- ***ប្លូមតាក់សូណូមី( Bloom's Taxonomy)៖*** ការសិក្សាបែបស្ថាបនានិយមផ្តោតខ្លាំងលើបំណិនការគិតកម្រិតខ្ពស់រួមមានការវិភាគ វាយតម្លៃ និងបង្កើតថ្មី។
- ***ការគិតពិចារណាស៊ីជម្រៅ៖*** ការវិភាគ ការវាយតម្លៃ និងបង្កើតថ្មីគឺជាបំណិនសំខាន់ៗ ក្នុងការគិតបែបស៊ីជម្រៅ។
- ***ការសហការ៖*** ការធ្វើការងារជាមួយអ្នកផ្សេងទៀតក្នុងក្រុមដើម្បីផ្លាស់ប្តូរគំនិតយោបល់គ្នាអាចធ្វើទៅបាន លុះត្រាតែតាមរយៈ*ការពិភាក្សា* ហើយ*ការពិភាក្សា*នេះនាំឱ្យមានការបង្កើតបញ្ញត្តិ និងជំរុញឱ្យសិស្សអាចសំយោគគំនិតប្លែកៗ ។
- ***បច្ចេកវិទ្យា៖*** បច្ចេកវិទ្យាព័ត៌មានវិទ្យា បានជួយបង្កើនប្រសិទ្ធភាពនៃការសិក្សាបែបស្ថាបនានិយម ដើម្បីលើកកម្ពស់*ការសិក្សាបែបសហការ* (ឧទាហរណ៍៖ តាមរយៈការប្រើប្រាស់បណ្តាញ Network) *សិស្សបង្កើត និងសំយោគព័ត៌មានថ្មីៗ* (ឧទាហរណ៍៖ តាមរយៈការប្រើប្រាស់ PowerPoint) និង*ដោះស្រាយបញ្ហាផ្សេងៗ* (ឧទាហរណ៍៖ តាមរយៈកម្មវិធីគ្រប់គ្រង និងរៀបចំទិន្នន័យជាដើម)។ ដូច្នេះការប្រើប្រាស់បច្ចេកវិទ្យា ជាឧបករណ៍ដ៏សំខាន់មួយដើម្បីជួយសិស្សអាចបង្កើតបញ្ញត្តិបាន ដែលចំណុចនេះ ជាធាតុស្នូលសំខាន់នៃគោលវិធីសិក្សាបែបស្ថាបនានិយម។

## ការកំណត់និយមន័យស្ថាបនានិយម និងគោលការណ៍សំខាន់ៗដែលគាំទ្រទ្រឹស្តីនេះ

ចាប់ផ្តើមផ្នែកនេះដោយចែក **ឯកសារចែកទី២ក៖** “ការកំណត់និយមន័យការសិក្សាបែបស្ថាបនានិយម”។

ពន្យល់ដោយបញ្ជាក់ឱ្យបានច្បាស់ថា ការសិក្សាតាមបែបស្ថាបនានិយមត្រូវទាមទារឱ្យមានការបង្កើតនូវបញ្ញត្តិថ្មីៗដោយសិស្សផ្ទាល់។ ពេលបង្ហាញបញ្ហាណាមួយ សិស្សផ្ទុះបញ្ចាំងបញ្ហានេះ ដោយត្រូវប្រៀបធៀបទៅនឹងបទពិសោធន៍ដែលពួកគេធ្លាប់ជួប និងចុងក្រោយមកទៀតបង្កើតបញ្ញត្តិថ្មី។

### តើការសិក្សាបែបស្ថាបនានិយមគឺជាអ្វី?

- ការសិក្សាសកម្ម & ដឹកនាំខ្លួនឯង
- កសាងចំណេះដឹងថ្មីដោយផ្អែកទៅលើចំណេះដឹង និងបទពិសោធន៍មានស្រាប់
- ផ្ទុះបញ្ចាំងពីទំនាក់ទំនងរវាងបញ្ញត្តិផ្សេងៗដើម្បីបង្កើតបញ្ញត្តិថ្មីៗ
- ការផ្លាស់ប្តូរគំនិតគ្នាតាមរយៈការសហការជំរុញឱ្យមានដំណើរការបង្កើតគំនិតថ្មី



*“ការបង្កើតបញ្ញត្តិថ្មីៗតាមរយៈការសហការ និងផ្លាស់ប្តូរគំនិតគ្នា”*

យើងអាចបង្ហាញដំណើរការនេះដោយសរសេររូបមន្តនៅលើក្តារខៀន៖

**ការដឹកនាំខ្លួនឯង+ការផ្ទុះបញ្ចាំងពីបញ្ហា/ចំណេះដឹងពីមុន+ការសហការ= ការសិក្សាបែបស្ថាបនានិយម**

សាកល្បងធ្វើឧទាហរណ៍ដែលបង្ហាញពីដំណើរការខាងលើនេះជាមួយគ្នា។ ឧទាហរណ៍៖ ចូរឱ្យឧទាហរណ៍ផ្សេងៗ នៃសទិសភាព (Analogy)៖

**ឧទាហរណ៍៖** *ឪពុក ជាគូ កូនប្រុស ដូចគ្នាទៅនឹង ម្តាយ ជាគូ កូនស្រី*

ប្រើប្រាស់ឧទាហរណ៍ខាងលើ សួរអ្នកចូលរួមឱ្យបង្កើតសទិសភាពផ្សេងទៀតឱ្យបាន ៤ ដែលបង្ហាញទំនាក់ទំនងស្រដៀងគ្នា។ លំហាត់ទាក់ទងនឹងចំណុចនេះត្រូវបានពន្យល់បន្ថែមក្នុង **ឯកសារទី ២ក**។

ផ្តល់ឱ្យអ្នកចូលរួមប្រហែលជា ១៥នាទី សម្រាប់ការធ្វើលំហាត់នេះ និងបន្ទាប់មកឱ្យក្រុមនីមួយៗ សរសេរពីសទិសភាពបានបង្កើតនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ទាប់មកឱ្យអ្នកចូលរួមបំពេញលំហាត់បន្ថែមទៀត ដែលបង្ហាញពីដំណើរការវិភាគសទិសភាព។

បន្ទាប់ពីការពិភាក្សារយៈពេលខ្លីអំពីសទិសភាពរួចមក អនុវត្តការវិភាគពីធាតុផ្សេងៗនៃការសិក្សាបែបស្ថាបនានិយមដែលលំហាត់នេះបានបង្ហាញ។ ធ្វើកិច្ចការនេះជាក្រុមធំ។ ឧទាហរណ៍៖ សួរអ្នកចូលរួមនូវសំណួរដូចខាងក្រោម៖

- តើផ្នែកណាមួយនៃលំហាត់នេះបង្ហាញពី "ការដឹកនាំខ្លួនឯង"?
  ***ចម្លើយ៖*** *អ្នកចូលរួមជ្រើសរើសគូសទិសភាពដោយខ្លួនឯង។*
- តើផ្នែកណានៃលំហាត់នេះបង្ហាញពី "ការឆ្លុះបញ្ចាំង" ដោយប្រើប្រាស់ចំណេះដឹងពីមុន?
  ***ចម្លើយ៖*** *អ្នកចូលរួម ឆ្លុះបញ្ចាំងលើឧទាហរណ៍ផ្តល់ដោយអ្នកសម្របសម្រួល ហើយពួកគាត់អនុវត្តចំណេះដឹងនេះទៅការបង្កើតគូសទិសភាពថ្មី។*
- តើផ្នែកណានៃលំហាត់នេះបង្ហាញពី "ការសហការ"?
  ***ចម្លើយ៖*** *អ្នកចូលរួមបានពិភាក្សាក្នុងក្រុម បង្កើតបានសទិសភាពផ្សេងៗជាច្រើន ដែលមានភាពល្អប្រសើរជាងការធ្វើការជាបុគ្គល។*

លំហាត់នេះជាឧទាហរណ៍គំរូមួយនៃការសិក្សាបែបស្ថាបនានិយម។

## គោលការណ៍សំខាន់ៗនៃការសិក្សាបែបស្ថាបនានិយម

សរសេរគោលការណ៍សំខាន់ៗ ៥ ដែលជាមូលដ្ឋាននៃការសិក្សាបែបស្ថាបនានិយមនៅលើក្តារខៀន។

ផ្តល់ការពន្យល់ពីគោលការណ៍នីមួយៗ ផ្អែកលើព័ត៌មានបានផ្តល់ឱ្យក្នុង **ឯកសារទី២ខ** ប៉ុន្តែកុំផ្តល់ឧទាហរណ៍។ សូមកុំចែកឯកសារ នៅដំណាក់កាលបំប៉ននេះ។

បន្ទាប់មក ត្រូវចែកក្រដាសផ្ទាំងធំដោយសរសេរគោលការណ៍សិក្សាបែបស្ថាបនានិយមនៅលើនោះ។ ក្រុមនីមួយៗត្រូវទទួលក្រដាសមួយ ឬពីរសន្លឹកដោយសរសេរគោលកាណ៍នៅផ្នែកខាងលើនោះ និងកន្លែងទំនេរខ្លះនៅផ្នែកខាងក្រោមសម្រាប់ជាឧទាហរណ៍។

> **ការសិក្សាបែបអន្តរកម្ម** – តាមធម្មជាតិ មនុស្សរៀន និងធ្វើការដោយមានការសហការគ្នាក្នុងជីវិតរស់នៅរបស់គេ។ អន្តរកម្ម ផ្តល់វិធីដើម្បីលើកទឹកចិត្ត និងជំរុញដល់អ្នកសិក្សា។
>
> *ផ្តល់ឧទាហរណ៍ខ្លះពីគោលការណ៍នេះនៅកន្លែងការងារ៖*
>
> - ???
> - ???
> - ???

ឱ្យអ្នកចូលរួមសរសេរឧទាហរណ៍ពីរ ឬបីបង្ហាញពីគោលការណ៍នីមួយៗនៅខាងក្រោមនៃសន្លឹកនីមួយៗ។ ផ្តល់ឱ្យពួកគេរយៈពេល ៥ ទៅ ១០នាទី សម្រាប់សកម្មភាពនេះ ហើយពិភាក្សាជាក្រុមធំលើឧទាហរណ៍របស់ក្រុមនីមួយៗ។

បន្ទាប់មក ចែក**ឯកសារទី២ខ៖** គោលការណ៍គន្លឹះការសិក្សាបែបស្ថាបនានិយម និងប្រៀបធៀបឧទាហរណ៍បានផ្តល់ឱ្យក្នុងឯកសារជាមួយនឹងអ្វីក្រុមនីមួយៗបានបង្កើត។ ព្យាយាមសម្រួលឱ្យស៊ីគ្នាចំពោះគំនិតដែលខុសគ្នា។

***លំហាត់ជម្រើស៖*** ប្រសិនបើអ្នកចូលរួមយល់គំនិត និងគោលការណ៍បានបង្ហាញនេះ ពួកគេអាចបង្កើតដ្យាក្រាមបង្ហាញពីទំនាក់ទំនងរវាងធាតុសំខាន់ៗនៃការសិក្សាបែបស្ថាបនានិយម។ លំហាត់នេះត្រូវបានពន្យល់ក្នុង **ឯកសារទី២ខ**។ ត្រូវចែកក្រដាសផ្ទាំងធំដល់ក្រុមនីមួយៗ សម្រាប់គូសដ្យាក្រាម។ ប្រសិនបើអ្នកចូលរួមអាចធ្វើលំហាត់នេះបាន ផ្តល់ពេល ៣០ នាទី ឱ្យពួកគេបង្កើតដ្យាក្រាមដែលពន្យល់ពីធាតុសំខាន់ៗនៃការសិក្សាបែបស្ថាបនានិយមនោះ។ ឱ្យក្រុមនីមួយៗបង្ហាញពីដ្យាក្រាមរបស់ពួកគេ និងហេតុផលនៃចម្លើយផង។



## ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាព

ចែក**ឯកសារទី៣៖** "ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាព?"។ បន្ទាប់មក អ្នកសម្របសម្រួលត្រូវពន្យល់ហេតុអ្វីបានជាការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាពបំផុតសម្រាប់ដំណើរការរៀនសូត្រ ដោយផ្តោតលើសកម្មភាពដែលសកម្មជាងអកម្ម? បង្ហាញកម្រិតនៃការ "ចងចាំ" កើនឡើងចេញពីសកម្មភាពបែបអកម្មមកសកម្ម។ នេះអាចឃើញយ៉ាងច្បាស់នៅក្នុងរូបភាពដែលបានផ្តល់ឱ្យ។

អ្នកសម្របសម្រួលត្រូវពន្យល់បន្ថែមថា សកម្មភាពអកម្មដូចជាការអានក៏មានក្នុងដំណើរការសិក្សាដែរ តែដំណើរការសិក្សាទាំងនេះគួរបន្ថែមសកម្មភាពបែបសកម្មផ្សេងៗទៀតដែលជាឧទាហរណ៍នៃការអនុវត្តគោលវិធីបែបស្ថាបនានិយម ដែលផ្តល់ ឱកាសឱ្យសិស្សមានគំនិតច្នៃប្រឌិតបង្កើតបញ្ញត្តិថ្មី ។

នៅក្នុងក្រុម សុំឱ្យអ្នកចូលរួម កំណត់សកម្មភាពផ្សេងៗដែលបង្ហាញពី "ភាពសកម្ម" និងឧទាហរណ៍មកបង្ហាញគោលការណ៍ការសិក្សាបែបស្ថាបនានិយមផង។ អ្នកចូលរួមត្រូវយល់ឱ្យច្បាស់ពីសកម្មភាពនីមួយៗ។ ផ្តល់ពេលប្រហែលជា ១៥នាទីសម្រាប់ធ្វើ លំហាត់ ហើយពិភាក្សាពីសកម្មភាពនីមួយៗដែលអ្នកចូលរួមបានកំណត់។



# មេរៀនទី៣.២ - ការអនុវត្តការសិក្សាបែបស្ថាបនានិយមនៅក្នុងថ្នាក់រៀន

**រយៈពេលបង្រៀន៖** ៣ម៉ោង និង ៣០នាទី

**ការត្រៀមលក្ខណៈ**

- សរសេរវត្ថុបំណងមេរៀននៅលើក្រដាសផ្ទាំងធំដើម្បីណែនាំមេរៀន។
- ថតចម្លង **ឯកសារទី៤៖** *ការផ្សារភ្ជាប់ការសិក្សាបែបស្ថាបនានិយម និងទ្រឹស្តីប្លូមតាក់សូណូមី (Bloom's Taxonomy)*
- ថតចម្លង **ឯកសារទី៥ក៖** *ការបង្កើតបញ្ញត្តិ និងការសិក្សាបែបស្ថាបនានិយម*
- ថតចម្លង **ឯកសារទី៥ខ៖** *ការបង្កើតបញ្ញត្តិផ្ទុយគ្នាពីរ*
- ថតចម្លង **ឯកសារទី៦៖** *វិធីសាស្ត្របង្រៀនមួយចំនួន ដែលគាំទ្រគោលវិធីបង្រៀនបែបស្ថាបនានិយម*
- ថតចម្លង **ឯកសារទី៧៖** *វិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហាដើម្បីជំរុញការសិក្សាបែបស្ថាបនានិយម*

**សម្ភារឧបទ្ទេស/ធនធានដែលត្រូវការ**

- ក្រដាសផ្ទាំងធំ ហ្វឺត
- ក្រដាសផ្ទាំងធំដែលសង្ខេបវត្ថុបំណងមេរៀន។
- ថតចម្លង **ឯកសារទី៤៖** *ការផ្សារភ្ជាប់ការសិក្សាបែបស្ថាបនានិយម និងទ្រឹស្តីប្លូមតាក់សូណូមី (Bloom's Taxonomy)*
- ថតចម្លង **ឯកសារទី៥ក៖** *ការបង្កើតបញ្ញត្តិ និងការសិក្សាបែបស្ថាបនានិយម*
- ថតចម្លង **ឯកសារទី៥ខ៖** *ការបង្កើតបញ្ញត្តិផ្ទុយគ្នាពីរ*
- ថតចម្លង **ឯកសារទី៦៖** *វិធីសាស្ត្របង្រៀនមួយចំនួន ដែលគាំទ្រគោលវិធីបង្រៀនបែបស្ថាបនានិយម*
- ថតចម្លង **ឯកសារទី៧៖** *វិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហាដើម្បីជំរុញការសិក្សាបែបស្ថាបនានិយម*
- សៀវភៅសិក្សាគោលសាលាមធ្យមសិក្សាគ្រប់មុខវិទ្យា (ដូចជា៖ គីមីវិទ្យា រូប

វិទ្យា ជីវវិទ្យា គណិតវិទ្យា ភាសាខ្មែរ និងសិក្សាសង្គម)

- ក្រដាសស្ទីកគ័រពណ៌ដែលមិនទាន់សរសេរ សម្រាប់ប្រើប្រាស់ជាបណ្ណការពិត (Fact card) និងបណ្ណលទ្ធផល (Consequence card) ដែលត្រូវបំពេញដោយសិក្ខាកាមតាមក្រុមពេលពិនិត្យមើលសៀវភៅសិក្សាគោល។
- រូបភាពអ៊ុតផ្លាស្ទិចរឹង ៣ ឬ៤សន្លឹកបង្ហាញពីសកម្មភាពនៅប្រទេសចិននាសម័យបុរាណដែលមានបង្ហាញនៅក្នុង **ឯកសារយោងទី៧**។
- ក្រដាសផ្ទាំងធំដោយមានគោលការណ៍គន្លឹះសំខាន់ៗ សរសេរលើនោះ

## លទ្ធផលសិក្សា៖

- អ្នកចូលរួមអាច**ពន្យល់**បានពីទំនាក់ទំនងរវាងការសិក្សាបែបស្ថាបនានិយម និង Bloom's Taxonomy ចំពោះកម្រិតនៃការគិត ហើយអាចបង្កើតសំណួរផ្សេងៗត្រឹមត្រូវតាមកម្រិតនីមួយៗ ។
- អ្នកចូលរួមអាច**ពន្យល់**ពីជំហានសំខាន់ៗ ក្នុងការបង្កើតគំនិត និងអាច**បំពេញ**លំហាត់ដោយប្រើប្រាស់ជំហានទាំងនេះ។
- អ្នកចូលរួមអាច**បង្ហាញពីភាពខុសគ្នា**រវាងបច្ចេកទេសផ្សេងៗដែលប្រើប្រាស់សម្រាប់ការបង្កើតគំនិតរួមមាន"ផែនទីគំនិត" និង "ផែនទីបញ្ញត្តិ"។
- អ្នកចូលរួមអាច**ឆ្លើយ**សំណួរពាក់ព័ន្ធនឹងការវិភាគពីលំហាត់បង្កើតបញ្ញត្តិដែលអនុវត្តដោយសិស្ស។
- អ្នកចូលរួមអាច**បំពេញ**លំហាត់បាន ដោយពួកគេត្រូវប្រើប្រាស់បច្ចេកទេសបង្រៀនមួយចំនួន ដើម្បីជំរុញការសិក្សាបែបស្ថាបនានិយម ជាមួយមេរៀនជាក់ស្តែងណាមួយក្នុងការបង្កើតលំហាត់ដោយអនុវត្តតាមទម្រង់ និងគោលការណ៍ដូចគ្នានេះដែរ ។
- អ្នកចូលរួមអាច**ពន្យល់**ថា លំហាត់ពួកគេធ្វើតាមវិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហា គឺជាឧទាហរណ៍ជាក់ស្តែងមួយពីការអនុវត្តគោលវិធីបង្រៀនបែបស្ថាបនានិយមនៅក្នុងការបំប៉ននេះ ។

## ផែនការមេរៀន

### លទ្ធផលសិក្សា

បិទផ្ទាំងក្រដាសលើក្តារខៀនសង្ខេបអំពីលទ្ធផលសិក្សា។ ពន្យល់អំពីលទ្ធផល និងពីអ្វីដែលសិក្ខាកាមអាចនឹងធ្វើបាននៅចុងបញ្ចប់នៃមេរៀន។

### ការផ្សាភ្ជាប់ការសិក្សាបែបស្ថាបនានិយម និង Bloom's Taxonomy

អ្នកសម្របសម្រួលគួរចាប់ផ្តើមការពិភាក្សានេះ ដោយរំលេចពីគោលការណ៍គន្លឹះដែលសិក្សារួចមកហើយ អំពីការសិក្សាតាមបែបស្ថាបនានិយមផ្តោតខ្លាំងទៅលើបំណិនការគិតកម្រិតខ្ពស់ ។ ប្រសិនបើយើងភ្ជាប់គោលការណ៍នេះទៅនឹង Bloom's Taxonomy យើងនឹងសន្និដ្ឋានបានថាការសិក្សាតាមបែបស្ថាបនានិយមភាគច្រើនត្រូវការបំណិនការគិតកម្រិតខ្ពស់ទាំង ៣ រួមមាន**ការវិភាគ វាយតម្លៃ** និង**បង្កើតថ្មី**។ ប៉ុន្តែមុននឹងផ្តល់ចម្លើយនេះ សួរសិក្ខាកាមទាំងអស់ថាតើកម្រិតការគិតខ្ពស់បំផុតទាំង ៣ នៃ Bloom's Taxonomy គឺមានអ្វីខ្លះ ?

បន្ទាប់មកចែក **ឯកសារទី៤៖** *ការផ្សាភ្ជាប់រវាងការសិក្សាតាមបែបស្ថាបនានិយម និង Bloom's Taxonomy*។ រំឭកឡើងវិញនូវកម្រិតនៃការគិតតាម Taxonomy ក្នុងករណីអ្នកចូលរួមខ្លះមិនសូវច្បាស់អំពីវា ដោយចង្អុលបង្ហាញថា កម្រិតនៃការគិតនីមួយៗ ត្រូវការបំណិនទាំងឡាយនៅពីក្រោមវា ។ សំខាន់បំផុត កំណត់លក្ខណៈសម្គាល់ពីកម្រិតវិភាគ វាយតម្លៃ និងបង្កើតថ្មី៖

- **ការវិភាគ៖** បំបែកបញ្ញត្តិមួយជាផ្នែកតូចៗ ដើម្បីធ្វើយ៉ាងណាយល់ពីរចនាសម្ព័ន្ធរបស់វា។ បែងចែកភាពខុសគ្នារវាងការពិត (fact) និងសេចក្តីសន្និដ្ឋាន (Inference)។
- **ការវាយតម្លៃ៖** ធ្វើការវាយតម្លៃគំនិត គួអង្គ ឬហេតុការណ៍ណាមួយ ដោយបង្កើតលក្ខណៈវិនិច្ឆ័យស្តង់ដាមួយ យកមកវាស់វែង ។
- **ការបង្កើតថ្មី៖** បង្កើតរចនាសម្ព័ន្ធ ឬលំនាំថ្មីមួយពីផ្នែកតូចៗផ្សេងៗ។ ដាក់ផ្នែកតូចៗទាំងអស់ចូលគ្នា ដើម្បីបង្កើតជារចនាសម្ព័ន្ធថ្មី ដោយផ្តោតទៅលើការបង្កើតអត្ថន័យថ្មី ឬរចនាសម្ព័ន្ធថ្មីមួយ។[3]

[3] http://www.nwlink.com/~donclark/hrd/bloom.html

បន្តពន្យល់ថា Bloom's taxonomy មានប្រយោជន៍ដល់ការសិក្សាបែបស្ពាបនានិយមដោយវិធី ២ យ៉ាង។ **ទីមួយ** វាអាចជួយយើងក្នុងការកំណត់សកម្មភាពនៅក្នុងកម្រិតជាក់លាក់មួយ។ ឧទាហរណ៍មួយចំនួន មានផ្ដល់ជូនក្នុងជួរក្រោមដំបូងគេក្នុង **ឯកសារចែកទី៤** ។ **ទីពីរ** វាអាចជួយយើងក្នុងការកំណត់ប្រភេទសំណួរ ដែលតម្រូវឱ្យមានបំណិនដោះស្រាយបញ្ហាកម្រិតខ្ពស់។

រំឭកឡើងវិញនូវឧទាហរណ៍ខ្លះៗ ពីសកម្មភាព និងសំណួរនៅកម្រិតពុទ្ធិនីមួយៗដែលមានផ្ដល់ជូននៅក្នុង**ឯកសារចែកទី ៤** ហើយឆ្លើយសំណួរសិក្ខាកាមសួរ។

នៅពេលពន្យល់ចប់ សុំឱ្យសិក្ខាកាមក្នុងក្រុមបង្កើតសំណួរការសិក្សាតាមបែបស្ពាបនានិយម ដែលបង្ហាញពីគំរូកម្រិតពុទ្ធិទាំង ៣ នៅក្នុង Bloom's Taxonomy ដោយប្រើប្រាស់លំហាត់បានផ្ដល់ជូននៅខាងផ្នែកខាងក្រោមនៃឯកសារចែក។ សិក្ខាកាមអាចជ្រើសរើសសំណួរពីមុខវិជ្ជាណាមួយ ពួកគេគិតថាស្រួល។ ផ្ដល់ពេលប្រហែល ១៥ នាទីសម្រាប់លំហាត់នេះ។

នៅពេលក្រុមនីមួយៗបានបញ្ចប់កិច្ចការហើយ សុំឱ្យពួកគេសរសេរសំណួរនៅលើក្ដារខៀន ហើយពិភាក្សាសំណួរទាំងនោះជាក្រុម ដោយពិនិត្យមើលថាតើសំណួរទាំងនោះពិតជាបង្ហាញបំណិន ស្របតាមនិយមន័យបានផ្ដល់ជូនដែរឬទេ ?

**ការបង្កើតបញ្ញត្តិនៅក្នុងថ្នាក់សិក្សាតាមបែបស្ពាបនានិយម**

ចាប់ផ្ដើមមេរៀននេះ ដោយរំឭកឡើងវិញនូវចំណុចមួយចំនួនបានលើកឡើងពីខាងដើមពីនិយមន័យរួមនៃការសិក្សាបែបស្ពាបនានិយម ។ ហេតុនេះ សុំសួរសំណួរខាងក្រោម៖

*តើផ្នែកសំខាន់ៗ ក្នុងការកំណត់និយមន័យការសិក្សាបែបស្ពាបនានិយមមានអ្វីខ្លះ ?*

ចម្លើយគឺ ផ្ដល់បរិបទថ្មីមួយសិស្សអាចបង្កើតបញ្ញត្តិថ្មី ដោយប្រើទិន្នន័យមានស្រាប់ ។

ចែក**ឯកសារចែកទី ៥ក៖ ការបង្កើតបញ្ញត្តិ និងការសិក្សាបែបស្ពាបនានិយម។** បន្ទាប់មក ដឹកនាំការពិភាក្សាជាមួយសិក្ខាកាម ដោយរំឭកឡើងវិញពីគោលការណ៍សំខាន់ៗដោយប្រើប្រាស់សំណួរ និងចម្លើយខាងក្រោម៖

- តើមានប៉ុន្មានជំហានក្នុងការរៀបចំដំណើរការបង្កើតបញ្ញត្តិ ? (មាន ៤ ជំហានដូចមានរៀបរាប់នៅក្នុងឯកសារចែក)

- តើសិស្សត្រូវធ្វើអ្វីខ្លះដើម្បីដាក់បញ្ចូលគ្នានូវទិន្នន័យច្រើន? (ឧ. វិភាគទំនាក់ទំនងរបស់ទិន្នន័យ ធ្វើចំណាត់ថ្នាក់ទិន្នន័យទៅតាមប្រភេទ ។ល។)
- តើបំណិននៃការគិតស៊ីជម្រៅអ្វីខ្លះ ដែលអ្នកនឹកឃើញទាក់ទងនឹងការវិភាគទំនាក់ទំនង? (ឧ. សទិសភាព- ដោយរកមើលទំនាក់ទំនង ការចាត់ថ្នាក់ ។ ល។)
- តើកម្រិតនៃការគិតអ្វីខ្លះ នៅក្នុងប្លុមតាក់សូណូមី ដែលអ្នកនឹកឃើញទាក់ទងនឹងជំហាននៃការបង្កើតបញ្ញត្តិទាំងនេះ?

  (ឧ. ការវិភាគពីទំនាក់ទំនងជា **បំណិនវិភាគ** - ការបង្កើតលក្ខណៈវិនិច្ឆ័យស្តង់ដាដើម្បីវាយតម្លៃទិន្នន័យជា **បំណិនវាយតម្លៃ**- ការបញ្ចូលទិន្នន័យជាច្រើនដើម្បីបង្កើតបញ្ញត្តិថ្មីជា **បំណិននៃការបង្កើតថ្មី** ។ល។)
- នៅពេលសិស្សចែករំលែកសម្មតិកម្មរកឃើញ តើសកម្មភាពនេះបានឆ្លុះបញ្ចាំងអំពីគោលការណ៍អ្វីនៃការសិក្សាតាមបែបស្ថាបនានិយម?

  (ឧ. ការសិក្សាបែបសហការ)
- តើវិធីសាស្ត្របង្រៀនអ្វីផ្សេងទៀតត្រូវបានអនុវត្តនៅក្នុងដំណើរការនេះ?

  (ឧ. ការសិក្សាបែបសហការ)

នៅពេលអ្នកសម្របសម្រួលបញ្ចប់ការរំឭកពីជំហានក្នុងការបង្កើតបញ្ញត្តិ គាត់ត្រូវឆ្លងទៅពិភាក្សាពីមធ្យោបាយផ្សេងៗប្រើប្រាស់ដើម្បីបង្កើតបញ្ញត្តិ (ឧ.ផែនទីគំនិត ផែនទីបញ្ញត្តិ។ល។) ព្រមទាំងពិភាក្សាអំពីប្រយោជន៍ក្នុងការបង្កើតបញ្ញត្តិផង។

*ត្រូវចងចាំថា ការប្រើប្រាស់ដ្យាក្រាម និងរូបភាពជាឧបករណ៍ល្អបំផុតសម្រាប់សកម្មភាពនានាក្នុងការបង្កើតបញ្ញត្តិ។*

សួរសិក្ខាកាម ថាតើពួកគេធ្លាប់បានឮអំពីបច្ចេកទេសទាំងនេះពីមុនមកទេ? ធ្វើបំណកស្រាយក្នុងករណីចាំបាច់ ឧទាហរណ៍៖

- **ផែនទីគំនិត៖** ជាបច្ចេកទេសមួយប្រើក្រាហ្វិកសម្រាប់បង្កើតផែនទី និងរៀបចំបញ្ញត្តិ ដោយប្រើមែកធាងផ្កុំរូបខុសៗគ្នាទាំងពណ៌ និងទម្រង់។ ផែនទីគំនិតប្រើពាក្យគន្លឹះ ដើម្បីពង្រីកគំនិតថ្មីៗ បន្ថែមជាច្រើនទៀត។




- **ផែនទីបញ្ញត្តិ៖** ជាបច្ចេកទេសក្រាហ្វិកមួយបែបទៀត ដែលស្រដៀងគ្នាទៅនឹង

ផែនទីគំនិតដែរ ប៉ុន្តែមានរចនាសម្ព័ន្ធ និងសេចក្តីលម្អិតច្រើនជាង ហើយប្រើប្រាស់ឃ្លាប្រយោគ ឬសញ្ញាព្រួញ ដើម្បីបង្ហាញពីលំហូរ និងទិសដៅនៃគំនិត ។ល។

បន្ទាប់ពីពន្យល់ចប់ សូមសិក្ខាកាមធ្វើការជាក្រុម ដើម្បីបំពេញលំហាត់បង្កើតបញ្ញត្តិមានផ្តល់ជូននៅចុង ឯកសារចែកទី ៥ក។ ទុកពេលប្រហែល ១៥ នាទីសម្រាប់ធ្វើលំហាត់នេះហើយលើកទឹកចិត្តសិក្ខាកាមឱ្យធ្វើការផ្ទៀងផ្ទាត់ការពិតជាមួយទិន្នន័យពីប្រព័ន្ធអ៊ីនធឺណិត ដើម្បីបន្ថែមសេចក្តីលម្អិតទៅលើផែនទីគំនិតពួកគេ។

អ្នកសម្របសម្រួលត្រូវរំឭកឡើងវិញនូវផែនទីគំនិត/បញ្ញត្តិ ជាក្រុមធំមួយដើម្បីធ្វើការប្រៀបធៀបភាពខុសគ្នាអាចកើតមានរបស់ក្រុមនីមួយៗទៅលើទិន្នន័យ។ អ្នកសម្របសម្រួលគួរកត់សម្គាល់ថា ក្នុងការបង្កើតព័ត៌មាន គ្មានវិធីណាមួយត្រូវបានចាត់ទុកថាត្រឹមត្រូវ ឬខុសទាំងស្រុងនោះទេ ហើយភាពខុសគ្នាសុទ្ធតែអាចទទួលយកបាន ឱ្យតែការធ្វើចំណាត់ថ្នាក់ទាំងនេះតាមរបៀបមួយត្រឹមត្រូវ។

បន្ទាប់មកចែក **ឯកសារចែកទី ៥ខ៖ ការបង្កើតបញ្ញត្តិផ្ទុយគ្នាពីរ**

ចូរកត់សម្គាល់ថាដ្យាក្រាមបានបង្ហាញក្នុងឯកសារចែកនេះគឺជា**ផែនទីបញ្ញត្តិ**។ អ្នកសម្របសម្រួលគួរពន្យល់ថាឯកសារចែកនេះបានផ្តល់នូវឧទាហរណ៍មួយទៀតអំពីការបង្កើតបញ្ញត្តិ នៅក្នុងមុខវិជ្ជាមួយគឺ ប្រវត្តិវិទ្យា។ អានឯកសារចែកដោយកត់សម្គាល់ថាលំហាត់អំពី "ហេតុ និងផល" គឺជាដំណើរការបង្កើតបញ្ញត្តិមួយទៀតដែលមានប្រយោជន៍យ៉ាងច្រើន។

សួរទៅសិក្ខាកាមថាតើដ្យាក្រាមបានបង្ហាញគឺជាផែនទីគំនិត ឬផែនទីបញ្ញត្តិ? បើពួកគេឆ្លើយថាជាផែនទីបញ្ញត្តិ សួរពួកគេថាហេតុអ្វីបានជាពួកគេគិតដូច្នេះ? ចម្លើយដែលអាចឆ្លើយ គួរតែមានដូចខាងក្រោម៖

- ដ្យាក្រាមមានរចនាសម្ព័ន្ធច្រើនជាង
- ដ្យាក្រាមមានប្រើឃ្លា និងល្បះ មិនមែនប្រើតែពាក្យគន្លឹះមួយដូចក្នុងផែនទីគំនិតទេ។
- ដ្យាក្រាមបង្ហាញប្រាប់ពីទិសដៅ និងលំហូរព័ត៌មាន

រំឭកឡើងវិញនូវសំណួរ ដើម្បីធ្វើការពិភាក្សាជាក្រុមធំ ឬជាក្រុមតូច ប្រសិនបើមានពេល។ នៅក្នុងការពិភាក្សាបន្តបន្ទាប់ ត្រូវកត់សម្គាល់ចំណុចដូចខាងក្រោម៖

- ដ្យាក្រាមទាំង ២ ត្រឹមត្រូវដូចគ្នា ប៉ុន្តែក្រុមមួយបានបង្កើតផែនទីដែលមានបញ្ញត្តិច្រើនជាង
- ដ្យាក្រាមទាំង ២ សមហេតុផលដូចគ្នា ប៉ុន្តែក្រុមមួយបានបញ្ជាក់ពីមូលហេតុដោយប្រើពណ៌ផ្សេងៗពីគ្នា។

**វិធីសាស្ត្របង្រៀនផ្សេងៗ ដែលមានប្រយោជន៍ក្នុងការអនុវត្តវិធីសាស្ត្រ ការសិក្សាតាមបែបស្ថាបនានិយម៖ ការសិក្សាតាមបែបសហការ**

ចាប់ផ្ដើមមេរៀននេះ ដោយត្រឡប់ចូលទៅគំនិតបានលើកឡើងពីខាងដើមថាការសិក្សាបែបស្ថាបនានិយម គឺពិតជាទ្រឹស្ដីសិក្សាមួយប្រើប្រាស់វិធីសាស្ត្រផ្សេងៗជាច្រើន ដូចជា **ការសិក្សាបែបសហការ** និង**ការសិក្សាអាស្រ័យទៅលើបញ្ហា**។ សម្រាប់មេរៀននេះ យើងសូមលើកយកគោលការណ៍មួយចំនួនពីទ្រឹស្ដីសិក្សាទាំងនេះមកប្រើប្រាស់ដើម្បីលើកកម្ពស់ការសិក្សាតាមបែបស្ថាបនានិយម។

ចែក**ឯកសារចែកទី ៦៖** វិធីសាស្ត្របង្រៀនមានប្រយោជន៍មួយចំនួនសម្រាប់ប្រើក្នុងការសិក្សាតាមបែបស្ថាបនានិយម។

រំឭកឡើងវិញនូវ*គោលការណ៍ណែនាំទូទៅ*ក្នុងឯកសារចែក អំពីវិធីសាស្ត្របង្រៀនមួយចំនួនមានលក្ខណៈ "ការសហការ" រួមមាន៖

(ក) របៀបបង្កើតក្រុម

(ខ) កិច្ចការដែលគួរធ្វើក្នុងក្រុម

(គ) របៀបង្កើតសម្ភារៈឧបទេសជួយបញ្ជាក់ពីការយល់ដឹង និងបច្ចេកទេសផ្សេងៗទៀត។

បន្ទាប់មក អ្នកសម្របសម្រួលត្រូវពន្យល់អ្នកចូលរួមថា យើងមាន*លំហាត់ពង្រឹងពុទ្ធិ*ចំនួន៣ ដែលបង្ហាញពីគំរូគោលការណ៍សិក្សាតាមបែបសហការ និងតាមបែបស្ថាបនានិយម។ លំហាត់ទីមួយឈ្មោះថា **ការសម្រេចចិត្ត-ការសម្រេចចិត្ត** (Decisions-Decisions) លំហាត់មួយទៀតឈ្មោះថា **ជីក-ស** (Jigsaw) ហើយលំហាត់មួយទៀតឈ្មោះថា **ស្វែងរកកំហុស** (Find the Mistake)។ ពន្យល់អំពីរបៀបលេងដោយផ្អែកលើការរៀបរាប់ក្នុងឯកសារចែក។ ធ្វើការជាក្រុមធំ មើលលំហាត់គំរូដែលបានផ្ដល់ជូន

ដោយឆ្លើយសំណួរបានផ្តល់ឱ្យ ជាឧទាហរណ៍។

**ការអនុវត្តជាក់ស្តែង**

បន្ទាប់ពីពិភាក្សាលំហាត់ខាងលើរួច ចែកសៀវភៅសិក្សាគោល តាមឯកទេសមុខវិជ្ជា (គីមីវិទ្យា ជីវវិទ្យា គណិតវិទ្យា ប្រវត្តិវិទ្យា ។ល។) ហើយសុំឱ្យពួកគេជ្រើសរើសមេរៀនអាចបង្កើតលំហាត់បាន ដោយប្រើបច្ចេកទេសមួយក្នុងចំណោមបច្ចេកទេសទាំង៣ បានស្នើខាងលើ( ឧទាហរណ៍៖ សម្រេចចិត្ត-សម្រេចចិត្ត ជីក-ស ឬស្វែងរកកំហុស)។ ចំណុចនេះមានពន្យល់នៅក្នុងលំហាត់នៅចុង **ឯកសារចែកទី៦** ផងដែរ។ ត្រូវផ្តល់ឱ្យសិក្ខាកាមនូវក្រដាសបណ្ណស្ទីកគ័រពណ៌មិនទាន់សរសេរ (ប្រសិនបើពួកគេសម្រេចចិត្តប្រើវិធី **ការសម្រេចចិត្ត-ការសម្រេចចិត្ត** ឬឱ្យក្រដាសផ្ទាំងធំ បើពួកគេសម្រេចចិត្តប្រើវិធី **ជីក-ស**។ ផ្តល់ពេលប្រហែល ៤០ នាទី សម្រាប់ក្រុមនីមួយៗធ្វើលំហាត់ និង ២០ នាទីសម្រាប់ធ្វើបទបង្ហាញ។ សិក្ខាកាមអាចប្រើទម្រង់គំរូមានផ្តល់ជូនក្នុងឯកសារចែក ឬប្រើប្រាស់ទម្រង់ផ្ទាល់ខ្លួន។

ពិភាក្សា និងឱ្យយោបល់ទៅលើលំហាត់ដែលក្រុមនីមួយៗបានបង្កើត។

អ្នកសម្របសម្រួលត្រូវត្រួតពិនិត្យមើលថាតើលំហាត់ទាំងនេះឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យខាងក្រោមដែរឬទេ៖

- យកគំរូតាមលំនាំបានពន្យល់សម្រាប់សកម្មភាពនីមួយៗ
- មានសំណួរ ឬលំហាត់ នៅកម្រិតនៃការវិភាគ ការវាយតម្លៃ និងបង្កើតថ្មី
- សេចក្តីណែនាំសម្រាប់សិស្សច្បាស់លាស់
- ។ល។

**វិធីសាស្ត្របង្រៀនផ្សេងៗ ដែលមានប្រយោជន៍ក្នុងការអនុវត្តវិធីសាស្ត្រ ការសិក្សាតាមបែបស្ថាបនានិយម៖ ការសិក្សាអាស្រ័យលើបញ្ហា**

មេរៀនបន្ទាប់ទៀតនេះ ផ្តោតលើការអនុវត្តវិធីសាស្ត្រ**ការសិក្សាអាស្រ័យលើបញ្ហា** ទៅនឹងការសិក្សាបែបស្ថាបនានិយម។ អ្នកសម្របសម្រួល គួរពន្យល់ថាការសិក្សាបែបស្ថាបនានិយមអាចខ្ចីគោលការណ៍ជាច្រើនពី**ការសិក្សាអាស្រ័យលើបញ្ហា** ដែលនាំទៅរកការបង្កើតបញ្ញត្តិ និងបំណិនផ្សេងៗ។ សរសេរគោលការណ៍គន្លឹះខាងក្រោម បង្ហាញពី**ការសិក្សាអាស្រ័យលើបញ្ហា** នៅលើក្តារខៀន៖

(ក) កំណត់ពីអ្វីមួយបានដឹងរួចហើយ

(ខ) កំណត់ពីអ្វីមួយត្រូវដឹង និង

(គ) ដឹងពីរបៀប និងកន្លែង ត្រូវរកព័ត៌មានដើម្បីដោះស្រាយបញ្ហា

បន្តពន្យល់ថា ពេលយើងដោះស្រាយបញ្ហា យើងត្រូវ **វិភាគបរិបទ** និងចំណេះដឹងផ្ទាល់ខ្លួនមានស្រាប់ កំណត់ពីអ្វីខ្លួនត្រូវដឹង (**វាយតម្លៃ**) និងបង្កើតដំណោះស្រាយ (**ការបង្កើតថ្មី**) ។

បង្ហាញ ឧទាហរណ៍ ដោយចែករូបភាពចិនបុរាណដែលបានអ៊ុតផ្លាស្ទិចរួច។

ពន្យល់ថារូបភាពជីវភាពចិនបុរាណមានកំហុស(បញ្ហា)មួយចំនួនទាក់ទងនឹងប្រវត្តិសាស្ត្រ។ សិស្សត្រូវធ្វើការស្វែងរកកំហុសប្រវត្តិសាស្ត្រទាំងនេះក្នុងរូបភាព ហើយពន្យល់ថាហេតុអ្វីបានជាខុស (ដំណោះស្រាយ)។



ឱ្យសិក្ខាកាមស្វែងរកកំហុសនៅក្នុងរូបភាពប្រហែល ១៥ នាទី បន្ទាប់មកពន្យល់ថា ហេតុអ្វីបានជាខុស? ប្រើកុំព្យូទ័រយួរដៃ ឬកុំព្យូទ័របន្ទះស្តើងដើម្បីស្រាវជ្រាវតាមអ៊ីនធឺណិតស្វែងរកការវិភាគរបស់អ្នក។

ប្រើប្រាស់តារាងគំរូខាងក្រោមដើម្បីដោះស្រាយបញ្ហាដែលបានផ្តល់ជូន។

| កំហុសក្នុងរូបភាព | ការពន្យល់ |
|---|---|
| ១. **ឧទាហរណ៍៖** ចិនបុរាណមិនទាន់មានរទេះរុញសម័យទំនើបទេ | ទោះបីប្រទេសចិន បង្កើតឧបករណ៍រទេះរុញមុនគេហៅថា "គោឈើ" ដូចមានបង្ហាញនៅក្នុងរូបភាពនេះក៏ដោយ ក៏ពួកគេមិនមានឧបករណ៍គោឈើលក្ខណៈទំនើប ដូចក្នុងរូបដែរ។ គោឈើមានកង់នៅកណ្តាល ចំណែករទេះរុញសម័យទំនើបមានទីប្រជុំទម្ងន់ខិតជិតទៅខាងចុងរទេះដាង។ |

២.

៣.

៤.

៥.

៦.

៧.

នៅពេលសិក្ខាកាមបានបំពេញលំហាត់រួចហើយ សួររកចម្លើយពីគ្រប់គ្នា ដោយរំឭកឡើងវិញនូវការពន្យល់បានផ្តល់ជូនក្នុង**ឯកសារចែកទី៧។**

បន្ទាប់មក អ្នកសម្របសម្រួលគួរឱ្យសិក្ខាកាមរំឭកឡើងវិញពីសំណួរពិភាក្សាក្នុង ឯកសារចែកទី ៧ និងធ្វើព្យុះគំនិតរកចម្លើយមួយចំនួនដើម្បីឆ្លើយទៅនឹងសំណួរនីមួយៗ។ នៅពេលប្រមូលបានចម្លើយហើយ ព្យាយាមធ្វើបញ្ជីចម្លើយលើក្តារខៀនជាក្រុមធំ។ ប្រើសំណួរខាងក្រោម ដើម្បីជួយដឹកនាំការពិភាក្សា៖

*១. តើអ្នកអាចរកឃើញកំហុសបានប៉ុន្មាន?*

- មាន ៧ កំហុសនៅក្នុងរូបភាពនេះ ហើយយើងបានរកឃើញទាំងអស់។

*២. តើក្រុមរបស់អ្នកដឹងអ្វីខ្លះអំពីកំហុសក្នុងរូបភាព? (ឧទាហរណ៍៖ កាលបរិច្ឆេទដែលមហាកំផែងត្រូវបានកសាង បច្ចេកវិទ្យាមាននៅសម័យនោះ ។ល។)។*

- យើងបានដឹងហើយថា រូបភាពនេះបង្ហាញពីសកម្មភាពនៅសម័យកាលនៃការកសាងមហាកំផែងចិន
- មហាកំផែងចិន ត្រូវបានកសាងនៅប្រហែល ២០០ ឆ្នាំមុនគ្រិស្តសករាជ ដែលឆ្លងកាត់ជាច្រើនសតវត្សរ៍មកហើយ
- បច្ចេកវិទ្យាពេលនោះគឺមានតិចតួច និងទំនាក់ទំនងជាមួយអឺរ៉ុបគឺលំបាក

*៣. តើអ្នកបានកំណត់អ្វីដែលអ្នកត្រូវដឹង ដើម្បីដោះស្រាយបញ្ហាដោយរបៀបណា? (ឧទាហរណ៍៖ តើវត្ថុអ្វីខ្លះអ្នកដឹងមិនប្រាកដក្នុងរូបភាពអ្នកសង្កេត?)*

- យើងត្រូវដឹងថាពេលណារទេះរុញសម័យទំនើបត្រូវបានបង្កើតឡើង

| | |
|---|---|
| | - យើងត្រូវដឹងថាពេលណាប៉មទូអេវហ្វែល ( Eiffel Tower ) ត្រូវបានកសាង<br>- យើងត្រូវដឹងថាលុយចិនបុរាណមានសណ្ឋានដូចម្ដេច ?<br>- យើងត្រូវដឹងថាពេលណាផ្លូវដែកត្រូវបានចាប់ផ្ដើមប្រើប្រាស់<br>- យើងត្រូវដឹងថាពេលណាប្រទេសអង់គ្លេសក្លាយជាប្រទេសមួយយកនិមិត្តសញ្ញាព្រះយេស៊ូ ដាក់នៅលើទង់ជាតិ<br>- ។ល។<br>*៤. តើអ្នកអាចកំណត់អ្វីដែលអ្នកមិនទាន់បានដឹង ដើម្បីដោះស្រាយបញ្ហាយ៉ាងងាយតាមវិធីណា ?*<br>- ស្វែងរកតាម Google ក្នុងប្រព័ន្ធអ៊ីនធឺណែត |

# មេរៀន ៣.៣៖ ការបង្កើតបរិបទស្ថាប័នដើម្បីលើកកម្ពស់ការសិក្សាបែបស្ថាបនានិយម

**រយៈពេលបង្រៀន៖ ៩០នាទី**

**ការត្រៀមលក្ខណៈទុកមុន៖**

- សរសេរលទ្ធផលសិក្សានៅលើក្រដាសផ្ទាំងធំដើម្បីបង្ហាញមេរៀន
- ថតចម្លង**ឯកសារចែកទី ៨៖** *ដំណើរការ និងផលិតផលនៃការសិក្សាតាមបែបស្ថាបនានិយម*
- ថតចម្លង**ឯកសារចែកទី ៩៖** *ការសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា*

**សម្ភារឧបទ្ទេស/ធនធានត្រូវការ៖**

- ក្រដាសផ្ទាំងធំ ហ្វឺត
- ផ្ទាំងក្រដាសសង្ខេបអំពីលទ្ធផលសិក្សា
- **ឯកសារចែកទី ៨៖** *ដំណើរការ និងផលិតផលនៃការសិក្សាបែបស្ថាបនានិយម*
- **ឯកសារចែកទី៩៖** *ការសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា*

**លទ្ធផលសិក្សា**

- សិក្ខាកាមអាច**កំណត់**បច្ចេកទេសបង្រៀនជាក់លាក់ (ឧ. ការងារក្រុម ការងារពិសោធន៍ ទស្សនកិច្ចសិក្សា ។ ល។) ដែលបង្ហាញជាគំរូអំពីការសិក្សាតាមបែបស្ថាបនានិយម។
- សិក្ខាកាមអាច**កំណត់**ថាតើសកម្មភាពសិក្សាតាមបែបស្ថាបនានិយម ទាំងនេះជាដំណើរការ ឬជាផលិតផល?
- សិក្ខាកាមអាច**កំណត់**ពីបច្ចេកទេសបង្រៀនជាក់លាក់ ដែលជាគំរូពីគោលការណ៍គន្លឹះនៃការសិក្សាតាមបែបស្ថាបនានិយម ។
- សិក្ខាកាមអាច**កំណត់**លក្ខខណ្ឌចាំបាច់របស់ស្ថាប័ន ដើម្បីអនុវត្តបច្ចេកទេសបង្រៀនដែលជំរុញការសិក្សាតាមបែបស្ថាបនានិយម។

# ផែនការបង្រៀន

## លទ្ធផលសិក្សា

បិតផ្ទាំងក្រដាសលើក្ដារខៀនដែលសង្ខេបពីលទ្ធផលសិក្សា។ ពន្យល់ពីលទ្ធផល និងប្រាប់ថានេះគឺជាអ្វីដែលសិក្ខាកាមគួរតែចេះនៅពេលបញ្ចប់មេរៀន។

## ដំណើរការ និងផលិតផល នៃការសិក្សាតាមបែបស្ថាបនានិយម

អ្នកសម្របសម្រួលគួរចាប់ផ្ដើមមេរៀននេះដោយពន្យល់ថាការសិក្សាបែបស្ថាបនានិយមលើកកម្ពស់ការបង្កើត ដំណើរការសិក្សា និងផលិតផលសិក្សា។ លទ្ធផលដែលកើតចេញមានច្រើនទម្រង់។

ព្យាយាមបំផុសគំនិតសិក្ខាកាម ដោយសរសេរបញ្ជីនៅលើក្ដារខៀន។ រំឭកសិក្ខាកាមថាសកម្មភាពទាំងនេះ គួរតែបង្ហាញពីបំណិនការគិតកម្រិតខ្ពស់ ។ ផ្ដល់នូវឧទាហរណ៍មួយចំនួន ដូចជាការធ្វើបទបង្ហាញ ការតាំងពិព័រណ៍ ។ល។ ដើម្បីឱ្យសិក្ខាកាមយល់គំនិតមួយចំនួនអំពីប្រភេទសកម្មភាពពួកគេគួរតែបំផុស។

បន្ទាបមក ចែក**ឯកសារចែក ទី៨៖** ដំណើរការ និងផលិតផលនៃការសិក្សាបែបស្ថាបនានិយម។ ធ្វើការប្រៀបធៀបបញ្ជីលើក្ដារខៀនជាមួយនឹងបញ្ជីនៅក្នុងឯកសារចែក។ ពិភាក្សាថាតើមានសកម្មភាពណាមួយដែលមិនពាក់ព័ន្ធ? សកម្មភាពគួរបន្ថែម ។ល។ រំឭកឡើងវិញថាសកម្មភាពទាំងនោះ មាននៅក្នុងឯកសារចែក ជាពិសេសសកម្មភាពមិនបានបង្ហាញនៅក្នុងបញ្ជីបំផុសគំនិត។

បន្ទាប់ពីពិភាក្សារួច សូមសិក្ខាកាមជ្រើសយកសកម្មភាពមួយចេញពីបញ្ជី ហើយធ្វើលំហាត់មាននៅក្នុង **ឯកសារចែកទី ៨**។ ក្រុមនីមួយៗត្រូវជ្រើសយកសកម្មភាព "មួយ" ប៉ុណ្ណោះ។ ផ្ដល់ឱ្យក្រុមប្រហែល ១០ ទៅ ១២ នាទីសម្រាប់សកម្មភាពនេះ។ នៅពេលពួកគេធ្វើសកម្មភាពរួច ដឹកនាំការពិភាក្សាអំពីចម្លើយ។ ឧទាហរណ៍មួយចំនួនត្រូវបានផ្ដល់ជូនសម្រាប់អ្នកសម្របសម្រួលដើម្បីជួយដឹកនាំការពិភាក្សា និងពិនិត្យចម្លើយ។

| សកម្មភាពសិក្សាបែបស្ថាបនានិយម | ផលិតផល ឬ ដំណើរការ | របៀបដែលវាទាក់ទងនឹងគោលការណ៍ការសិក្សាបែបស្ថាបនានិយម |
|---|---|---|
| គម្រោងវិទ្យាសាស្ត្រ (ឧទាហរណ៍) | ដំណើរការ (លុះត្រាតែមានលទ្ធផលជាក់ស្តែង ដូចជាកូនសៀវភៅ គំរូគម្រោង។ល។ ) | មានអន្តរកម្ម ពីព្រោះសិស្សធ្វើការងារជាក្រុម<br>ការសិក្សាបែបសម្របសម្រួល ពីព្រោះសិស្សអាចរៀននៅក្នុងបរិបទមិនមានរចនាសម្ព័ន្ធអាចឱ្យពួកគេសួរសំណួរក្នុងក្រុម និងជាមួយគ្រូបានដោយសេរី<br>មានភាពជាក់ស្តែង ប្រសិនបើដោះស្រាយបញ្ហាជីវិតជាក់ស្តែង ដូចជាការបំពុលទឹក គ្រោះថ្នាក់នៃការលាយកូកាកូឡាជាមួយម៉ង់តូស បញ្ហាតមអាហារ ។ល។<br>សិស្សមជ្ឈមណ្ឌល ពីព្រោះវាអាចឱ្យសិស្សកំណត់ព្រំដែននៃអ្វីពួកគេធ្វើសម្រាប់គម្រោង និងរបៀបពួកគេធ្វើ<br>ពាក់ព័ន្ធការគិតកម្រិតខ្ពស់ ពីព្រោះសិស្សត្រូវវិភាគបញ្ហា ឬ ប្រធានបទវិទ្យាសាស្ត្រណាមួយ និងធ្វើសេចក្តីសន្និដ្ឋាន (វាយតម្លៃ) |
| គម្រោងធ្វើជាក្រុម | ដំណើរការ និង ផលិតផល | |
| ការតាំងពិព័រណ៌ | ផលិតផល | |
| បទបង្ហាញ | ដំណើរការ | |
| សៀវភៅរបាយការណ៍ និងសៀវភៅកំណាព្យ | ផលិតផល | |
| ការស្រាវជ្រាវតាមអ៊ីនធឺណែត | ដំណើរការ | |
| ទស្សនកិច្ចសិក្សា | ដំណើរការ | |
| ការងារពិសោធន៍វិទ្យាសាស្ត្រ | ដំណើរការ<br>ផលិតផល | |

បន្ទាប់មក អ្នកសម្របសម្រួលពន្យល់ថា ការរៀបចំសកម្មភាពសិក្សាបែបស្ថាបនានិយម នៅក្នុងសាលារៀន និងថ្នាក់រៀន អាចជាបញ្ហាប្រឈមមួយ ប្រសិនបើមិនមាន

ការរៀបចំបរិស្ថានសិក្សាអំណោយផលសម្រាប់ការអនុវត្តគោលវិធីនេះដោយប្រសិទ្ធភាពនោះទេ។ ឧទាហរណ៍ ចូរពិចារណាសំណួរមួយចំនួនដូចខាងក្រោម៖

- តើសាលារៀនមានក្លឹបមុខវិជ្ជាដែលជាសកម្មភាពសិក្សាក្រៅថ្នាក់ដូចជាមុខវិជ្ជាវិទ្យាសាស្ត្រ ប្រវត្តិវិទ្យា និងគម្រោងដទៃទៀតដែរឬទេ?
- តើក្លឹបមុខវិជ្ជាមានថវិកាឬទេ?
- តើសាលារៀនមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ដែលការងារពិសោធន៍អាចត្រូវបានអនុវត្តដែរឬទេ? តើបន្ទប់ពិសោធន៍មានសម្ភារៈដែរឬទេ?
- តើថ្នាក់រៀន មានក្តារខៀន ឬទូសម្រាប់តាំងពិព័រណ៍ដែរ ឬទេ?
- តើសាលារៀនមានការរៀបចំទស្សនកិច្ចសិក្សា ហើយមាតាបិតាសិស្សត្រូវចុះហត្ថលេខាលើទម្រង់អនុញ្ញាតឱ្យបុត្រធីតាបានចូលរួមដែរ ឬទេ?

គូសតារាងនៅចុង**ឯកសារចែកទី ៨** (ទំព័រ ២) នៅលើក្តារខៀន ហើយបំពេញតារាងជាក្រុមធំ ដោយកំណត់តម្រូវការស្ថាប័ន ឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីសម្រួលការអនុវត្តសកម្មភាពនីមួយៗប្រកបដោយជោគជ័យ។

| សកម្មភាពសិក្សាបែបស្ថាបនានិយម | តម្រូវការស្ថាប័ន |
|---|---|
| គម្រោងវិទ្យាសាស្ត្រ | ការរៀបចំគ្រូវិទ្យាសាស្ត្រម្នាក់ស្ម័គ្រចិត្តប្រឹក្សាដល់ក្លឹបវិទ្យាសាស្ត្រ<br>ថវិកាសម្រាប់ទិញសម្ភារៈ<br>ពេលវេលាគ្រប់គ្រាន់ សកម្មភាពក្រៅថ្នាក់ ឬម៉ោងបន្ថែម<br>សៀវភៅបំប៉នក្លឹបមុខវិជ្ជា |
| គម្រោងធ្វើជាក្រុម | ការរៀបចំកន្លែងអង្គុយសមរម្យក្នុងថ្នាក់រៀនសម្រាប់ការងារក្រុម<br>សម្ភារៈសម្រាប់ស្រាវជ្រាវតាមអ៊ីនធឺណែត<br>ពេលវេលាគ្រប់គ្រាន់សម្រាប់សកម្មភាពក្រៅថ្នាក់ ឬម៉ោងបន្ថែម<br>សម្ភារៈការិយាល័យ សម្រាប់សិក្សា របាយការណ៍ ។ល។ |
| ការតាំងពិព័រណ៍ | ក្តារខៀនក្នុង និងក្រៅថ្នាក់រៀនសម្រាប់តាំងពិព័រណ៍<br>ក្តារខៀនព័ត៌មាន និងទូតាំង<br>ថវិកាសម្រាប់ទិញសម្ភារៈចាំបាច់<br>ការរៀបចំពិពរណ៌ រាត្រី ឬទិវាជួបជុំអាណាព្យាបាល<br>សម្ភារៈស្រាវជ្រាវតាមអ៊ីនធឺណែត និងបោះពុម្ព |
| បទបង្ហាញ | ការប្រើប្រាស់ម៉ាស៊ីន LCD<br>ពេលវេលា ៖ ក្នុងម៉ោងបង្រៀន ឬពេលវេលាសកម្មភាពក្រៅថ្នាក់ |

| | |
|---|---|
| | ✚ សម្ភារៈស្រាវជ្រាវតាមអ៊ីនធឺណែត (ឧ. ក្នុងបណ្ណាល័យ បន្ទប់កុំព្យូទ័រ ។ល។)<br>✚ ការប្រើសុសវែរ ដើម្បីធ្វើបទបង្ហាញដូចជាកម្មវិធី PowerPoint |
| **សៀវភៅរបាយការណ៍ និងកំណាព្យ** | ✚ សម្ភារៈស្រាវជ្រាវតាមអ៊ីនធឺណែត (ឧ. ក្នុងបណ្ណាល័យ បន្ទប់កុំព្យូទ័រ ។ល។)<br>✚ មានក្លឹបមុខវិជ្ជា ពិសេសក្លឹបអ្នកនិពន្ធ<br>✚ សម្ភារៈបោះពុម្ព និងថវិកាគាំទ្រ |
| **ការស្រាវជ្រាវតាមអ៊ីនធឺណែត** | ✚ សម្ភារៈស្រាវជ្រាវតាមអ៊ីនធឺណែត (ឧ. ក្នុងបណ្ណាល័យ បន្ទប់កុំព្យូទ័រ ។ល។)<br>✚ មានសេវាអ៊ីនធឺណែត |
| **ទស្សនកិច្ចសិក្សា** | ✚ ពិធីសារជាលាយលក្ខណ៍អក្សរសម្រាប់ការរៀបចំសិស្ស (ឧ. ចំនួនសិស្សត្រូវគ្រប់គ្រងដោយគ្រូម្នាក់ ទម្រង់ស្នើសុំការអនុញ្ញាតពីមាតាបិតាសិស្ស ។ល។)<br>✚ ថវិកាសម្រាប់ការធ្វើដំណើរ តម្លៃចូលរួម ។ល។ |
| **ការងារពិសោធន៍វិទ្យាសាស្ត្រ** | ✚ ការចូលប្រើសម្ភារៈពិសោធន៍វិទ្យាសាស្ត្រ<br>✚ ការអាចរកបាននូវសម្ភារៈពិសោធន៍<br>✚ ពេលវេលា ៖ ក្នុងម៉ោងបង្រៀន ឬពេលវេលាសកម្មភាពក្រៅថ្នាក់ |

## ការសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា

ចាប់ផ្តើមមេរៀនចុងក្រោយនេះ ដោយពន្យល់ថាបច្ចេកវិទ្យា គឺជាឧបករណ៍ល្អបំផុតជួយសម្រួលដល់ការបង្កើតផលិតផលសិក្សាដូចជា របាយការណ៍ បទបង្ហាញជា PowerPoint សៀវភៅកំណាព្យ។ល។ ការចងបណ្តាញសិក្សា និងការចែករំលែក ផ្តល់ឱកាសដល់សិស្សក្នុងការសហការគ្នា ចែករំលែកគំនិតគ្នា ។ល។

ដូចនេះ ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងសាលារៀនមួយគឺ ជាតម្រូវការស្ថាប័នសំខាន់ដែលអាចជួយសម្រួលដល់ការសិក្សាបែបស្ថាបនានិយម។

សង្ខេបគំនិតនេះដោយគូសដ្យាក្រាមខាងក្រោមនៅលើក្តារខៀន៖



**ចែកឯកសារទី ៩៖ ការសិក្សាតាមបែបស្ថាបនានិយម និងបច្ចេកវិទ្យា**

រំឭកឡើងវិញនូវវិធីមួយចំនួនដែលបច្ចេកវិទ្យាអាចលើកកម្ពស់ការបង្កើតផលិតផលសិក្សា និងការសហការ។ សរសេរវិធីទាំងនេះនៅខាងក្រោមប្រអប់ដ្យាក្រាមទាំងពីរ ដែលអ្នកបានគូសនៅលើក្ដារខៀន ដោយផ្អែកតាមអ្វីដែលវិធីទាំងនោះជំរុញខ្លាំងបំផុត។ ឧទាហរណ៍ ឧបករណ៍ទូរគមនាគមន៍បានលើកកម្ពស់ដល់ការសហការ និងការធ្វើទំនាក់ទំនង។

- *ឧបករណ៍ទូរគមនាគមន៍៖* ដូចជាអ៊ីម៉ែល និងអ៊ីនធឺណែត ផ្ដល់នូវមធ្យោបាយក្នុងការសន្ទនា ពិភាក្សា និងជជែកដេញដោលជាដើម ដែលជាអន្តរកម្មនាំទៅរកការបង្កើតអត្ថន័យសង្គម។
- *បទបង្ហាញជា PowerPoint៖* បទបង្ហាញបង្កើតឡើងដោយសិស្សនៅក្នុងក្រុមរក៏បានផ្ដល់នូវបណ្ដាញសង្គមដ៏មានប្រយោជន៍សម្រាប់សិស្សធ្វើការរួមគ្នាក្នុងការបង្កើតផលិតផលសិក្សាប្រកបដោយភាពច្នៃប្រឌិតដើម្បីចែករំលែកជាមួយសិស្សក្នុងថ្នាក់។ សាលារៀនគួរតែមានម៉ាស៊ីន LCD សម្រាប់បញ្ចាំង ហើយទាំងគ្រូ និងសិស្សអាចប្រើប្រាស់បានសម្រាប់គោលបំណងនេះ។
- *សម្ភារៈបរិក្ខារបំពាក់អ៊ីនធឺណែតនៅក្នុងបណ្ណាល័យ៖* ការបង្កើតឱ្យមានសម្ភារៈបរិក្ខារ ដែលងាយស្រួលចូលប្រើអ៊ីនធឺណែតនៅក្នុងបណ្ណាល័យគឺជាមធ្យោបាយមួយទៀត សម្រាប់សិស្សធ្វើការជាមួយគ្នាលើកិច្ចការផ្សេងៗ។ សម្រាប់សម្ភារៈបរិក្ខារទាំងនេះអាចត្រូវបានប្រើដើម្បីដោះស្រាយបញ្ហា ដែលគ្រូដាក់ឱ្យសិស្សដើម្បីបង្កើតការងារគម្រោង និងប្រភពនៃរូបភាព និងដ្យាក្រាមមានប្រយោជន៍នានា។
- *កម្មវិធីសរសេរតាមបណ្ដាញ* ផ្ដល់នូវវេទិកាសម្រាប់ការសរសេរតាមបែបសហការ។ សិស្សអាចសរសេរទៅកាន់ទស្សនិកជនជាក់ស្ដែង ដោយពួកគេអាចឆ្លើយតបភ្លាមៗទៅកាន់អ្នកចូលរួមក្នុងសកម្មភាពសរសេររួមគ្នានេះ។

ចូរបំផុសគំនិតរកយន្តការផ្សេងទៀតបង្ហាញថាបច្ចេកវិទ្យាអាចលើកកម្ពស់ការសិក្សាបែបសហការ និងបង្កើតផលិតផលសិក្សា ហើយបន្ថែមយន្តការទាំងនោះទៅក្នុងបញ្ជីអ្នកបានសរសេរនៅលើក្ដារខៀន។

# មេរៀនទី ៣.៤៖ ការវាយតម្លៃសិស្សតាមបែបស្ថាបនានិយម

រយៈពេលបង្រៀន ៖ ២ ម៉ោង

**ការត្រៀមលក្ខណៈ៖**

- សរសេរលទ្ធផលសិក្សានៃមេរៀននៅលើក្រដាសផ្ទាំងធំ
- ថតចម្លង **ឯកសារចែកទី ១០** ៖ *ការវាយតម្លៃផ្ទុយគ្នានៃការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម*
- ថតចម្លង **ឯកសារចែកទី១១** ៖ *យុទ្ធសាស្ត្រវាយតម្លៃក្នុងបរិស្ថានសិក្សាបែបស្ថាបនានិយម*
- ថតចម្លង **ឯកសារចែកទី១២** ៖ *ឧទាហរណ៍ជាក់ស្តែងនៃវិធីសាស្ត្រវាយតម្លៃដែលប្រើប្រាស់សម្រាប់វាយតម្លៃការសិក្សាបែបស្ថាបនានិយម*

**សម្ភារឧបទ្ទេស/ធនធានដែលត្រូវការ**

- ក្រដាសផ្ទាំងធំ ហ្វឺត
- ក្រដាសផ្ទាំងធំដែលសង្ខេបវត្ថុបំណងមេរៀន។
- **ឯកសារចែកទី១០៖** *ការវាយតម្លៃផ្ទុយគ្នានៃការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម*
- **ឯកសារចែកទី១១៖** *យុទ្ធសាស្ត្រវាយតម្លៃក្នុងបរិស្ថានសិក្សាបែបស្ថាបនានិយម*
- **ឯកសារចែកទី១២៖** *ឧទាហរណ៍ជាក់ស្តែងនៃវិធីសាស្ត្រវាយតម្លៃ ដែលប្រើប្រាស់សម្រាប់វាយតម្លៃការសិក្សាបែបស្ថាបនានិយម*

**លទ្ធផលសិក្សា**

- អ្នកចូលរួមអាច **ពន្យល់** មូលហេតុដែលការសិក្សាបែបស្ថាបនានិយមត្រូវការវិធីសាស្ត្រវាយតម្លៃពិសេសដើម្បីវាយតម្លៃការសិក្សារបស់សិស្ស
- អ្នកចូលរួមអាច **កំណត់** បានពីវិធីសាស្ត្រសំខាន់ៗសម្រាប់ធ្វើការវាយតម្លៃ
- អ្នកចូលរួមអាច **ពណ៌នា** ពីលក្ខណៈពិសេសនៃវិធីសាស្ត្រវាយតម្លៃនីមួយៗ
- អ្នកចូលរួមអាច **ប្រៀបធៀប** ភាពដូចគ្នា និងខុសគ្នារវាងលក្ខណៈពិសេសនៃវិធីសាស្ត្រវាយតម្លៃទាំងនោះ ដោយប្រើប្រាស់តារាងនៅក្នុងឯកសារចែកទី១២ ។

# ផែនការបង្រៀន

## លទ្ធផលសិក្សា

បិតក្រដាសផ្ទាំងធំសង្ខេបពីលទ្ធផលសិក្សាលើក្តារខៀន។ ពន្យល់ពីអ្វីដែលអ្នកចូលរួមទាំងអស់អាចធ្វើបានពេលបញ្ចប់មេរៀននេះ ។

## ដំណើរការ និងផលិតផលនៃការបសិក្សាបែបស្ថាបនានិយម

ដំបូង អ្នកសម្របសម្រួលគួរពន្យល់ថា ការប្រើវិធីសាស្ត្រវាយតម្លៃផ្សេងៗបែបបុរាណ (ឧទាហរណ៍ ៖ ការប្រឡង ការធ្វើតេស្តខ្លីជាដើម)មិនសមស្របយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃការសិក្សាបែបស្ថាបនានិយមទេ ព្រោះគ្រូត្រូវយល់ពីដំណើរការនៃការគិតខាងក្នុងរបស់សិស្សដើម្បីបង្កើតផលិតផលសិក្សាណាមួយជាមុនសិន។ ដូចនេះហើយ ការយល់ពីរបៀប ឬដំណើរការសិស្សគិតរកដំណោះស្រាយ ឬសេចក្តីសន្និដ្ឋានណាមួយ ពិតជាសំខាន់ មិនខុសពីផលិតផលសិក្សា ឬដំណោះស្រាយទាំងនោះទេ។

បន្ទាប់ពីការពន្យល់ហើយ **ចែកឯកសារចែកទី ១០** ដើម្បីជួយអ្នកចូលរួមឱ្យយល់ពីភាពផ្ទុយគ្នារវាងការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម និងការអនុវត្ត។

បន្ទាប់មកទៀត ចែកក្រុមពិភាក្សា ដោយឱ្យអ្នកចូលរួមមើលរូបភាពតុក្កតាក្នុងឯកសារចែក ហើយឆ្លើយសំណួរនៅផ្នែកខាងក្រោមនៃឯកសារ។ ទុកពេលឱ្យពួកគេធ្វើការពិភាក្សាជាក្រុមប្រហែល ១៥ នាទី ។ បន្ទាប់មក ពិនិត្យមើលចម្លើយជាក្រុមធំ ដើម្បីធានាថា អ្នកចូលរួមទាំងអស់យល់ពីភាពខុសគ្នារវាងការសិក្សាបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម ហើយចំណុចខុសគ្នានេះ មានឥទ្ធិពលយ៉ាងដូចម្តេចទៅលើការវាយតម្លៃសិស្ស? ប្រើប្រាស់ចម្លើយខាងក្រោម ដើម្បីជួយការពិភាក្សាជាក្រុមធំ៖

### សំណួរពិភាក្សា

**១. តើកម្រិតនៃការគិតមានលក្ខណៈយ៉ាងដូចម្តេចនៅក្នុងការវាយតម្លៃនៅក្នុងរូបភាព ក? នៅក្នុងរូបភាព ខ? ចូរប្រើប្រាស់ទ្រឹស្តីតាក់សូណូមីប្លូមដើម្បីរៀបចំចម្លើយរបស់អ្នក។**

*ក. រូបភាព ក៖ ការចងចាំ ការយល់ដឹង ( អាចជាការអនុវត្តផងដែរ)*

*ខ. រូបភាព ខ ៖ ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការបង្កើតថ្មី*

**២. រៀបរាប់ពីគុណសម្បត្តិ និងគុណវិបត្តិនៃយុទ្ធសាស្ត្រវាយតម្លៃដែលមានទាំងក្នុងរូបភាព ក និងរូបភាព ខ។**

ក. រូបភាព ក ៖ គុណសម្បត្តិ

១. ងាយស្រួលវាយតម្លៃតាមរយៈការធ្វើតេស្តងាយៗ និងសួរសំណួរ

២. ទាមទារការវាយតម្លៃដែលសមស្របនឹងប្រព័ន្ធវាយតម្លៃបែបប្រពៃណីរបស់សាលាភាគច្រើន

ខ. រូបភាព ក៖ គុណវិបត្តិ

១. កិច្ចការមិនមានលក្ខណៈប្រកួតប្រជែងជាមួយសមត្ថភាពសិស្ស

២. ការសិក្សាកើតឡើងតែនៅកម្រិតទាបនៃប្លូម

៣. សិស្សមានឱកាសតិចតួចដើម្បីគិតស៊ីជម្រៅ ឬគិតបែបបង្កើតថ្មី

គ. រូបភាព ខ ៖ គុណសម្បត្តិ

១. កិច្ចការមានលក្ខណៈប្រកួតប្រជែងជាមួយសមត្ថភាពសិស្ស

២. សកម្មភាពសិក្សាផ្តល់ឱ្យមានបំណិនគិតកម្រិតខ្ពស់

៣. គ្រូមានការយល់ដឹងច្រើនពីរបៀបសិស្សគិត និង កិច្ចការអ្វីដែលប្រកួតប្រជែងដល់សមត្ថភាពសិស្ស

ឃ. រូបភាព ខ ៖ គុណវិបត្តិ

១. ការអនុវត្តវិធីសាស្ត្រនេះ គឺប្រើប្រាស់ពេលវេលាច្រើ

២. ត្រូវការវិធីសាស្ត្រវាយតម្លៃថ្មីៗ ដែលភាគច្រើនគ្រូមិនទាន់ដឹង

៣. មិនសមស្របជាមួយប្រព័ន្ធវាយតម្លៃបែបប្រពៃណីរបស់សាលាភាគច្រើន

**៣. ហេតុអ្វីបានជាអ្នកគិតថាគ្រូបង្រៀននៅកម្ពុជាមិនចូលចិត្តប្រើយុទ្ធសាស្ត្រវាយតម្លៃមាននៅក្នុង  រូបភាព ខ?**

ក. គ្រូភាគច្រើនផ្តោតទៅលើការប្រឡងបែបប្រពៃណី ដែលមិនសូវជំរុញសិស្សឱ្យមានការគិតបែបស៊ីជម្រៅ

ខ. គ្រូភាគច្រើនមិនទាន់ដឹងពីគោលវិធីការសិក្សាបែបស្ថាបនានិយម និងពីរបៀបវាយតម្លៃតាមគោលវិធីនេះ

គ. គ្រូភាគច្រើនមានសកម្មភាពអាទិភាពនៅក្រៅសាលាច្រើន ហើយមិនមានពេលដើម្បីសិក្សាពីបច្ចេកទេសបង្រៀនដែលមានភាពល្អិតល្អន់ និងបច្ចេកទេសវាយតម្លៃ

ឃ. ផ្សេងៗទៀត

បន្ទាប់ពីការពិភាក្សាខាងលើបានបញ្ចប់ អ្នកសម្របសម្រួលត្រូវចែក **ឯកសារទី ១១** ដើម្បីរំឭកឡើងវិញពីយុទ្ធសាស្ត្រវាយតម្លៃខ្លះៗ តាមបែបស្ថាបនានិយម។ យុទ្ធសាស្ត្រទាំងនោះ រួមមាន៖

- ការវាយតម្លៃបែបឌីណាម៉ិក
- ការវាយតម្លៃបែបកម្រងស្នាដៃ
- ការវាយតម្លៃបែបដំណើរការ
- ការវាយតម្លៃបែបក្រៅផ្លូវការ

រំឭកឡើងវិញពីលក្ខណៈពិសេសនៃយុទ្ធសាស្ត្រវាយតម្លៃបែបថ្មីទាំងនេះ ជាមួយអ្នកចូលរួមដោយប្រើប្រាស់ឯកសារចែក។ ពេលកំពុងរំឭក អ្នកសម្របសម្រួលត្រូវប្រាកដថាអ្នកចូលរួមអាចយល់ពីចំណុចខាងក្រោម៖

- យុទ្ធសាស្ត្រទាំងនេះ ទាមទារឱ្យសិស្សមានទំនាក់ទំនង និងការចូលរួមច្រើនទាំងជាមួយក្រុម និងគ្រូ ។
- ទំនាក់ទំនងនេះ ភាគច្រើនមានទម្រង់ជាការសម្ភាស ការពិភាក្សាក្រៅផ្លូវការ និងការអង្កេតពីអាកប្បកិរិយារបស់ពួកគេម្នាក់ៗជាមួយសិស្សដទៃទៀត ។
- ការសិក្សាផ្តោតខ្លាំងទៅលើសកម្មភាពរៀន ផលិតផលសិក្សាជាក់ស្តែង និងដំណោះស្រាយ ពេលធ្វើការងារគ្រូដាក់ឱ្យ ។
- ជារឿយៗ វាអាចមានភាពជាន់គ្នាច្រើនរវាងលក្ខណៈនៃយុទ្ធសាស្ត្រនីមួយៗ
- យុទ្ធសាស្ត្រទាំងនេះ អាចបំពេញបន្ថែមលើការវាយតម្លៃបែបផ្លូវការ ដោយវាផ្តល់ព័ត៌មានពីការសិក្សារបស់សិស្ស។

បន្ទាប់មកទៀត អ្នកសម្របសម្រួលអាចពន្យល់បន្ថែមទៅលើការពិភាក្សាខាងលើ ដោយផ្តល់ឧទាហរណ៍ជាក់ស្តែងពីយុទ្ធសាស្ត្រវាយតម្លៃក្នុង **ឯកសារចែកទី ១១**។ បន្ទាប់មកចែក**ឯកសារទី ១២** ហើយពន្យល់ពីឧទាហរណ៍នៃយុទ្ធសាស្ត្រនីមួយៗ។

ក្រោយពីការពន្យល់នេះ ឱ្យអ្នកចូលរួមចូលតាមក្រុមតូច ហើយពិភាក្សាបំពេញលំហាត់នៅចុងឯកសារចែកទី ១២ ។ ទុកពេលឱ្យពួកគេ ២០ នាទីសម្រាប់លំហាត់នេះដោយឱ្យពួកគេបំពេញចម្លើយនៅលើក្រដាសផ្ទាំងធំ។

ពេលក្រុមនីមួយៗបំពេញចម្លើយអស់ហើយ ឱ្យពួកគេបិតក្រដាសនៅលើជញ្ជាំង ដើម្បីប្រៀបធៀបចម្លើយគ្នា។ ប្រើប្រាស់ចម្លើយខាងក្រោម ដើម្បីជាជំនួយឱ្យអ្នកចូលរួមអាចយល់បានពីចំណុចសំខាន់ៗពេលធ្វើការពិភាក្សាក្រុមធំ៖

| កត្តា | ការវាយតម្លៃបែបឌីណាមិក | ការវាយតម្លៃបែបកម្រងស្នាដៃ | ការវាយតម្លៃបែបដំណើរការ | ការវាយតម្លៃបែបក្រៅផ្លូវការ |
|---|---|---|---|---|
| **ពេលវេលា** (ឧ. មុន អំឡុងពេល ចុងបញ្ចប់នៃកិច្ចការ) | ធ្វើជាប្រចាំ | ចុងបញ្ចប់ | ធ្វើជាប្រចាំ | ធ្វើជាប្រចាំ |
| **ការផ្តោតលើផលិតផល** (ឧ. ខ្ពស់ ទាប ។ល។) | មធ្យម | ខ្ពស់ | ទាប | មធ្យម |
| **ការផ្តោតលើដំណើរការ** (ឧ. ខ្ពស់ ទាប ។ល។) | ខ្ពស់ | មធ្យម | ខ្ពស់ | ខ្ពស់ |
| **អន្តរកម្មគ្រូបង្រៀន** (ឧ. ខ្ពស់ ទាប ។ល។) | ខ្ពស់ | មធ្យម | ខ្ពស់ | ខ្ពស់ |
| **ប្រើបច្ចេកទេសវាយតម្លៃផ្លូវការ** (ឧ. បញ្ជីផ្ទៀងផ្ទាត់ តេស្ត ។ល។) | មធ្យម | ខ្ពស់ | មធ្យម | ទាប |

# ផែនការមេរៀន

# សម្រាប់

# អ្នកសម្របសម្រួល

## ផ្នែកទី២៖ ការគិតបែបគណនា

# មេរៀនទី ៣.៥ តើយើងកំណត់និយមន័យបែបណាសម្រាប់ការគិតបែបគណនា?

**រយៈពេលបង្រៀន ៖** ៣ ម៉ោង

**ការត្រៀមលក្ខណៈទុកមុន៖**

- សរសេរលទ្ធផលសិក្សានៃមេរៀននៅលើក្រដាសផ្ទាំងធំ
- ថតចម្លង **ឯកសារចែកទី ១៣ ៖** *ការកំណត់និយមន័យនៃ ការគិតបែបគណនា និងការយល់ដឹងពីប្រភពដើមរបស់វា*
- ថតចម្លង **ឯកសារចែកទី ១៤ក៖** *ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ*
- **ឯកសារចែកទី ១៤ខ៖** *ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ (ដំណោះស្រាយណែនាំ)*
- ថតចម្លង **ឯកសារចែកទី ១៥៖** *តើបុគ្គលគ្រប់គ្នាចូលចិត្តការគិតបែបគណនាដែរឬទេ? (ជាជម្រើស)*

**សម្ភារឧបទ្ទេស/ធនធានដែលត្រូវការ**

- ក្រដាសផ្ទាំងធំ ហ្វឺត
- ក្រដាសផ្ទាំងធំដែលសង្ខេបវត្ថុបំណងមេរៀន
- **ឯកសារចែកទី១៣៖** *ការកំណត់និយមន័យនៃ ការគិតបែបគណនា និងការយល់ដឹងពីប្រភពដើមរបស់វា*
- **ឯកសារចែកទី១៤ក៖** *ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ*
- **ឯកសារចែកទី១៤ខ៖** *ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ (ដំណោះស្រាយណែនាំ)*
- **ឯកសារចែកទី១៥៖** *តើបុគ្គលគ្រប់គ្នាចូលចិត្តការគិតបែបគណនាដែរឬទេ? (ជាជម្រើស)*

**លទ្ធផលសិក្សា**

- អ្នកចូលរួមអាច **ពន្យល់** និយមន័យនៃការគិតបែបគណនាទាក់ទងនឹងជំហានអនុវត្តចំនួន ៤៖ ការបំបែកបញ្ហា ការស្វែងរកលំនាំគំរូ ការសម្រាំងលំនាំគំរូ និងការបង្កើតក្បួនដោះស្រាយ។
- អ្នកចូលរួមអាច**ពន្យល់**ពីអត្ថន័យនៃជំហានអនុវត្តទាំង ៤ ក្នុងការគិតបែបគណនា ដោយប្រើឧទាហរណ៍ នៅពេលចាំបាច់។

- អ្នកចូលរួមអាច**ប្រើប្រាស់**ការគិតបែបគណនា ដើម្បីដោះស្រាយបញ្ហាក្នុងជីវិតប្រចាំថ្ងៃ ដោយផ្អែកលើសំណុំនៃជម្រើសមាននៅក្នុងលំហាត់ឯកសារចែក។
- អ្នកចូលរួមអាច**សង្ខេប**ការរិះគន់មួយចំនួនទៅលើការគិតបែបគណនា។ (ជាជម្រើស)
- អ្នកចូលរួមអាច**បញ្ចេញមតិ**អំពីការគិតបែបគណនាដែលបង្ហាញពីសមត្ថភាពពួកគេក្នុងការវាយតម្លៃគុណសម្បត្តិ និងគុណសម្បត្តិនៃបច្ចេកទេសដោះស្រាយបញ្ហាប្រភេទនេះ។ (ជាជម្រើស)

## ផែនការបង្រៀន

### លទ្ធផលសិក្សា

បិទក្រដាសផ្ទាំងធំនៅលើក្តារខៀនសង្ខេបពីវត្ថុបំណងឬការរំពឹងទុករបស់មេរៀន។ ពន្យល់ពីលទ្ធផលរំពឹងទុក និងអ្វីអ្នកចូលរួមអាចធ្វើបាននៅពេលបញ្ចប់មេរៀន។

### ការកំណត់និយមន័យ ការគិតបែបគណនា និងរបៀបដែលវាជាប់ទាក់ទងជាមួយទ្រឹស្តីស្ថាបនានិយម

អ្នកសម្របសម្រួលគួរណែនាំថាការគិតបែបគណនា ជាវិធីសាស្ត្រមួយក្នុងការដោះស្រាយបញ្ហា។ ដូច្នេះហើយ វាគឺជាវិធីសាស្ត្រមួយក្នុងការសិក្សាដែលមានបំណងជំរុញ 'ការគិតបែបស៊ីជម្រៅ'។ សូមរំឭកអ្នកចូលរួមថា ជំនាញនៃការគិតបែបស៊ីជម្រៅ គឺជាផ្នែកមួយដ៏សំខាន់នៃការសិក្សាផ្អែកលើបញ្ហា ដែលជាគំរូដ៏ល្អបំផុតមួយនៃទស្សនវិជ្ជាការសិក្សាបែបស្ថាបនានិយម។ ដោយជាប់ពាក់ព័ន្ធនឹងទ្រឹស្តីស្ថាបនានិយមបែបនេះ វិធីសាស្ត្រនៃការគិតបែបគណនាក្នុងការដោះស្រាយបញ្ហាក៏អាចជួយសម្រួលដល់ការសិក្សាបែបស្ថាបនានិយមផងដែរ។

បន្ទាប់មក ចែក**ឯកសារទី ១៣៖** *ការកំណត់និយមន័យនៃ ការគិតបែបគណនា និងការយល់ដឹងពីប្រភពដើមរបស់វា។* អ្នកសម្របសម្រួលគួរតែពិនិត្យមើលឡើងវិញនូវនិយមន័យដែលផ្តល់ជូននៅផ្នែកខាងលើនៃឯកសារចែក ដោយផ្តោតលើចំណុចខាងក្រោម៖

- ការគិតបែបគណនា **ជាយុទ្ធសាស្ត្រដោះស្រាយបញ្ហា។**

- ការគិតបែបគណនាត្រូវការ**ជំនាញគិតបែបត្រិះរិះពិចារណា**។
- ដោយសារតែវាផ្តោតសំខាន់លើការដោះស្រាយបញ្ហា ការគិតបែបគណនាមានទំនាក់ទំនងច្រើនទៅនឹង**វិធីសាស្ត្រផ្អែកលើបញ្ហា និងទ្រឹស្តីស្ថាបនានិយម**។
- ការគិតបែបគណនាមាន**ជំហានអនុវត្តចំនួន ៤** ដែលមានបង្ហាញក្នុងដ្យាក្រាមខាងក្រោម។

បន្ទាប់ពីពន្យល់ខាងលើ សូមពិនិត្យមើលនិយមន័យនៃ (១) ការបំបែកបញ្ហា(២) ការស្គាល់លំនាំគំរូ (៣) ការសម្រាំងលំនាំគំរូ និង (៤) ការបង្កើតក្បួនដោះស្រាយ។




ប្រើឧទាហរណ៍នៅចុងឯកសារចែកទី ១៣ ស្តីពី 'ការរៀបចំរ៉ាលី' ដើម្បីបង្ហាញពីអត្ថន័យនៃជំហានទាំង៤ ក្នុងការគិតបែបគណនា។ នេះគឺជាសំណួរមួយចំនួនដែលអ្នកសម្របសម្រួលអាចសួរទៅអ្នកចូលរួមនៅពេលពិនិត្យមើលឧទាហរណ៍បានផ្តល់ជូន៖

- *តើមានបញ្ហារងចំនួនប៉ុន្មានត្រូវបានសម្គាល់ឃើញនៅក្នុងឧទាហរណ៍នេះ ដែលជាលទ្ធផលនៃដំណើរការ 'បំបែក'?*
- *តើប្រភេទសម្ភារៈអ្វីខ្លះត្រូវបានកំណត់សម្រាប់ផ្នែកនៃដំណើរការ 'ការសម្គាល់លំនាំគំរូ'? (ឧ. ស្បែកជើង សម្លៀកបំពាក់ វត្ថុងាយបែក ដូចជាកែវជាដើម ។ល។)*
- *តើដំណើរការ 'ការសម្រាំងលំនាំគំរូ' ធ្វើឱ្យបញ្ជីនៃសម្ភារៈត្រូវបានកំណត់ក្នុងដំណើរការសម្គាល់លំនាំគំរូ មានភាពងាយស្រួលដោយរបៀបណា?*
- *តើអ្នកអាចសង្ខេបដំណើរការ ការបង្កើតក្បួនដោះស្រាយបញ្ហា ក្នុងការរៀបចំរ៉ាលីសប្រកបដោយប្រសិទ្ធភាពបានដែរឬទេ?*

## ការប្រើប្រាស់ការគិតបែបគណនា ដើម្បីដោះស្រាយបញ្ហាក្នុងជីវិតប្រចាំថ្ងៃ

រំឭកអ្នកចូលរួមថា ការគិតបែបគណនា គឺជាបច្ចេកទេសដោះស្រាយបញ្ហាដែលមិនត្រឹមតែពាក់ព័ន្ធទៅនឹងការសិក្សាមុខវិជ្ជាណាមួយប៉ុណ្ណោះទេ ប៉ុន្តែក៏ពាក់ព័ន្ធនឹងការរស់នៅប្រចាំថ្ងៃផងដែរ (ដូចជាការរៀបចំរ៉ាលី)។ ដើម្បីបង្ហាញពីគំនិតនេះ សូមចែក **ឯកសារទី ១៤ក៖** *ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ* រួមជាមួយនឹងក្រដាសផ្ទាំងធំ និងហ្វឺតទៅក្រុមតូចៗនីមួយៗ។ អានការណែនាំជាមួយគ្នា ហើយសុំឱ្យក្រុមនីមួយៗជ្រើសរើសបញ្ហាប្រចាំថ្ងៃ**មួយ** ដើម្បីដោះស្រាយដោយប្រើការគិតបែបគណនា។ អ្នកចូលរួមគួរតែប្រើតារាងនៅផ្នែកខាងក្រោមនៃឯកសារចែក ដើម្បីចងក្រងអំពីរបៀបដែលបច្ចេកទេសនៃការគិតបែបគណនាអាចត្រូវបានប្រើដើម្បីដោះស្រាយបញ្ហា។ ក្រុមនីមួយៗគួរគូរតារាងឡើងវិញនៅលើក្រដាសផ្ទាំងធំ ដើម្បីអាចចែករំលែកជាមួយក្រុមធំ។

| ការគិតបែបគណនា | អ្វីដែលខ្ញុំគិត | គំនិតចុងក្រោយ |
|---|---|---|
| ការបំបែកបញ្ហា | •<br>•<br>• | •<br>•<br>• |
| ការសម្គាល់លំនាំគំរូ | •<br>•<br>• | |
| ការសម្រាំងលំនាំគំរូ | •<br>•<br>• | •<br>•<br>•<br>• |
| ការបង្កើតក្បួនដោះស្រាយ | • | |

ផ្តល់ពេលវេលាឱ្យអ្នកចូលរួមប្រហែល ៤៥ នាទីសម្រាប់ធ្វើលំហាត់នេះ។ អ្នកចូលរួមប្រហែលយល់ថាលំហាត់នេះពិបាក។ អ្នកសម្របសម្រួលអាចប្រើ **ឯកសារចែកទី ១៤ខ៖** ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ (ដំណោះស្រាយណែនាំ) ជាមួយនឹងឧទាហរណ៍នៃដំណោះស្រាយអាចមាន ជាឧទាហរណ៍ដើម្បីជួយធ្វើការណែនាំដល់

ក្រុមនីមួយៗអំពីរបៀបពួកគេអាចដោះស្រាយបញ្ហាបាន។

នៅពេលដែលអ្នកចូលរួមបានបញ្ចប់ការវិភាគរបស់ពួកគេ សូមឱ្យក្រុមនីមួយៗបង្ហាញពីរបៀបពួកគេបំពេញតារាង។ អ្នកសម្របសម្រួលក៏អាចចែក ឯកសារទី១៤ខ ដល់អ្នកចូលរួមដើម្បីប្រៀបធៀបការវិភាគរបស់ពួកគេជាមួយនឹងដំណោះស្រាយអាចធ្វើបានផ្សេងទៀត។

នៅពេលអ្នកចូលរួមកំពុងធ្វើបទបង្ហាញការវិភាគរបស់ពួកគេទៅកាន់ក្រុមធំនោះ អ្នកសម្របសម្រួលអាចសួរសំណួរសាកល្បងដូចខាងក្រោម ដើម្បីធ្វើឱ្យប្រាកដថាអ្នកចូលរួមយល់បានពីបច្ចេកទេសនៃការគិតបែបគណនា៖

**សំណួរណែនាំសម្រាប់អ្នកសម្របសម្រួលក្នុងការពិនិត្យមើលបទបង្ហាញរបស់ក្រុម**

- តើអ្នកបានសម្រេចចិត្តដោយរបៀបណាលើបញ្ហារង ឬបញ្ហាដែលអ្នកបានលើកឡើងសម្រាប់ការបំបែក?
- តើមានលំនាំគំរូផ្សេងទៀតទេ?
- តើលំនាំគំរូទាំងអស់ដែលអ្នកបានបង្ហាញស្របនឹងបញ្ហារងបានកំណត់ថាជាផ្នែកនៃដំណើរការ បំបែកបញ្ហា ដែរឬទេ?
- តើមានវិធីណាខ្លះអ្នកអាចធ្វើឱ្យប្រសើរឡើងនូវ ការសម្រាំងលំនាំគំរូ នៃការវិភាគលំនាំគំរូខាងលើ ឬធ្វើសេចក្តីសង្ខេបឱ្យកាន់តែប្រសើរឡើង?
- តើអ្នកប្រាកដទេថា ការបង្កើតក្បួនដោះស្រាយ ដែលអ្នកបានបង្កើត អាចដោះស្រាយរាល់បញ្ហារងអ្នកបានកំណត់នៅក្នុងដំណើរការ បំបែកបញ្ហា?

## ការរិះគន់ទៅលើការគិតបែបគណនា (ជាជម្រើស)

ផ្នែកខាងក្រោមគឺជាជម្រើស ប្រសិនបើមានពេលវេលាគ្រប់គ្រាន់នៅក្នុងសិក្ខាសាលា អ្នកសម្របសម្រួលអាចចាប់ផ្តើមវគ្គដោយចែក **ឯកសារទី ១៥៖** *តើបុគ្គលគ្រប់គ្នាចូលចិត្តការគិតបែបគណនាដែរឬទេ? (ជម្រើស)* ពិនិត្យមើលការរិះគន់របស់អ្នកអប់រំមួយចំនួន ចំពោះការគិតបែបគណនា។ មានការរិះគន់ពិសេសចំនួន ៣ ដែលត្រូវបានលើកឡើងនៅក្នុងឯកសារចែក៖

- **កង្វះភាពច្បាស់លាស់អំពីរបៀបដែលវាខុសពីវិធីសាស្ត្រផ្សេងទៀត៖** អ្នកអប់រំខ្លះរិះគន់ថា ការគិតបែបគណនា ជាវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហា និងមិនមានភាពខុសគ្នាខ្លាំងពីប្រភេទនៃវិធីសាស្ត្រដោះស្រាយបញ្ហាផ្សេងទៀតនោះទេ។

- **មិនសូវសមស្របសម្រាប់មុខវិជ្ជាមិនមែនជា STEM៖** ទោះបីជាអ្នកគាំទ្រការគិតបែបគណនាបានអះអាងថាវាអាចត្រូវបានប្រើសម្រាប់ការដោះស្រាយបញ្ហាក្នុងមុខវិជ្ជាផ្សេងៗក៏ដោយ ការពិតគឺថាវាស័ក្តិសមបំផុតសម្រាប់មុខវិជ្ជា STEM និងជាពិសេសវិទ្យាសាស្ត្រកុំព្យូទ័រ។ វាពិបាកប្រើជាមួយមុខវិជ្ជាដែលមិនមែនជា STEM។
- **ការផ្ដោតតូចចង្អៀត៖** អ្នកផ្សេងទៀតរិះគន់ទៅលើ ការគិតបែបគណនា ព្រោះវាផ្ដោតចង្អៀតពេកលើ 'ការដោះស្រាយបញ្ហា' និងមិនគ្រប់គ្រាន់លើទិដ្ឋភាពផ្សេងទៀតនៃការគិតដូចជាការច្នៃប្រឌិត និងការបង្កើតចំណេះដឹង។

បន្ទាប់ពីការពិនិត្យនេះ អ្នកសម្របសម្រួលអាចសួរអ្នកចូលរួមឱ្យឆ្លើយតបនឹងសំណួរពិភាក្សាបានផ្ដល់ជូនខាងក្រោម។

## សំណួរពិភាក្សា

១. តើអ្នកយល់ស្របនឹងមតិរិះគន់ទៅលើការគិតបែបគណនាដែរឬទេ? ហេតុអ្វី?

២. តើការរិះគន់ទាំងនេះធ្វើឱ្យប៉ះពាល់ដល់សុទិដ្ឋិនិយមរបស់អ្នកដែលថាការគិតបែបគណនាអាចប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនៅក្នុងសាលារៀននៅកម្ពុជាដែរឬទេ? សូមពន្យល់ចម្លើយរបស់អ្នក។

សកម្មភាពនេះអាចធ្វើជាក្រុមធំ ឬតូច។ ប្រសិនបើអ្នកសម្របសម្រួលធ្វើសកម្មភាពនេះជាក្រុមតូច ផ្ដល់ពេលឱ្យអ្នកចូលរួមទាំងអស់ប្រហែល ១៥ ទៅ ២០ នាទីដើម្បីបង្កើតចម្លើយរបស់ពួកគេ ហើយត្រៀមខ្លួនបង្ហាញចម្លើយទៅកាន់ក្រុមធំ។

## ៣.៦ ការអនុវត្តជាក់ស្តែងនៃការគិតបែបគណនា

**រយៈពេលបង្រៀន៖** ៣ម៉ោង និង៣០នាទី

**ការត្រៀមលក្ខណៈរបស់គ្រូឧទ្ទេស៖**

- សរសេរលទ្ធផលសិក្សានៃមេរៀននេះនៅលើក្រដាសផ្ទាំងធំណែនាំមេរៀន។
- ថតចម្លង**ឯកសារទី ១៦ក៖** *ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា (លំហាត់ទី១)*
- ថតចម្លង**ឯកសារទី ១៦ខ៖** *ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា (លំហាត់ទី២)*
- **ឯកសារទី ១៧៖** *បច្ចេកទេសទូទៅមួយចំនួនដើម្បីអនុវត្តការគិតបែបគណនាទៅក្នុងមុខវិជ្ជាផ្សេងៗ*

**សម្ភារឧបទ្ទេស/ធនធានដែលត្រូវការ៖**

- ក្រដាសផ្ទាំងធំ ហ្វឺត
- ក្រដាសផ្ទាំងធំដែលសង្ខេបវត្ថុបំណងមេរៀន។
- សៀវភៅសិក្សាក្នុងមុខវិជ្ជាផ្សេងៗគ្នា
- **ឯកសារចែកទី១៦ក៖** *ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា (លំហាត់ទី១)*
- **ឯកសារចែកទី១៦ខ៖** *ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា (លំហាត់ទី២)*
- **ឯកសារចែកទី១៧៖** *បច្ចេកទេសទូទៅមួយចំនួនដើម្បីអនុវត្តការគិតបែបគណនាទៅក្នុងមុខវិជ្ជាផ្សេងៗ*

**លទ្ធផលសិក្សា៖**

- អ្នកចូលរួមអាច**ចាត់ថ្នាក់**ជំនាញគិតត្រិះរិះពិចារណាផ្សេងៗទាក់ទងនឹងជំហាអនុវត្តទាំង ៤ សម្រាប់ការគិតបែបគណនា។
- អ្នកចូលរួមអាច**ពណ៌នា**អំពីករណីសិក្សាធ្វើការសម្រេចចិត្តជាច្រើនពីពិភពធុរកិច្ច (ឧ. អាជីវកម្មស្រូវ ទេសចរណ៍ សណ្ឋាគារ ។ល។) ទាក់ទងនឹងបញ្ញត្តិនៃការគិតបែបគណនា។

- អ្នកចូលរួមអាច**ប្រើ**គោលការណ៍នៃការគិតបែបគណនា ដើម្បីរៀបចំផែនការមេរៀនពីមុខវិជ្ជាណាមួយ ដោយផ្អែកលើឧទាហរណ៍មួយចំនួនដែលពួកគេបានពិនិត្យ។

## ផែនការបង្រៀន

### លទ្ធផលសិក្សា

បិទក្រដាសផ្ទាំងធំនៅលើក្តារខៀនសង្ខេបពីវត្ថុបំណងរបស់មេរៀន។ ពន្យល់ពីលទ្ធផលរំពឹងទុក និងអ្វីដែលអ្នកចូលរួមអាចធ្វើបាននៅពេលបញ្ចប់មេរៀន។

### ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា

គោលបំណងនៃវគ្គនេះ គឺដើម្បីពង្រឹងការយល់ដឹងអ្នកចូលរួមបន្ថែមទៀតអំពីការគិតបែបគណនា។ អ្នកសម្របសម្រួលអាចណែនាំវិធីនៃការគិតអំពីការគិតបែបគណនាក្នុងន័យកាន់តែទូលំទូលាយទាក់ទងនឹងជំនាញការគិតបែបស៊ីជម្រៅជាច្រើន។ នោះគឺ នៅពេលយើងគិតពីសមាសធាតុសំខាន់ៗនៃការគិតបែបគណនា (ឧ. ការបំបែកបញ្ហាការសម្គាល់លំនាំគំរូ ។ល។)។ វាអនុវត្តជំនាញការគិតបែបស៊ីជម្រៅដែលយើងអាចប្រើដោយមិនដឹងខ្លួន។ បន្ទាប់មក អ្នកសម្របសម្រួលចែក **ឯកសារទី១៦កៈ** *ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា (លំហាត់ទី១)* ដើម្បីពិនិត្យមើលជំនាញការគិតបែបស៊ីជម្រៅមួយចំនួនបង្កប់ក្នុងការគិតបែបគណនា។ សរុបមក មានជំនាញការគិតបែបស៊ីជម្រៅចំនួន ១០ បានរាយនៅក្នុងឯកសារចែក។

បន្ទាប់ពីការពិនិត្យឡើងវិញនៃភាពខុសគ្នា សុំឱ្យអ្នកចូលរួមមើលលំហាត់បានផ្តល់នៅក្នុងឯកសារចែកដែលរាយបញ្ជីជំហានអនុវត្តទាំង ៤ ពាក់ព័ន្ធនឹងការគិតបែបគណនា។ បន្ទាប់មក ដោយពិនិត្យមើលឡើងវិញដឹកនាំដោយអ្នកសម្របសម្រួលមុននេះ សុំឱ្យអ្នកចូលរួមចំណាយពេលប្រហែល ១៥ នាទី ដើម្បីចាត់ថ្នាក់ជំនាញការគិតបែបស៊ីជម្រៅទាំង ១០ បានពិភាក្សាខាងលើ ហើយចាត់ថ្នាក់តាមប្រភេទនៃជំហានអនុវត្តទាំង ៤ នៃការគិតបែបគណនា។ រំឭកអ្នកចូលរួមថា ជំនាញមួយចំនួនអាចត្រូវបានប្រើប្រាស់ជាមួយជំហានអនុវត្តច្រើនជាងមួយ។ ឧទាហរណ៍ ជំនាញគិតទី១ តំណាងឱ្យ

ទាំងការស្គាល់លំនាំគំរូ និងការសម្រាំងលំនាំគំរូ។

***ការណែនាំ៖*** *សូមសរសេរលេខនៃជំនាញខាងលើក្នុងជួរដែលត្រូវនឹងគ្នា។ ឧទាហរណ៍មួយត្រូវបានជ្រើសម្រាប់អ្នក។*

| | |
|---|---|
| ការបំបែកបញ្ហា | (២) (៥) (៨) |
| ការសម្គាល់លំនាំគំរូ | (១) (**ឧទាហរណ៍**) (៣) (៤) (៦) |
| ការសម្រាំងលំនាំគំរូ | (១) (**ឧទាហរណ៍**) (៦) (៨) (៩) |
| ការបង្កើតក្បួនដោះស្រាយ | (៦) (៧) (៨) (១០) |

គោលបំណងនៃលំហាត់ខាងលើ គឺដើម្បីជួយឱ្យអ្នកសម្របសម្រួលដឹងបានកាន់តែច្បាស់ពីកម្រិតយល់ដឹងរបស់អ្នកចូលរួមពីជំហានអនុវត្តនៃការគិតបែបគណនា និងជំនាញគិតផ្សេងៗ។ នៅពេលអ្នកចូលរួមបញ្ចប់ការចាត់ថ្នាក់រួច សូមពិនិត្យមើលរួមគ្នាជាក្រុមធំអំពីរបៀបពួកគេបែងចែកជំនាញគិតនីមួយៗ។ ចម្លើយត្រូវបានផ្តល់ជូនសម្រាប់អ្នកសម្របសម្រួលខាងលើ ដើម្បីជួយណែនាំការពិភាក្សា។ អ្នកសម្របសម្រួលគួរតែស្តាប់ដោយយកចិត្តទុកដាក់ចំពោះក្រុមនីមួយៗ នៅពេលពួកគេរាយការណ៍អំពីលំហាត់ចាត់ចំណាត់ថ្នាក់នេះ។ ប្រសិនបើចម្លើយភាគច្រើនប្រហាក់ប្រហែលនឹងចម្លើយបានផ្តល់ខាងលើ នោះអ្នកអាចបន្តទៅលំហាត់បន្ទាប់។ ប្រសិនបើក្រុមហាក់ដូចជាមានកំហុសច្រើន អ្នកសម្របសម្រួលប្រហែលជាចាំបាច់ពិនិត្យមើលឡើងវិញនូវលក្ខណៈផ្សេងៗនៃការគិតបែបគណនាបានពិភាក្សាកន្លងមក។

## ការប្រើប្រាស់ការគិតបែបគណនាដើម្បីដោះស្រាយបញ្ហាក្នុងពិភពអាជីវកម្ម

អ្នកសម្របសម្រួលអាចចាប់ផ្តើមវគ្គនេះ ដោយកត់សម្គាល់ថាមាននិស្សិតកម្ពុជាជាច្រើនចាប់អារម្មណ៍លើអាជីវកម្ម ជាសកម្មភាពមួយបង្កើនទ្រព្យសម្បត្តិរបស់ប្រទេស។ គោលបំណងនៃវគ្គនេះ គឺដើម្បីពង្រឹងបន្ថែមទៀតនូវសមត្ថភាពអ្នកចូលរួមក្នុងការអនុវត្តការគិតបែបគណនាក្នុងបរិបទជាក់ស្តែង ដោយបង្ហាញពីរបៀបដែលជំនាញទាំងនោះមានទំនាក់ទំនងខ្លាំងក្នុងការធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព។ បន្ទាប់ពីការពន្យល់នេះ សូមចែក**ឯកសារទី ១៦ខ៖** ឧទាហរណ៍ជាក់ស្តែងពាក់ព័ន្ធនឹងជំនាញគិតបែបគណនា (លំហាត់ទី២)។ សុំឱ្យអ្នកចូលរួមពិនិត្យមើលករណីសិក្សានីមួយៗក្នុងចំណោមករណីសិក្សាទាំង ៣ បានផ្តល់ជូន ហើយក្នុងក្រុមពួកគេ ឆ្លើយសំណួរអំពី

ករណីសិក្សានីមួយៗនៅក្នុងតារាងបានផ្តល់ឱ្យ។ ផ្តល់ពេលប្រហែល ៤៥ នាទីសម្រាប់លំហាត់នេះ ហើយសុំឱ្យក្រុមនីមួយៗ ត្រៀមខ្លួនរាយការណ៍ទៅក្រុមធំអំពីការវិភាគរបស់ពួកគេសម្រាប់ករណីសិក្សានីមួយៗ។

| | **សំណួរ** | **ការវិភាគរបស់អ្នក** |
|---|---|---|
| **ករណីសិក្សាទី១** | *(១) តើអ្វីជាបញ្ហាប្រឈម?* | *តើឈ្មួញស្រូវអាចបង្កើនប្រាក់ចំណេញបានដោយរបៀបណាពេលទិញលក់ស្រូវ?* |
| | *(២) តើអ្វីទៅជាបញ្ហារង?* | *តើពេលណាជាពេលវេលាដ៏ល្អបំផុតដើម្បីទិញ?*<br>*តើពេលណាជាពេលវេលាដ៏ល្អបំផុតដើម្បីលក់?* |
| | *(៣) តើទិន្នន័យអ្វីខ្លះត្រូវបានប្រើដើម្បីស្វែងរកដំណោះស្រាយ?* | *ទិន្នន័យបង្ហាញពីពេលតម្លៃទីផ្សារស្រូវថោកបំផុត*<br>*ទិន្នន័យបង្ហាញពីពេលតម្លៃស្រូវឡើងថ្លៃជាងគេបំផុត* |
| | *(៤) តើលំនាំគំរូអ្វីខ្លះត្រូវបានគេសង្កេតឃើញ?* | *ស្រូវមានតម្លៃថោកក្នុងរដូវច្រូតកាត់*<br>*ស្រូវមានតម្លៃថ្លៃក្នុងរដូវដាំដុះ* |
| | *(៥) តើការបង្កើតក្បួនដោះស្រាយចុងក្រោយត្រូវបានកំណត់ដោយរបៀបណាក្នុងលក្ខខណ្ឌនៃជំហានអនុវត្តជាក់ស្តែង?* | • *ចាប់ផ្តើមទិញស្រូវក្នុងខែវិច្ឆិកា ដល់ខែកុម្ភៈ*<br>• *ស្តុកស្រូវខែមីនា-ឧសភា*<br>• *ចាប់ផ្តើមលក់ស្រូវខ្លាំងចាប់ពីខែមិថុនា ដល់ខែ តុលា។* |

ពេលក្រុមនីមួយៗបញ្ចប់ការវិភាគករណីសិក្សាពួកគេហើយ សុំឱ្យពួកគេរាយការណ៍ទៅកាន់ក្រុមធំ។ ពិនិត្យមើលការវិភាគរួមគ្នា និងពិភាក្សាការបកស្រាយផ្សេងទៀត។ ការបកស្រាយផ្សេងៗអាចទទួលយកបាន ដរាបណាវាសមហេតុផល។ ឧទាហរណ៍នៃការវិភាគសម្រាប់ករណីសិក្សាទី១ ត្រូវបានផ្តល់ជូនខាងលើ ដើម្បីជួយផ្តល់ឱ្យអ្នកសម្របសម្រួលនូវឧទាហរណ៍អំពីអ្វីដែលគាត់គួរតែស្វែងរកជាផ្នែកនៃការវិភាគ។

## បច្ចេកទេសប្រើជាទូទៅក្នុងការអនុវត្តការគិតបែបគណនាទៅលើមុខវិជ្ជាផ្សេងៗ

វគ្គបន្ទាប់ មានគោលបំណងជួយអ្នកចូលរួមឱ្យមើលឃើញនូវឧទាហរណ៍ជាក់ស្តែងមួយចំនួនអំពីរបៀបដែលការគិតបែបគណនាអាចប្រើជាមួយមុខវិជ្ជាមួយចំនួន( ឧ.

អក្សរសាស្ត្រខ្មែរ វិទ្យាសាស្ត្រ គណិតវិទ្យា ។ល។)។ ចែក**ឯកសារទី ១៧៖** *បច្ចេកទេសទូទៅមួយចំនួនដើម្បីអនុវត្តការគិតបែបគណនាទៅក្នុងមុខវិជ្ជាផ្សេងៗ*។ ផ្ដល់ពេលឱ្យអ្នកចូលរួមប្រហែល ៥ នាទីដើម្បីអានឧទាហរណ៍នីមួយៗដោយខ្លួនឯងជាមុនសិន។ នៅពេលអ្នកចូលរួមបានបញ្ចប់ការអានឧទាហរណ៍នេះ អ្នកសម្របសម្រួលគួរកត់សម្គាល់ថា បច្ចេកទេសប្រើសម្រាប់ការគិតបែបគណនាគឺមានភាពចម្រុះ។ ឧទាហរណ៍ខ្លះអាចត្រូវបានរៀបចំជាលំហាត់ជាក្រុមក្រៅថ្នាក់ ដើម្បីដោះស្រាយបញ្ហាគ្រូលើកឡើង (ឧ. តើនរណាជាតួអង្គសំខាន់ក្នុង ទុំទាវ?) ខណៈពេលដែលនៅក្នុងមុខវិជ្ជាផ្សេងទៀត បញ្ហាគឺត្រូវបានដាក់ជា 'គម្រោងនៃការសិក្សាអាស្រ័យលើបញ្ហា' ដែលសិស្សក៏ធ្វើក្រៅថ្នាក់ដែរ (ឧ. តើអ្វីជាវិធីល្អបំផុតក្នុងការសាងសង់ស្ពានធន់នឹងការរញ្ជួយដី?)។ ពិនិត្យឡើងវិញនូវឧទាហរណ៍នីមួយៗបានផ្ដល់ឱ្យ បង្ហាញពីរបៀបដំណើរការនៃបំបែក សម្គាល់លំនាំគំរូ ការសម្រាំងលំនាំគំរូ ការបង្កើតក្បួនដោះស្រាយ ត្រូវបានប្រើដើម្បីដោះស្រាយបញ្ហាបានបញ្ជាក់នីមួយៗ។

បន្ទាប់ពីការពិភាក្សាខាងលើ អ្នកសម្របសម្រួលគួរចែកក្រដាសផ្ទាំងធំ និងហ្វឺត ហើយសុំអ្នកចូលរួមឱ្យមើលថាតើពួកគេអាចបង្កើតឧទាហរណ៍អំពីរបៀបការគិតបែបគណនាអាចត្រូវបានប្រើដើម្បីដោះស្រាយបញ្ហាក្នុងមុខវិជ្ជាណាមួយពួកគេបង្រៀនដោយប្រើតារាងខាងក្រោមដែរឬទេ?

<table>
<tr><td colspan="4">បញ្ហា៖<br>____________________________________________?</td></tr>
<tr><th>ការបំបែកបញ្ហា</th><th>ការសម្គាល់លំនាំគំរូ</th><th>ការសម្រាំងលំនាំគំរូ</th><th>ការបង្កើតក្បួនដោះស្រាយ</th></tr>
<tr><td>•</td><td>•</td><td>•</td><td>•</td></tr>
</table>

ក្នុងលំហាត់នេះ អ្នកចូលរួមគួរតែប្រើឧទាហរណ៍ក្នុងឯកសារចែក ដើម្បីផ្ដល់ឱ្យអ្នកគ្រប់

គ្នាក្នុងក្រុមនីមួយៗ នូវគំនិតខ្លះៗអំពីរបៀបធ្វើកិច្ចការបានកំណត់។ ចែកឯកសារ ប្រសិនបើចាំបាច់ ដើម្បីជួយអ្នកចូលរួមគិតអំពីកិច្ចការនេះទាក់ទងនឹងខ្លឹមសារពួកគេបង្រៀនប្រចាំថ្ងៃ។ ដោយសារភាពស្មុគស្មាញនៃកិច្ចការនេះ អ្នកសម្របសម្រួលគួរផ្តល់ពេលប្រហែល ១ ម៉ោងសម្រាប់សកម្មភាពនេះ។

ពេលក្រុមនីមួយៗបញ្ចប់ភារកិច្ចពួកគេ អ្នកសម្របសម្រួលគួរសុំក្រុមនីមួយៗបង្ហាញឧទាហរណ៍ពួកគេដល់ក្រុមធំដើម្បីពិនិត្យ និងពិភាក្សា។ អ្នកសម្របសម្រួលគួរសួរសំណួរមួយចំនួនខាងក្រោម នៅពេលពិនិត្យមើលការងារក្រុម៖

- តើអ្នកអាចគិតឃើញវិធីផ្សេងទៀតដើម្បីបំបែកបញ្ហាអ្នកបានកំណត់បានដែរឬទេ? តើមានបញ្ហារងផ្សេងទៀតត្រូវបន្ថែមទេ?
- តើមានចំណុចទិន្នន័យផ្សេងទៀតអ្នកគិតថាអាចបន្ថែមទៅលើលំនាំគំរូរបស់អ្នកដែរឬទេ?
- តើដំណើរការសម្រាំងលំនាំគំរូអាចខ្លី និងមានភាពច្បាស់ជាងនេះទេ?តើមានលំនាំគំរូសំខាន់ៗផ្សេងទៀតអាចជាផ្នែកនៃដំណើរការស្គាល់លំនាំគំរូ ដែរឬទេ?
- តើអ្នកអាចពន្យល់ពីការបង្កើតក្បួនដោះស្រាយ អ្នកបានបង្កើតតាមរបៀបផ្សេងបានដែរឬទេ?
- ។ល។

ទាំងនេះគ្រាន់តែជាសំណួរគំរូមួយចំនួនដើម្បីសួរដែលអាច ឬមិនពាក់ព័ន្ធទៅនឹងអ្វីក្រុមណាបង្ហាញ ប៉ុន្តែអាចជួយអ្នកសម្របសម្រួលឱ្យដឹកនាំការពិភាក្សាបានស៊ីជម្រៅអំពីរបៀបអ្នកចូលរួមបានអនុវត្តការគិតបែបគណនាចំពោះមុខវិជ្ជាពួកគេបង្រៀន។

# ឯកសារចែក

## សម្រាប់

# សិក្ខាកាម

# ឯកសារចែកទី១៖ ការផ្សាភ្ជាប់រវាងការសិក្សាតាមបែបស្ថាបនានិយម និងទ្រឹស្តីសិក្សាផ្សេងៗទៀត

- ការសិក្សាបែបស្ថាបនានិយម គឺជាទ្រឹស្តីទូលំទូលាយមួយបញ្ចូលគ្នានូវបញ្ញត្តិផ្សេងៗជាច្រើន។
- គោលការណ៍ស្នូលនៃការសិក្សាបែបស្ថាបនានិយម គឺផ្តោតលើសមត្ថភាពសិស្សក្នុងការ**បង្កើតបញ្ញត្តិ** ទន្ទឹមនឹងនោះក៏មានជាតុពាក់ព័ន្ធជាច្រើនពីវិធីសាស្ត្រផ្សេងៗទៀតរួមមានការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា ការសិក្សាបែបសហការ ការប្រើប្រាស់បច្ចេកវិទ្យា និងវិធីសាស្ត្រដទៃជាច្រើនទៀត។




សំណួរសម្រាប់ការពិភាក្សា

- តើអ្នកធ្លាប់ដឹងពីទ្រឹស្តីសិក្សាទាំងនេះពីមុនមកឬទេ? ដោយផ្អែកលើអ្វីដែលអ្នកដឹងរហូតមកដល់ពេលនេះ អ្នកអាចពន្យល់បានទេថាតើវាមានទំនាក់ទំនងដូចម្តេចទៅនឹងការសិក្សាតាមបែបស្ថាបនានិយម?
- តើហេតុអ្វីបានជាអ្នកគិតថា "ការសហការ" មានសារៈសំខាន់សម្រាប់ការបង្កើតបញ្ញត្តិ និងគំនិតថ្មីៗ?
- តើអ្នកគិតថាទ្រឹស្តីប្លូមតាក់សូណូមី (Bloom's Taxonomy) មានទំនាក់ទំនងអ្វីខ្លះ ទៅនឹងការសិក្សាតាមបែបស្ថាបនានិយម?
- តើអ្នកគិតថាបច្ចេកវិទ្យាអាចលើកកម្ពស់ការសិក្សាបែបស្ថាបនានិយមបានដោយរបៀបណា?



# ឯកសារចែកទី២ក៖ និយមន័យការសិក្សាបែបស្ថាបនានិយម

## និយមន័យ

ការសិក្សាបែបស្ថាបនានិយម មានន័យថាសិស្សសហការគ្នា **ស្ថាបនា** ចំណេះដឹងពួកគេ ចេញពីបទពិសោធន៍ និងការគិតពីបទពិសោធន៍ទាំងនេះ (ការឆ្លុះបញ្ចាំង)។ គំរូការសិក្សាបែបស្ថាបនានិយម បញ្ជាក់ថាអ្នកសិក្សាគួរតែមានភាពម្ចាស់ការឱ្យបានច្រើន (ពោលគឺជាអ្នកដឹកនាំខ្លួនឯង) លើដំណើរការសិក្សា ជាង "ថ្នាក់រៀនបង្រៀនតាមបែបប្រពៃណី" ហើយសិស្សម្នាក់រៀនកាន់តែពូកែ នៅពេលពួកគេស្រាវជ្រាវអ្វីមួយដោយខ្លួនឯង។[4]




ដ្យាក្រាមខាងលើ ផ្តល់នូវអត្ថន័យច្បាស់លាស់សម្រាប់និយមន័យនៃការសិក្សាបែបស្ថាបនានិយម។ យោងតាមដ្យាក្រាមនេះ ប្រសិនបើអ្នក៖

- ចូលរួមយ៉ាងសកម្មក្នុងកិច្ចការអ្នកជ្រើសរើសធ្វើ (ដឹកនាំខ្លួនឯង)
- ឆ្លុះបញ្ចាំងពីព័ត៌មានថ្មី និងបទពិសោធន៍ពីមុន
- បន្ថែមគំនិតថ្មីផ្អែកលើការសហការគ្នាជាមួយក្រុមការងារ
- និង ... បង្កើតបញ្ញត្តិថ្មី ដោយផ្អែកលើការឆ្លុះបញ្ចាំងរបស់អ្នក

**នៅពេលនោះ គឺអ្នកកំពុងតែរៀន "តាមបែបស្ថាបនានិយម" ហើយ។**

[4] https://bc.instructure.com/courses/829527/pages/theory-constructivist-learning

# លំហាត់

**សេចក្តីណែនាំ៖ សទិសភាព** គឺជាការប្រៀបធៀបពាក្យ ២ គូ មានទំនាក់ទំនងស្រដៀងគ្នាមួយ។ សូមមើលឧទាហរណ៍ខាងក្រោម។

***ឧទាហរណ៍ទី១៖*** ឪពុក ជាគូនឹង កូនប្រុស ( គូទី១ ) ក៏ដូចជា ម្តាយ ជាគូនឹង កូនស្រី ( គូទី២ ) តើគូទាំងពីរនេះមានទំនាក់ទំនងអ្វីនឹងគ្នា? កូនមានភេទដូចឪពុកម្តាយ

***ឧទាហរណ៍ទី២៖*** ស្លាប ជាគូនឹង យន្តហោះ ក៏ដូចជា ក្តោង ជាគូនឹង ទូក

តើគូទាំងពីរនេះមានទំនាក់ទំនងអ្វីនឹងគ្នា? មធ្យោបាយជួយរុញច្រានឱ្យទៅមុខ

*តាមរយៈឧទាហរណ៍ខាងលើសូមធ្វើការជាក្រុមសាកល្បងបង្កើតសទិសភាពឱ្យបាន ៤ បន្ថែមទៀត ដែលបង្ហាញពីទំនាក់ទំនងស្រដៀងគ្នា។*

***សទិសភាព១៖*** ________ *ជាគូនឹង* ________ *ក៏ដូចជា* ________ *ជាគូនឹង* ________

***សទិសភាព២៖*** ________ *ជាគូនឹង* ________ *ក៏ដូចជា* ________ *ជាគូនឹង* ________

***សទិសភាព៣៖*** ________ *ជាគូនឹង* ________ *ក៏ដូចជា* ________ *ជាគូនឹង* ________

***សទិសភាព៤៖*** ________ *ជាគូនឹង* ________ *ក៏ដូចជា* ________ *ជាគូនឹង* ________

*នៅពេលចប់ សូមចែករំលែកសទិសភាពទាំងនោះ ជាមួយក្រុមធំ ។*

*បន្ទាប់មក រៀបរាប់របៀបដំណើរការលំហាត់នេះ ដោយឆ្លុះបញ្ចាំងពីការសិក្សាបែបស្ថាបនានិយម ដោយឆ្លើយតបតាមសំណួរខាងក្រោម៖*

*តើអ្នកបានធ្វើអ្វីខ្លះក្នុងលំហាត់នេះ ដែលឆ្លុះបញ្ចាំងពីធាតុផ្សេងៗនៃការសិក្សបែបស្ថាបនានិយម?*

១. សកម្មភាពដឹកនាំខ្លួនឯង៖

________________________________________

២. ការឆ្លុះបញ្ចាំងពីបទពិសោធន៍ពីមុន និងព័ត៌មានថ្មី៖

________________________________________

៣. ការសហការគ្នាដើម្បីបង្កើនគំនិតឱ្យបានច្រើន៖

________________________________________

៤. បង្កើតចំណេះដឹង និងបញ្ញត្តិថ្មីៗ៖

________________________________________

## ឯកសារចែកទី២ខ៖ គោលការណ៍គន្លឹះនៃការសិក្សាបែបស្ថាបនានិយម

*ទាំងនេះ គឺជាគោលការណ៍គន្លឹះមួយចំនួននៃការអនុវត្តការសិក្សាបែបស្ថាបនានិយមក្នុងថ្នាក់រៀន៖*

- **ការសិក្សាបែបអន្តរកម្ម៖** ជាធម្មតា មនុស្សរៀន និងធ្វើការដោយសហការគ្នានៅក្នុងជីវិតពួកគេ។ អន្តរអំពើ ជាវិធីមួយក្នុងការលើកទឹកចិត្ត និងជំរុញអ្នកសិក្សា។ វាបានផ្តល់នូវវិធីមួយតាមរយៈសកម្មភាព និងការពិភាក្សាសម្រាប់គ្រូ ដើម្បីជំរុញអ្នកសិក្សាឱ្យចេះពិចារណា និងឆ្លុះបញ្ចាំងលើខ្លឹមសារ និងដំណើរការសិក្សា។ អន្តរកម្មរវាងគ្រូបង្រៀន សិស្ស និងខ្លឹមសារ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសិក្សាបែបស្ថាបនានិយម។

  **ឧទាហរណ៍៖** សិស្សធ្វើការជាក្រុមក្នុងថ្នាក់រៀន ធ្វើគម្រោងជាក្រុម បណ្តាញអ៊ីនធឺណែត ក្លឹបមុខវិជ្ជា ការចុះសម្ភាសដល់មូលដ្ឋានដើម្បីប្រមូលព័ត៌មានសម្រាប់គម្រោងមួយ ។ល។

- **ការសិក្សាបែបសម្របសម្រួល៖** បង្កើតបរិយាកាសមានសុវត្ថិភាពសម្រាប់អ្នកសិក្សាដើម្បីឱ្យពួកគេបញ្ចេញគំនិតដោយសេរី ចែករំលែកគំនិត និងសួរសំណួរ។ គ្រូនៅក្នុងមជ្ឈដ្ឋានសិក្សាបែបស្ថាបនានិយម មានទំនួលខុសត្រូវ ពិនិត្យតាមដាន ធានាគុណភាពសិក្សា និងពិភាក្សាជាក្រុម។ វាចាំបាច់ណាស់សម្រាប់គ្រូបង្រៀនក្នុងការគាំទ្រ និងណែនាំឱ្យបានច្បាស់លាស់ដល់សិស្សដែលរៀនតាមបណ្តាញអ៊ីនធឺណែត។

  **ឧទាហរណ៍៖** គ្រូបង្រៀនដើរតួជា "អ្នកសម្របសម្រួលក្នុងការសិក្សា" មិនមែនជាគ្រូឧទ្ទេសទេ គ្រូបង្រៀនដើរតួជាទីប្រឹក្សាដល់ក្លឹបមុខវិជ្ជាដែលដឹកនាំដោយសិស្ស ជាដើម។

- **ការសិក្សាបែបជាក់ស្តែង៖** ការសិក្សាបែបស្ថាបនានិយម សង្កត់ធ្ងន់លើការសិក្សាណាដែលមានលក្ខណៈជាក់ស្តែង និងឆ្លើយតបទៅនឹងបទពិសោធន៍ជីវិតពិត។ បរិយាកាសសិក្សានេះ គួរតែផ្តល់នូវពិតពិត ការសិក្សាអាស្រ័យលើករណីសិក្សា ដើម្បីទទួលបាននូវចំណេះដឹងច្បាស់លាស់ និងមានអត្ថន័យ។

  **ឧទាហរណ៍៖** ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រ សារមន្ទីរ រោងចក្រ ។ល។ ការពិសោធវិទ្យាសាស្ត្រដឹកនាំដោយសិស្ស ។ល។

- **ការសិក្សាបែបសិស្សមជ្ឈមណ្ឌល៖** ជាធម្មតា សិស្សដែលចេះដឹកនាំខ្លួនឯង មានការជំរុញទឹកចិត្តខ្ពស់ ដឹងពីអ្វីពួកគេចង់រៀន ចេះកំណត់វត្ថុបំណង ស្វែងរកធនធាន និងវាយតម្លៃដំណើរការសិក្សា ដើម្បីសម្រេចគោលបំណងរបស់ខ្លួន។

  **ឧទាហរណ៍៖** សិស្សជ្រើសរើសប្រធានបទពួកគេចង់សិក្សា និងមុខវិជ្ជារៀនដូចជាគីមីវិទ្យា រូបវិទ្យា និងមុខវិជ្ជាផ្សេងទៀតតាមចំណាប់អារម្មណ៍។ សិស្សជ្រើសរើសចូលរួមក្លឹបមុខវិជ្ជា ដែលពួកគេចាប់អារម្មណ៍បំផុត។ ក្រុមសិស្សជ្រើសរើសយកប្រធានបទគម្រោងដោយខ្លួនឯង

សម្រាប់ធ្វើការស្រាវជ្រាវ ។ល។

- **ការសិក្សាដែលមានគុណភាពខ្ពស់៖** ការសិក្សាបែបស្ថាបនានិយម គួរពាក់ព័ន្ធនឹងបំណិនការគិតកម្រិតខ្ពស់ ដែលសិស្សត្រូវធ្វើការវាយតម្លៃ និងសំយោគព័ត៌មាន។ អ្នកសិក្សាត្រូវរៀនពីរបៀបគ្រប់គ្រង វិភាគ រិះគន់ ប្រៀបធៀបឯកសារយោង និងប្រែក្លាយព័ត៌មានទៅជាចំណេះដឹងថ្មី។

  **ឧទាហរណ៍៖** សិស្សបង្កើតបទបង្ហាញជា PowerPoint សិស្សនិពន្ធកំណាព្យ រឿងនិទាន និងសំណេរបែបច្នៃប្រឌិតផ្សេងទៀត។ សិស្សសរសេររបាយការណ៍ ឬធ្វើជាសៀវភៅវិភាគអត្ថន័យសាច់រឿងមួយពួកគេបានអាន ។ល។

## លំហាត់៖

**សេចក្តីណែនាំ៖** ការសិក្សាបែបស្ថាបនានិយម គឺជាការបង្កើតបញ្ញត្តិថ្មី តាមរយៈការឆ្លុះបញ្ចាំងលើ**ចំណេះដឹងថ្មី** និង**បទពិសោធន៍ពីមុន**របស់ខ្លួន។ សូមសហការជាមួយក្រុមរបស់អ្នក ដើម្បីបង្កើតដ្យាក្រាមបង្ហាញពីការយល់ដឹងរបស់អ្នកចំពោះបញ្ញត្តិសំខាន់ៗ ដែលកំណត់និយមន័យការសិក្សាបែបស្ថាបនានិយម និងទំនាក់ទំនងគ្នានៃបញ្ញត្តិទាំងនោះ។ មានដ្យាក្រាមច្រើនប្រភេទ អ្នកអាចប្រើសម្រាប់ធ្វើលំហាត់នេះ។ ឧទាហរណ៍ពីដ្យាក្រាមសម្រាប់បង្កើតបញ្ញត្តិមួយចំនួនមានផ្តល់ជូនដូចខាងក្រោម។ មិនមែនមានតែដ្យាក្រាមត្រឹមត្រូវតែមួយគត់នោះទេ ក្រុមផ្សេងគ្នាអាចបង្កើតដ្យាក្រាមផ្សេងគ្នា ដើម្បីបកស្រាយផ្សេងៗគ្នាផងដែរ។









## ឯកសារចែកទី៣៖ ហេតុអ្វីការសិក្សាបែបស្ថាបនានិយមមានប្រសិទ្ធភាព?

- ដ្យាក្រាមខាងក្រោមបង្ហាញពីកម្រិតចូលរួមក្នុងសកម្មភាពសិក្សា និងភាគរយនៃការចងចាំបន្ទាប់ពីចូលរួមកិច្ចការទាំងនោះ។
- កិច្ចការទាំងអស់នៅផ្នែកខាងក្រោមនៃពីរ៉ាមីត អាចជួយឱ្យយើងចងចាំបាន ៥០% ឬច្រើនជាងនេះ នូវអ្វីដែលយើងបានរៀន ចំណែកឯកិច្ចការសិក្សានៅផ្នែកខាងលើនៃពីរ៉ាមីតអាចឱ្យយើងចងចាំតិចជាង ៥០% ។
- យើងមិនគួរយល់ច្រឡំថា ដ្យាក្រាមនេះចង់ឱ្យគ្រូបង្រៀនជៀសវាងហៅសិស្សឱ្យ "អាន" ឬ "ស្ដាប់" ការឧទ្ទេសនោះទេ។ ផ្ទុយទៅវិញដ្យាក្រាមនេះចង់ពន្យល់ថា កិច្ចការទាំងនេះគួរតែប្ដូរទៅជាកិច្ចការសកម្មៗជាច្រើនទៀត ដើម្បីពង្រឹងចំណេះដឹងឱ្យកាន់តែប្រសើរ។
- ប្រើដ្យាក្រាមផ្ដល់ជូន ដើម្បីបំពេញកិច្ចការក្នុងលំហាត់ខាងក្រោម៖



# លំហាត់

*សេចក្តីណែនាំ៖ សូមបំពេញកិច្ចការខាងក្រោមដោយកំណត់កិច្ចការ "សកម្ម" ដើម្បីធ្វើឱ្យប្រសើរឡើងនូវកិច្ចការ "អកម្ម"។ កិច្ចការអកម្មត្រូវបានផ្តល់ជូនរួចហើយនៅខាងក្រោម។ ឧទាហរណ៍មួយត្រូវបានផ្តល់ជូនសម្រាប់អ្នកផងដែរ។*

| | កិច្ចការអកម្ម | កិច្ចការសកម្ម<br>(ពង្រឹងចំណេះដឹង) |
|---|---|---|
| ឧ. | **កិច្ចការទី១៖** អានសៀវភៅអំពីប្រវត្តិអង្គរ | **កិច្ចការទី២៖** ឱ្យសិស្សក្នុងថ្នាក់ឡើងនិយាយពីសៀវភៅប្រវត្តិអង្គរ |
| ១ | **កិច្ចការទី១៖** ស្តាប់គ្រូអំពីអគ្គិសនីវារីអគ្គិសនីភាគទឹក | **កិច្ចការទី២៖** ??? |
| ២ | **កិច្ចការទី១៖** អានឯកសារអំពីរបៀបបេះដូងដំណើរការ | **កិច្ចការទី២៖** ??? |
| ៣ | **កិច្ចការទី១៖** មើលវីដេអូពីការធ្វើបង្អែមខ្មែរ | **កិច្ចការទី២៖** ??? |
| ៤ | **កិច្ចការទី១៖** ស្តាប់គ្រូឧទ្ទេសពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន | **កិច្ចការទី២៖** ??? |
| ៥ | **កិច្ចការទី១៖** ចូលរួមការតាំងពិព័រណ៍អំពីរបៀបកែច្នៃជ័រកៅស៊ូក្នុងរោងចក្រ | **កិច្ចការទី២៖** ??? |

# ឯកសារចែកទី៤៖ ការផ្សាភ្ជាប់រវាងការសិក្សាបែបស្ថាបនានិយម និង Bloom's Taxonomy




## ការពិភាក្សា

- កិច្ចការនៃការសិក្សាបែបស្ថាបនានិយម ជាទូទៅកើតឡើងនៅកម្រិតកាន់តែខ្ពស់ក្នុងប្លូមតាក់សូណូមី។

| | | | | |
|---|---|---|---|---|
| វិភាគ | ស្រាវជ្រាវតាមអ៊ីនធឺណែត | ធ្វើពិសោធវិភាគកង្កែប | បង្កើតដ្យាក្រាមមូលហេតុប្រវត្តិសាស្ត្រ | ពិភាក្សាការងារជាក្រុម |
| វាយតម្លៃ | វាយតម្លៃ របាយការណ៍សៀវភៅ | កំណត់ និងអនុវត្តស្តង់ដា | ធ្វើអាទិភាពបញ្ជីការងារ | រិះគន់ស្នាដៃប្រវត្តិសាស្ត្រ |
| បង្កើត | បង្កើតអត្ថបទកំណាព្យ | តាំងពិព័រណ៌ | ធ្វើបទបង្ហាញ | ព្យាករណ៍វិបាក |

- កិច្ចការក្នុងការសិក្សាបែបស្ថាបនានិយមនៅកម្រិតស្មុគស្មាញនេះ ជាញឹកញាប់តម្រូវឱ្យមានការរៀបផែនការរយៈពេលវែង ការប្រជុំ ការពិភាក្សា និងការកែលម្អច្រើនដងទៅលើផលិតផលសិក្សា ។
- ការសួរសំណួរកម្រិតខ្ពស់ ជំរុញឱ្យសិស្សបង្កើតបញ្ញត្តិផ្ទាល់ខ្លួនថ្មីៗ ដូច្នោះសំណួរដែលជំរុញឱ្យមានការគិតរកហេតុផលគឺជួយជំរុញបង្កើតបញ្ញត្តិ។

- ខាងក្រោមនេះជាគោលការណ៍ណែនាំមួយចំនួនសម្រាប់សួរសំណួរដែលគាំទ្រដល់ការសិក្សាបែបស្ពាបនានិយម៖

| វិភាគ | |
|---|---|
| **សំណួរ "របៀបណា និង ហេតុអ្វី"** | *-តើហេតុអ្វីអាកាសធាតុផ្លាស់ប្តូរ?*<br>*-តើជំងឺគ្រុនឈាម និងជំងឺគ្រុនចាញ់ដូចគ្នា និងខុសគ្នាដូចម្តេច?* |

| វាយតម្លៃ | |
|---|---|
| **សំណួរ "វិនិច្ឆ័យ"** | *-តើអ្នកណាជាមនុស្សអស្ចារ្យបំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ?* |

| បង្កើតថ្មី | |
|---|---|
| **សំណួរ "នឹងមានអ្វីកើតឡើង ប្រសិនបើ..."** | *-ប្រសិនបើអ្នកជាព្រះបាទជ័យវរ្ម័នទី ៧ តើអ្នកនឹងកាត់បន្ថយភាពក្រីក្រយ៉ាងដូចម្តេច?* |

## លំហាត់

***សេចក្តីណែនាំ៖*** បង្កើតសំណួរមួយសម្រាប់មុខវិជ្ជាមួយអ្នកជ្រើសរើស ដែលគាំទ្រដល់ការសិក្សាបែបស្ពាបនានិយមសម្រាប់ប្រភេទនៃការគិតនីមួយៗក្នុងបញ្ជីខាងក្រោម៖

| **មុខវិជ្ជា៖** ____________ | **មុខវិជ្ជា៖** ____________ | **មុខវិជ្ជា៖** ____________ |
|---|---|---|
| វិភាគ | វាយតម្លៃ | បង្កើតថ្មី |
| ____________ | ____________ | ____________ |
| ____________ | ____________ | ____________ |
| ____________ | ____________ | ____________ |
| ____________? | ____________? | ____________? |

## ឯកសារចែកទី៥កៈ ការបង្កើតបញ្ញត្តិ[5] និងការសិក្សាបែបស្ថាបនានិយម

**សេចក្ដីផ្ដើមៈ** ការសិក្សាបែបស្ថាបនានិយម ផ្ដោតលើការបង្កើតលក្ខខណ្ឌសិស្សអាចបង្កើតបញ្ញត្តិដោយធ្វើការរួមបញ្ចូលគ្នានូវទិន្នន័យ ឬព័ត៌មានផ្សេងៗទៅជាទម្រង់ថ្មីមួយ។

**និយមន័យនៃការបង្កើតបញ្ញត្តិៈ** ការបង្កើតបញ្ញត្តិ គឺជាដំណើរការមួយដែលលើកទឹកចិត្តឱ្យសិស្សចេះរៀបចំព័ត៌មានជាក្រុម ឬជាប្រភេទ រួមមានជាពាក្យ រូបភាព រូបមន្ត ឬដំណើរការដោយផ្អែកលើលក្ខណៈពិសេសរួមគ្នា។

### ជំហានទូទៅក្នុងការបង្កើតបញ្ញត្តិ ៖

**ជំហានទី១៖** គ្រូបង្ហាញទិន្នន័យ ឬឱ្យសិស្សជួយបង្កើតទិន្នន័យ

**ជំហានទី២៖** សិស្សរៀបចំទិន្នន័យជាក្រុម ឬប្រភេទទៅតាមលក្ខណៈដូច ឬប្រហាក់ប្រហែលគ្នា ឬលក្ខណៈវិនិច្ឆ័យអ្វី ដែលឱ្យគេអាចដាក់ទិន្នន័យក្នុងក្រុមរួមគ្នា។

**ជំហានទី៣៖** តាមរយៈសំណួរ និងការពិភាក្សា សិស្សកំណត់ឈ្មោះប្រភេទក្រុមទិន្នន័យ

**ជំហានទី៤៖** សិស្សចែករំលែកការរកឃើញពួកគេអំពីប្រភេទក្រុម ព្រមទាំងរៀបពួកគេដាក់ទិន្នន័យចូលក្នុងប្រភេទក្រុម។

### ការពិចារណាលើការគ្រប់គ្រងថ្នាក់រៀន៖

- ធ្វើការជាក្រុម
- ការកំណត់ទិន្នន័យអាចធ្វើឡើងជាមុន (ដោយគ្រូ) ឬកំណត់ដោយសិស្ស
- មធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្ហាញរួមមានការប្រើដ្យាក្រាម ផែនទីគំនិត ផែនទីបញ្ញត្តិ និងតារាងរចនាសម្ព័ន្ធ ។ល។




### អត្ថប្រយោជន៍៖

- ផ្ដល់ឱ្យសិស្សនូវបទពិសោធន៍ក្នុងការកំណត់ទំនាក់ទំនង នៅពេលដាក់ទិន្នន័យជាក្រុម
- ជួយសិស្សឱ្យយល់ពីខ្លឹមសារព័ត៌មាន
- សម្រួលការចងចាំព័ត៌មានពេលវាស្ថិតនៅក្នុងទម្រង់ជារូបភាព ជាពិសេសមានប្រយោជន៍សម្រាប់អ្នករៀនចេះតាមរយៈរូបភាព។

[5] http://www.tvdsb.ca/webpages/tkernaghan/educatorresources.cfm?subpage=190909

## លំហាត់

បង្កើតផែនទីគំនិតដែលបញ្ជាក់ពីប្រភេទភាសាផ្សេងៗនៃប្រទេសកម្ពុជា។ ប្រើពណ៌ផ្សេងគ្នាដើម្បីបែងចែករវាងក្រុមភាសាផ្សេងគ្នា។ អ្នកក៏អាចបែងចែកភាសាទៅតាមសំឡេងឡើងចុះ ការប្រើតួអក្សរឡាតាំង ។ល។ជាដើម សូមរកមើលព័ត៌មានក្នុងតារាងនេះ និងនៅលើបណ្ដាញអ៊ីនធឺណែត។

### ទិន្នន័យមុនពេលបង្កើត

| អូស្ត្រូអាស៊ី | អូស្ត្រូណេស៊ី | ស៊ីណូ-ទីបេ | តៃ-កាដៃ | ឥណ្ឌូ-អ៊ឺរ៉ុប |
|---|---|---|---|---|
| ខ្មែរ | ម៉ាលេ | ចិន | ថៃ | អង់គ្លេស |
| មន | ចាម | វៀតណាម | ឡាវ | បារាំង |
| ពួង | | ភូមា | អ៊ីសាន | បាលី |
| ទំពួន | | | | |
| គ្រឹង | | | | |
| គួយ | | | | |
| ស្ទៀង | | | | |

* * * * * * * * * * * * * * * * *

# ឯកសារចែកទី៥ខ៖ ការបង្កើតបញ្ញត្តិផ្ទុយគ្នាពីរ

*សំណួរសម្រាប់ស្រាវជ្រាវ៖* តើកត្តាអ្វីបង្កឱ្យមានការចុះខ្សោយនៃអាណាចក្រអង្គ?




- *សាវតារ៖* មានទ្រឹស្តីខុសៗគ្នាជាច្រើនស្តីពីមូលហេតុអាណាចក្រអង្គរធ្លាក់ចុះនៅក្នុងសតវត្សរ៍ទី១៥ នេះ។ មូលហេតុចម្បងបំផុត គឺការឈ្លានពានរបស់ថៃនៅក្នុងឆ្នាំ១៤៣១ ដែលជាលទ្ធផល ទីក្រុងរាជធានីអង្គររងការបំផ្លិចបំផ្លាញជាទ្រង់ទ្រាយធំ ហើយនៅទីបំផុត ក៏មានការសម្រេចចិត្តបោះបង់ចោលរាជធានីមកនៅទីតាំងថ្មីមួយស្ថិតនៅជិតតំបន់រាជធានីភ្នំពេញសព្វថ្ងៃនេះ។
- *កិច្ចការ៖* ធ្វើការស្រាវជ្រាវរកមូលហេតុនៃការចុះខ្សោយនៃអាណាចក្រអង្គរ និងបង្កើតផែនទីកត្តាបង្ក(ហេតុ និងផល) ពន្យល់ថាតើកត្តាទាំងនេះមានទំនាក់ទំនងគ្នាដូចម្តេច ហើយវាធ្វើឱ្យមានការដួលរលំនៃអាណាចក្រអង្គរដោយរបៀបណា?
- **ទិន្នន័យដែលត្រូវពិចារណា**



| | |
|---|---|
| • សង្គ្រាម<br>• ការឈ្លានពាន<br>• កម្សោយនៃភាពដឹកនាំ<br>• ការប្រែប្រួលអាកាសធាតុ<br>• គ្រោះរាំងស្ងួត<br>• ការផ្លាស់ប្តូរទៅកាន់ព្រះពុទ្ធសាសនាថេរវាទ | • អរិភាពជាមួយប្រទេសថៃ<br>• ការផ្លាស់ប្តូរជាសាកលផ្នែកសេដ្ឋកិច្ចតាមផ្លូវសមុទ្រ<br>• គ្រោះទុរភិក្ស<br>• អស្ថេរភាពសេដ្ឋកិច្ច<br>• ការបែកបាក់ផ្ទៃក្នុង |

## ការបង្កើតបញ្ញត្តិដោយក្រុមទី១




## ការបង្កើតបញ្ញត្តិដោយក្រុមទី២



## សំណួរសម្រាប់ពិភាក្សា

១. តើផែនទីបញ្ញត្តិទាំងពីរនេះដូចគ្នាបែបណាខ្លះ ?

២. តើផែនទីបញ្ញត្តិបង្កើតឡើងដោយក្រុមនីមួយៗខុសគ្នារបៀបណា ? (ឧ. តើក្រុមណាបានបង្កើតផែនទីមានបញ្ញត្តិច្រើនជាង ? តើផែនទីទាំងពីរមានទំនាក់ទំនងរវាងបញ្ញត្តិសមហេតុផលឬទេ ?

៣. តើអ្នកគិតថាសិស្សប្រើពណ៌ផ្សេងគ្នាក្នុងផែនទីពួកគេចង់និយាយពីអ្វី ?

៤. តើយើងអាចនិយាយថា ផែនទីបញ្ញត្តិមួយណា ឬទាំងពីរត្រឹមត្រូវ ឬខុសបានទេ ? ហេតុអ្វីត្រឹមត្រូវ ? ហេតុអ្វីមិនត្រឹមត្រូវ ?

* * * * * * * * * * * *

# ឯកសារចែកទី៦៖ យុទ្ធសាស្រ្តបង្រៀនល្អៗ មួយចំនួនសម្រាប់ការសិក្សាបែបស្ថាបនានិយម 6

## គោលការណ៍ណែនាំទូទៅ

- ប្រើយុទ្ធសាស្រ្តបង្រៀនដែលតម្រូវឱ្យសិស្សបង្កើត គំនិត ឬបញ្ញត្តិ បាន។ (ការបង្ហាញតែព័ត៌មាន គឺមិនគ្រប់គ្រាន់ទេ។) សិស្សត្រូវអនុវត្ត ប្រើប្រាស់ ឬធ្វើដំណើរការព័ត៌មាននេះ។
- ធានាថាសិស្សទាំងអស់បានចូលរួមក្នុងការបង្កើតគំនិត ដោយមានការទទួលខុសត្រូវចំពោះការសិក្សារៀងៗខ្លួន។
- ធានាថាកិច្ចការទាំងឡាយតម្រូវឱ្យសិស្សគិតនៅកម្រិតខ្ពស់តាម Bloom's taxonomy ៖ ការវិភាគ វាយតម្លៃ និងបង្កើតថ្មី។
- តម្រូវឱ្យសិស្សបង្កើតផលិតផលត្រូវប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃទៅលើកំហុស និងភាពខ្វះខាតនៃការសិក្សា។ ឧ.សន្ទនាជាមួយដៃគូ ផ្ទាំងផ្គងបណ្ណ និងលំហាត់សរសេរផ្សេងៗ។
- តម្រូវឱ្យសិស្សពិនិត្យរកមើលកំហុស និងភាពខ្វះខាតនៃការសិក្សារបស់ខ្លួនឯងផ្ទាល់ផង និងរបស់ដៃគូផង។
- តម្រូវឱ្យសិស្សកែតម្រូវលើកំហុស និងភាពខ្វះខាតនៃការសិក្សាទាំងនេះ។

## បច្ចេកទេសមួយចំនួនក្នុងសម្រេចបាននូវយុទ្ធសាស្រ្តខាងលើ

សិស្សធ្វើការជាដៃគូ សិក្សា អត្ថបទ វីដេអូ បានផ្តល់ឲ្យ រួមជាមួយ៖

- **បណ្ណការពិត** (Summary Facts Cards)៖ ជួយសង្ខេបចំណុចគន្លឹះៗពីអត្ថបទមួយចំណុចខ្លះពិត ហើយខ្លះទៀតមិនពិត។ ឧទាហរណ៍៖
  - ពាក្យថាវ៉ាឡង់ សំដៅទៅលើចំណងរវាងអាតូម
  - វ៉ាឡង់ជាធម្មតាកំណត់នៅក្នុងលក្ខខណ្ឌនៃចំនួនអប្បបរមារបស់អាតូមអ៊ីដ្រូសែនដែលជាតុមួយផ្សេងទៀតអាចភ្ជាប់ជាមួយវាបាន។
- **បណ្ណលទ្ធផល** (Consequence Cards) ៖ បង្ហាញពីលទ្ធផលការពិតណាមួយក្នុងអត្ថបទ។ លទ្ធផលទាំងនេះគឺមិនបង្ហាញជាក់ស្តែងនៅក្នុងអត្ថបទនោះទេ ហើយលទ្ធផលខ្លះពិត ខ្លះទៀតក៏មិនពិតដែរ ។

  *ឧទាហរណ៍ ៖ តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកជំនួសអាតូមស្ពាន់ធ័រ ដោយអាតូមអុកស៊ីសែន នៅក្នុងរូបមន្ត $H_2S$ ?*

ដៃគូនីមួយៗ ត្រូវសម្រេចចិត្តថាតើប័ណ្ណមួយណាត្រឹមត្រូវ ហើយប័ណ្ណមួយណាមិនត្រឹមត្រូវ?

---

[6] http://www.teacherstoolbox.co.uk/25_Ways/25ways-15-decisions2.html

ខាងក្រោមនេះជាឧទាហរណ៍លំហាត់ **ការសម្រេចចិត្ត-ការសម្រេចចិត្ត** សម្រាប់មេរៀនគីមីវិទ្យាមួយស្តីពីវ៉ាឡង់៖

### អត្ថបទ[7]

ក្នុងគីមីវិទ្យា វ៉ាឡង់ នៃធាតុមួយត្រូវបានបង្កើតឡើងពីការបញ្ចូលថាមពលគ្នាជាមួយអាតូមផ្សេងទៀត ពេលវាបង្កើតបានជាសមាសធាតុគីមី ឬម៉ូលេគុល។ បញ្ញត្តិនៃវ៉ាឡង់នេះ បានបង្កើតឡើងនៅពាក់កណ្តាលទី២ នៃសតវត្សរ៍ទី១៩ និងទទួលបានជោគជ័យក្នុងការពន្យល់អំពីរចនាសម្ព័ន្ធម៉ូលេគុលនៃសមាសធាតុអសរីរាង្គ និងសមាសធាតុសរីរាង្គ។ ថាមពលអាតូមនៃធាតុមួយត្រូវបានកំណត់ដោយចំនួននៃអាតូមអ៊ីដ្រូសែនវាបានបញ្ចូលជាមួយ។ ក្នុងមេតាន កាបូនមានវ៉ាឡង់ ៤ និងក្នុងអាម៉ូញាក់ អាសូតមានវ៉ាឡង់ ៣។ ក្នុងនីដ្រូសែនស៊ុលហ្វីដ ស្ពាន់ធ័រមានវ៉ាឡង់២។ ដ្យាក្រាមវ៉ាឡង់នៃសមាសធាតុ តាងឲ្យការតភ្ជាប់គ្នានៃធាតុដែលហៅថា**សមាសធាតុ** ជាមួយនឹងគំនូសបន្ទាត់រវាងធាតុទាំងពីរតំណាងឲ្យការដាក់ចូលគ្នារវាងវ៉ាឡង់សម្រាប់ធាតុនីមួយៗ។ ខាងក្រោម នេះជាឧទាហរណ៍មួយចំនួន៖

| **សមាសធាតុ** | $H_2$ (Hydrogen) អ៊ីដ្រូសែន | $CH_4$ (Methane) មេតាន | $NH_3$ (Ammonia) អាម៉ូញាក់ | $H_2S$ (Hydrogen Sulfide) អ៊ីដ្រូសែនស៊ុលហ្វីដ |
|---|---|---|---|---|
| **ដ្យាក្រាម** |  |  |  |  |
| **វ៉ាឡង់** | អ៊ីដ្រូសែន១ | កាបូន៤ អ៊ីដ្រូសែន១ | អាសូត ៣ អ៊ីដ្រូសែន១ | ស្ពាន់ធ័រ២ អ៊ីដ្រូសែន១ |

សេចក្តីណែនាំ៖ ដោយផ្អែកទៅលើការយល់ដឹងទៅលើអត្ថបទខាងលើ នៅក្នុងក្រុមសូម កំណត់បណ្ណការពិតសង្ខេប មួយដែលខុស និងមូលហេតុនាំឲ្យខុស ។ បន្ទាប់មក ទស្សន៍ទាយលទ្ធផលនៃលក្ខខណ្ឌបានរៀបរាប់នៅក្នុងបណ្ណលទ្ធផល។

[7] https://en.wikipedia.org/wiki/Valence_(chemistry)

| បណ្ណការពិតសង្ខេប | បណ្ណលទ្ធផល |
|---|---|
| ១. គំនិតនៃវ៉ាំឡង់នេះបានទទួលជោគជ័យក្នុងការពន្យល់អំពីរចនាសម្ព័ន្ធម៉ូលេគុលនៃសមាសធាតុសរីរាង្គ។ | ក. តើមានអ្វីកើតឡើងប្រសិនបើអ្នកជំនួសអាតូមស្ពាន់ធ័រ ដោយអាតូមអុកស៊ីសែននៅក្នុង $H_2S$ ? |
| ២. ពាក្យថាវ៉ាំឡង់សំដៅទៅលើការភ្ជាប់គ្នារវាងអាតូមនិងអាតូម។ | ខ. តើនឹងមានអ្វីកើតឡើងទៅលើម៉ូលេគុលមេតាន ប្រសិនបើដកអាតូមកាបូនចេញ ? |
| ៣. ជាធម្មតា វ៉ាំឡង់ត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌចំនួនអប្បបរមាអាតូមអ៊ីដ្រូសែន ដែលធាតុមួយអាចភ្ជាប់ជាមួយបាន។ | គ. តើមានអ្វីកើតឡើងដល់ស្ថេរភាពនៃ ម៉ូលេគុលរបស់អាម៉ូញាក់ $NH_3$ ប្រសិនបើអ្នកដកអាតូមអ៊ីដ្រូសែនមួយចេញ ? |
| ៤. វ៉ាំឡង់ គឺបញ្ញត្តិថ្មី។ | ឃ. តើមានអាតូមផ្សេងទៀតដែរឬទេអាចជំនួសស្ពាន់ធ័រក្នុង $H_2S$ ? តើនឹងផលិតបានអ្វី ? |

- ជីក-ស ( Jigsaw)៖ វិធីសាស្ត្រសិក្សាបែបសហការ

ជីក-ស គឺជាយុទ្ធវិធីបង្រៀនបែបបែបសហការមួយមានប្រសិទ្ធិភាពខ្ពស់។




- ចែកប្រធានបទមួយ ឲ្យទៅប្រធានបទតូចៗចំនួន ៤។ ចំនួនប្រធានបទតូចៗ អាចមានច្រើនឬតិចជាងនេះ អាស្រ័យលើទំហំថ្នាក់របស់អ្នក។ ឧទាហរណ៍៖ ជំងឺក្នុងតំបន់ត្រូពិចដែលមានជំងឺផ្សេងគ្នាអាចនឹងត្រូវបានបែងចែកទៅជា (ក) រាគមួល (ខ) ជំងឺគ្រុនឈាម (គ) គ្រុនចាញ់ និង (ឃ) គ្រុនពោះវៀន។



- មានជម្រើសមួយទៀត អ្នកអាចផ្តល់ឲ្យសិស្សនូវសំណួរគន្លឹះ ឬ "ទស្សនៈ"ផ្សេងគ្នាចំនួន ៤ តម្រូវឲ្យសិស្សវិភាគលើប្រធានបទដូចគ្នា តែទៅលើផ្នែកផ្សេងៗពីគ្នា។ ឧទាហរណ៍៖ សិស្សទាំងអស់ត្រូវបានផ្តល់ព័ត៌មានពីសម័យអាណានិគមបារាំងដូចគ្នា ប៉ុន្តែបន្ទាប់មកគេសួរដើម្បីវាយតម្លៃផ្សេងគ្នាពី (ក) កសិករកម្ពុជា (ខ) អ្នកគ្រប់គ្រងកម្ពុជា (គ) អ្នកគ្រប់គ្រងបារាំង និង (ឃ) ព្រះមហាក្សត្រនៃប្រទេសកម្ពុជា។

នេះជាការវាយតម្លៃគួរឲ្យចាប់អារម្មណ៍មួយ ព្រោះសិស្សត្រូវបង្កើតស្តង់ដានៃការវិនិច្ឆ័យផ្សេងគ្នា



ចេញពីក្រុមនីមួយៗ និងឆ្លើយតបទៅនឹងសំណួររួមមួយគឺ បារាំងបានធ្វើអ្វីខ្លះក្នុងអំឡុងពេលសម័យអាណានិគម?

- ចែកសិស្សជា ៤ ក្រុម។ គ្រូជ្រើសរើសក្រុមមានសមត្ថភាព បទពិសោធន៍ផ្សេងគ្នា ភេទ ជាតិសាសន៍ចម្រុះ។ កុំរើសក្រុមផ្អែកលើមិត្តភាព ។ សិស្សនឹងតវ៉ាពេលអនុវត្តដំបូង ប៉ុន្តែពួកគេនឹងសម្របខ្លួនបានបើអ្នកនៅតែទទូចឲ្យពួកគេចូលរួម។
- ក្រុមនីមួយៗសិក្សាពីជំងឺឬសំណួរមួយដោយមានជំនួយពីអត្ថបទ និងសន្លឹកកិច្ចការជាដើម ទោះបីជាអ្នកអាចប្រើវិធីសាស្ត្រនេះសម្រាប់សិស្សសិក្សានៅខាងក្រៅពេលម៉ោងសិក្សាក៏ដោយ ជាធម្មតាគេប្រើវានៅក្នុងម៉ោងសិក្សាប៉ុណ្ណោះ។ (សូមមើលការស្រាវជ្រាវតាមបណ្ដាញអ៊ីនធឺណែតក្នុងឯកសារចែក ៩) ។
- ឥឡូវសិស្សសិស្សពីក្រុមនីមួយៗ ត្រូវចូលរួមបង្កើតក្រុមថ្មីទៀតទៅតាមប្រធានបទគេទទួលខុសត្រូវដោយមានសិស្សម្នាក់ មកពីក្រុមនីមួយៗផ្សេងគ្នា។ សិស្សទាំងឡាយណាលើសចំនួនគឺអាចធ្វើការធ្វើជាដៃគូលើប្រធានបទតែមួយ។ ក្រុមនីមួយៗពេលនេះឈ្មោះថា "ក្រុមជំនាញ" នៃជំងឺតំបន់ត្រូពិចនីមួយ។ (អាចមានអ្នកជំនាញពីរនាក់លើប្រធានបទជំងឺមួយ)។

## ដំណើរការជីក-ស៖ ជំងឺត្រូពិច

### ជំហាន១៖ ស្រាវជ្រាវ

ក្រុមនីមួយៗសិក្សាពីជំងឺមួយទាក់ទងនឹង៖

- របៀបនៃការឆ្លង
- រោគសញ្ញា
- រយៈពេលរបស់វីរុសផ្ទុក
- ការការពារ
- ការព្យាបាល

### ជំហាន២៖ ជីក-ស (Jigsaw)

សិស្សម្នាក់ពីក្រុមនីមួយៗចូលរួមជាមួយក្រុមផ្សេងទៀតដើម្បីចែករំលែកពីប្រធានបទជំងឺរបស់ពួកគេ។

ពួកគេត្រូវតែបង្កើតទម្រង់សំណួរជីក-ស សង្ខេបលក្ខណៈនៃជំងឺនីមួយៗ។ ក្រោយមកពួកគេត្រូវបំពេញសំណួរ **ជីក-ស** មានបង្ហាញក្នុងប្រអប់ខាងក្រោម។




⚜ = អ្នកជំនាញ ជំងឺរាកមូល

⚜ = អ្នកជំនាញ ជំងឺគ្រុនឈាម

⚜ = អ្នកជំនាញ ជំងឺគ្រុនចាញ់

⚜ = អ្នកជំនាញ ជំងឺគ្រុនពោះវៀន

បន្ទាប់ពីបញ្ចប់សកម្មភាពពិភាក្សាក្នុងក្រុមជំនាញ ពួកគេត្រូវត្រឡប់ចូលក្រុមដើមវិញ ហើយចែកវេនគ្នាចែករំលែកប្រធានបទរៀងៗខ្លួន។

**សំណួរ ជីក-ស (Jigsaw)**

- ពន្យល់ពីជំងឺរបស់អ្នកទៅក្រុមថ្មីរបស់អ្នកដែលនៅសេសសល់ ដោយពន្យល់ដូចគ្នានូវកិច្ចការដែលបានធ្វើខាងដើម។ (ពេល ផ្ទុកមេរោគ របៀបចម្លង ។ល។)

______________________________________

______________________________________

______________________________________

- សហការក្នុងការស្វែងរកចំណុចបីដែលជំងឺទាំងអស់មានសណ្ឋានរួមគ្នា។

______________________________________

______________________________________

______________________________________

- សម្រាប់ជំងឺទាំងបួន សហការគ្នាដើម្បីស្វែងរកលក្ខណៈពិសេសឱ្យបានចំនួនបួន។

______________________________________

______________________________________

______________________________________

- ផលិតខិត្តបណ្ណស្តីពីជំងឺតំបន់ត្រូពិច។ រៀបជំងឺទាំងបួនដាក់តាមលំដាប់៖

    A) ភាពធ្ងន់ធ្ងរនៃផលវិបាក

    B) ភាពងាយស្រួលក្នុងការការពារ

# ឯកសារចែក ៧៖ វិធីសាស្ត្រការសិក្សាអាស្រ័យលើបញ្ហាដើម្បីលើកកម្ពស់ការសិក្សាបែបស្ថាបនានិយម[8]

**និយមន័យ៖** ការសិក្សាអាស្រ័យលើបញ្ហា (PBL) គឺជាបច្ចេកទេសសិក្សាតាមបែបស្ថាបនានិយម សិស្សនឹងរៀនអំពីមុខវិជ្ជាតាមរយៈបទពិសោធន៍នៃការដោះស្រាយបញ្ហាទូទៅ។ សិស្សរៀនទាំងវិធីនៃការគិត និងផ្នែកចំណេះដឹង។

**ដំណើរការ៖** ពេលធ្វើការជាក្រុម សិស្ស (ក) កំណត់អ្វីពួកគេបានដឹងរួចហើយ (ខ) កំណត់អ្វីពួកគេត្រូវដឹង និង (គ) របៀប និងកន្លែងសិស្សស្រាវជ្រាវយកព័ត៌មានថ្មីនាំទៅរកដំណោះស្រាយបញ្ហា។ តួនាទីគ្រូ គឺជួយសម្រួលដល់ការសិក្សាដោយផ្តល់ការគាំទ្រ ណែនាំ និងតាមដានការសិក្សាសិស្ស។ គ្រូបង្រៀនត្រូវតែធ្វើឲ្យសិស្សមានទំនុកចិត្តក្នុងការទទួលយកបញ្ហា ព្រោះវាអាចជួយយពង្រីកការយល់ដឹងពួកគេបាន។ ការសិក្សាអាស្រ័យលើបញ្ហា តំណាងឲ្យការផ្លាស់ប្តូរគំរូពីការបង្រៀនតាមបែបប្រពៃណី និងទស្សនវិជ្ជាបង្រៀនដោយផ្តោតទៅលើសកម្មភាពគ្រូច្រើន និងសន្មតថាសិស្សរៀនបានច្រើនពេលពួកគេបានស្តាប់ច្រើន។

### ឧទាហរណ៍៖

*សេចក្តីណែនាំ៖ រូបភាពខាងក្រោមនេះបានបង្ហាញពីឈុតឆាកមួយពីការសាងសង់មហាកំផែងចិនដែលបានសាងសង់ឡើងដោយអធិរាជ Qin Shihuang អំឡុងឆ្នាំ ២២០ មុនគ.ស។ មានកំហុសចំនួន៧ ក្នុងរូបភាពនេះដែលខុសពីប្រវត្តិសាស្ត្រ។ ដោយផ្អែកលើចំណេះដឹងរបស់អ្នក ចូរកំណត់កំហុសទាំង៧ ដែលមិនត្រឹមត្រូវ និងធ្វើការបកស្រាយពីមូលហេតុដែលខុស។*



[8]https://en.wikipedia.org/wiki/Problem-based_learning

## សំណួរពិភាក្សា

*ក្នុងក្រុមរបស់អ្នក ចូរពិភាក្សាពីសំណួរខាងក្រោម និងរាយការណ៍ទៅក្រុមធំ។*

១. តើអ្នកអាចរកឃើញកំហុសបានប៉ុន្មាន ?

២. តើក្រុមរបស់អ្នកកំណត់អ្វីបានដឹងរួចហើយដោយរបៀបណា ដើម្បីដោះស្រាយបញ្ហា ? (ឧទាហរណ៍៖ កាលបរិច្ឆេទសាងសង់មហាកំផែង និងបច្ចេកវិទ្យានាសម័យ ។ល។)។

៣. តើអ្នកបានកំណត់អ្វីអ្នកត្រូវដឹងបន្ថែមដោយរបៀបណា ដើម្បីដោះស្រាយបញ្ហា ? (ឧទាហរណ៍៖ តើអ្វីអ្នកដឹងមិនទាន់ច្បាស់នៅក្នុងរូបភាព ហើយត្រូវស្វែងយល់ ? )

៤. តើអ្នកបានកំណត់អ្វីអ្នកមិនទាន់បានដឹងដោយរបៀបណា ដើម្បីដោះស្រាយបញ្ហា ?

**ចម្លើយ**[9]

១. ចិនបុរាណ មិនមាន រទេះរុញប្រភេទទំនើបនោះទេ។ ទោះបីជាពួកគេបានបង្កើតឧបករណ៍នេះមុនគេ ដែលគេហៅថា 'គោឈើ " ដែលបានបង្ហាញនៅក្នុងរូបភាពនេះក៏ដោយ ក៏ពួកគេមិនមានរទេះរុញដែលទំនើបដូចបច្ចុប្បន្ននោះទេ។

២. សិប្បករជនជាតិហាន-ចិនបានផលិតវត្ថុល្អៗជាច្រើនដូចជាសេះដែលធ្វើពីលង្ហិនដែលបានបង្ហាញក្នុងរូបភាពនេះ។ ប៉ុន្តែពួកគេមិនអាចធ្វើជាគំរូនៃប៉ម តួអេហ្វែល( Eiffel Tower) ដែលទើបតែសាងសង់ក្នុងឆ្នាំ ១៨៨៩ នៅក្នុងប្រទេសបារាំង ដែលជាប្រទេសមួយចិនមិនទាន់ស្គាល់នៅពេលនោះទេ។

៣. ចិនបុរាណមិនបានប្រើលុយដែលមានសណ្ឋានដូចនេះទេ។ កាក់ចិនបុរាណ មានរាងមូល និងមានរន្ធនៅចំកណ្តាល។

៤. ក្មេងៗចិនមិនមានឡានជរំ លេងទេ នៅក្នុងសតវត្សរ៍ទី ៣ មុនគ.ស។

៥. ចិនបុរាណជាជាងឈើដ៏ចំណាន ប៉ុន្តែពួកគេមិនមានម៉ូទ័រស្វានប្រើអំឡុងពេលនេះទេ។

៦. យើងមិនអាចរកឃើញនិមិត្តសញ្ញារបស់ St. George ដែលជាអស្សឫទ្ធិប្រទេសអង់គ្លេស នៅលើផែនទីចិនបុរាណនោះទេ។ ប្រទេសអង់គ្លេសមិនទាន់កើតនៅឡើយនាពេលនោះ សូម្បីព្រះយេស៊ូគ្រិស ក៏មិនទាន់កើតផងដែរ។

៧. មិនមានផ្លូវដែកនៅក្នុងប្រទេសចិនទេពីមុនទេ វាទើបតែមាននៅចុងសតវត្សរ៍ទី១៩ ។ ក្នុងសតវត្សរ៍ទី៣ ទំនិញចិនត្រូវបានដឹកជញ្ជូនតាមបណ្តាញផ្លូវគោក និងផ្លូវទឹក។

[9] Wood, J. (1992) *Errata: A Book of Historical Errors,* New York: Green Tiger Press.

## លំហាត់

ប្រើការពន្យល់ផ្តល់ជូនខាងលើ និងប្រើប្រាស់សៀវភៅសិក្សាគោលផ្តល់ឲ្យដោយគ្រូបណ្តុះបណ្តាលបង្កើតសំណួរ ឬលំហាត់ផ្សេងៗតាមគោលវិធីសិក្សាបែបស្ថាបនានិយមដោយប្រើបច្ចេកទេសសម្រេចចិត្ត-សម្រេចចិត្ត (Decisions-Decisions) ឬបច្ចេកទេសជីក-ស(Jigsaw)។ ពន្យល់ពីសំណួរ ឬលំហាត់នោះ ឲ្យបានលម្អិតដោយផ្តល់ជាឧទាហរណ៍ជាគំរូសិស្សអាចឆ្លើយបាន។

# ឯកសារចែកទី ៧៖ វិធីសាស្រ្តការសិក្សាអាស្រ័យលើបញ្ហាដើម្បីលើកកម្ពស់ការសិក្សាបែបស្ថាបនានិយម

**និយមន័យ៖** ការសិក្សាអាស្រ័យលើបញ្ហា (PBL) គឺជាវិធីសាស្ត្របង្រៀនដ៏សំខាន់មួយបង្កើតឡើងផ្អែកលើគោលការណ៍នៃទ្រឹស្តីស្ថាបនានិយម។ ឧទាហរណ៍ នៅក្រោមវិធីសាស្ត្រនេះ សិស្សសហការគ្នាសិក្សាអំពីប្រធានបទ ឬគោលការណ៍តាមរយៈបទពិសោធន៍នៃការប្រើប្រាស់គោលការណ៍ទាំងនោះដើម្បីដោះស្រាយបញ្ហាជីវិតពិត។ យន្តការទូទៅបំផុតដែលសិស្សប្រើដើម្បីសម្រេចការដោះស្រាយបញ្ហាគឺតាមរយៈការបង្កើត 'គម្រោង'។ គម្រោងនេះអាចត្រូវបានធ្វើជាក្រុម ឬដោយបុគ្គល (ប៉ុន្តែភាគច្រើនធ្វើជាក្រុម)។ ការបង្កើតគម្រោងគឺជាឧទាហរណ៍ដ៏ល្អបំផុតមួយនៃរបៀបសិស្ស 'បង្កើត' ផលិតផលចំណេះដឹងថ្មីដោយប្រើជំនាញគិតកម្រិតខ្ពស់ដូចជា 'វិភាគ' 'វាយតម្លៃ' និង 'បង្កើតថ្មី' ។

PBL តំណាងឱ្យការផ្លាស់ប្តូរគំរូពីទស្សនវិជ្ជាបង្រៀន និងរៀនបែបបុរាណ ដែលច្រើនតែផ្អែកលើការបង្រៀន ហើយសន្មតថាសិស្សរៀនបានល្អបំផុតនៅពេលពួកគេជាអ្នកស្តាប់អសកម្ម។

## ឧទាហរណ៍នៃគម្រោងសិក្សាអាស្រ័យលើបញ្ហា

សុភា ជាសិស្សថ្នាក់ទី៩ នៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ក្រុងកំពង់ចាម។ សុភា និងក្រុមគាត់មានបញ្ហាទាក់ទងនឹងសួនជីវចម្រុះនៅសាលា។ នេះជារបៀបដែលពួកគេបានពិពណ៌នាអំពីបញ្ហា៖





***ការបរិយាយអំពីបញ្ហា៖***

*រុក្ខជាតិនៅក្នុងសួនច្បារហាក់ដូចជាទទួលទឹកច្រើនពេកធ្វើឱ្យពួកវារលួយ ឬនៅថ្ងៃខ្លះទទួលបានទឹកតិចពេកធ្វើឱ្យក្រៀមស្វិត។*

ដើម្បីដោះស្រាយបញ្ហានេះ សុភា និងក្រុមរបស់គាត់បានសម្រេចចិត្តប្រើប្រាស់អ្វីពួកគេកំពុងរៀននៅក្នុងថ្នាក់ 'ការសរសេរកូដ' ដើម្បីបង្កើតកម្មវិធីមួយនៅពេលភ្ជាប់ជាមួយឧបករណ៍អេឡិចត្រូនិចគាត់បានបង្កើត អាចគ្រប់គ្រងលំហូរទឹកទៅកាន់សួនច្បារសាលាបាន។ ក្នុងន័យនេះ សុភាបានប្រើចំណេះដឹងដែលគាត់បានរៀនក្នុងថ្នាក់សរសេរកូដ ព្រមទាំងអ្វីគាត់រៀននៅក្លឹបអេឡិចត្រូនិក។ សមាសធាតុសំខាន់នៅក្នុង 'ដំណោះស្រាយ' របស់គាត់គឺត្រូវប្រើឧបករណ៍ចាប់ស៊ីញ៉ាល់ចាប់បរិមាណសំណើមនៅក្នុងដី និងផ្តល់សញ្ញាថាតើទឹកត្រូវបានបើក ឬបិទ?

ករណីសិក្សានេះគឺជាឧទាហរណ៍ដ៏ល្អនៃគម្រោងមានការប្រើប្រាស់ជាក់ស្តែងបំផុតនៅពេលបញ្ចប់។ ក្នុងករណីនេះ សិស្សម្នាក់កំណត់បញ្ហាជាក់ស្តែងមួយ ហើយបានប្រើអ្វីគាត់កំពុងរៀនក្នុងថ្នាក់

និងក្នុងក្លីបសិក្សាដើម្បី 'បង្កើត' ដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត។ សូមចុច តំណភ្ជាប់ ខាងក្រោមដើម្បីយល់កាន់តែច្បាស់ពីគម្រោងរបស់សុភា៖

https://www.facebook.com/NGSAction/videos/540970754473055

## លំហាត់

តាមរយៈការឆ្លុះបញ្ចាំងពីនិយមន័យនៃការសិក្សាបែបស្ថាបនានិយមអ្នកបានរៀននៅក្នុងឯកសារចែក ២ក សូមចង្អុលបង្ហាញពីរបៀបដែល ការសិក្សាអាស្រ័យលើបញ្ហា អនុវត្តនូវគោលការណ៍មួយចំនួនមានក្នុងទ្រឹស្តីស្ថាបនានិយម ។ ឧទាហរណ៍មួយត្រូវបានធ្វើសម្រាប់អ្នកខាងក្រោម។

**១. សកម្មភាពដឹកនាំដោយខ្លួនឯង៖ (ឧទាហរណ៍)**

សុភា និងក្រុមរបស់គាត់បានកំណត់បញ្ហាពួកគេចង់ដោះស្រាយដោយខ្លួនឯងដោយផ្អែកលើបញ្ហាជីវិតពិតពួកគេបានជួបប្រទះនៅសួនជីវចម្រុះរបស់សាលា។ គ្រូមិនបានប្រាប់ពួកគេឱ្យធ្វើគម្រោងនេះទេ ផ្ទុយទៅវិញ ពួកគេបានជ្រើសរើសគម្រោងនេះដោយខ្លួនឯង។

**២. ការឆ្លុះបញ្ចាំងលើបទពិសោធន៍ពីអតីតកាល និងព័ត៌មានថ្មី៖**

______________________________________________

______________________________________________

______________________________________________

**៣. សហការជាមួយអ្នកដទៃដើម្បីបង្កើតគំនិតចម្រុះគ្នា៖**

______________________________________________

______________________________________________

______________________________________________

**៤. ការបង្កើតចំណេះដឹង និងគំនិតថ្មីៗ៖**

______________________________________________

______________________________________________

______________________________________________

# ឯកសារចែកទី៨៖ ដំណើរការ និងផលិតផល នៃកាសិក្សាបែបស្ថាបនានិយម

<table>
<tr><td rowspan="8">ឧទាហរណ៍ពីដំណើរការ និងផលិតផលសិក្សា តាមបែបស្ថាបនានិយម<br><br>បង្កើតបរិបទសម្រាប់ការសិក្សាបែបសកម្ម...</td><td></td><td>គម្រោងវិទ្យាសាស្ត្រ</td></tr>
<tr><td></td><td>ការងារគម្រោងជាក្រុម</td></tr>
<tr><td></td><td>ការតាំងពិព័រណ៍</td></tr>
<tr><td></td><td>បទបង្ហាញ</td></tr>
<tr><td></td><td>របាយការណ៍សៀវភៅ & ការនិពន្ធ</td></tr>
<tr><td></td><td>ការស្រាវជ្រាវតាមអ៊ីនធឺណែត</td></tr>
<tr><td></td><td>ទស្សនកិច្ចសិក្សា</td></tr>
<tr><td></td><td>កិច្ចការពិសោធន៍</td></tr>
</table>

## សំណួរសម្រាប់ពិភាក្សា

១. តើឧទាហរណ៍ខាងលើណាខ្លះបង្ហាញពី "ដំណើរការ" ហើយណាខ្លះជា "ផលិតផល"? តើអ្នកដឹងដោយរបៀបណា?

២. ពិចារណាពី *គោលការណ៍នៃការសិក្សាបែបស្ថាបនានិយម* បានពិភាក្សានៅក្នុងឯកសារចែក ២៩ ។ ជ្រើសយកដំណើរការ / ផលិតផលមួយ ហើយពន្យល់មូលហេតុដែលទាក់ទងនឹងគោលការណ៍ស្ថាបនានិយមដោយបំពេញតារាងខាងក្រោម។
តើវាមាន *អន្តរកម្ម* ដោយរបៀបណា? តើវា *ជាក់ស្តែង* ដោយរបៀបណា? តើវាជា *ការសិក្សាបែបសម្របសម្រួល* ដោយរបៀបណា? តើវាលក្ខណៈជា *សិស្សមជ្ឈមណ្ឌល* ដោយរបៀបណា?

| សកម្មភាពសិក្សាបែបស្ថាបនានិយម | ផលិតផល ឬ ដំណើរការ | តើវាបង្ហាញពីគោលការណ៍ស្ថាបនានិយមដោយរបៀបណា? |
|---|---|---|
| | ✚ | ✚ |

## លំហាត់

*សេចក្តីណែនាំ៖* ពិនិត្យមើលសកម្មភាពនីមួយៗ ហើយកំណត់ការរៀបចំ ផ្សេងៗដើម្បីពង្រឹងស្ថាប័នដើម្បីឲ្យសកម្មភាពទាំងនោះកើតឡើងប្រកបដោយប្រសិទ្ធិភាព។

| សកម្មភាពសិក្សាបែបស្ថាបនានិយម | តម្រូវការស្ថាប័ន |
|---|---|
| **គម្រោងវិទ្យាសាស្ត្រ** | ✚ ការរៀបចំគ្រូវិទ្យាសាស្ត្រស្ម័គ្រចិត្តប្រឹក្សាដល់ក្លឹបវិទ្យាសាស្ត្រ<br>✚ ថវិកាសម្រាប់ទិញសម្ភារ<br>✚ ពេលវេលាគ្រប់គ្រាន់៖ ទាំងសកម្មភាពក្រៅថ្នាក់ ទាំងសកម្មភាពសិក្សាម៉ោងបន្ថែម<br>✚ មានសៀវភៅបំប៉នក្លឹបមុខវិជ្ជា |
| **គម្រោងការងារជាក្រុម** | ✚ |

| សកម្មភាពសិក្សាបែបស្ថាបនានិយម | តម្រូវការស្ថាប័ន |
|---|---|
| ការតាំងពិព័រណ៌ | |
| បទបង្ហាញ | |
| សៀវភៅរបាយការណ៍ និងកំណាព្យ | |
| ការស្រាវជ្រាវតាមបណ្ដាញអ៊ីនធឺណែត | |
| ទស្សនកិច្ចសិក្សា | |
| កិច្ចការបន្ទប់ពិសោធន៍ | |

# ឯកសារចែកទី៩៖ ការសិក្សាបែបស្ថាបនានិយម និងបច្ចេកវិទ្យា



**ការសិក្សាគឺការបង្កើតទំនាក់ទំនងសង្គម៖** ប្រសិនបើកុមារ អភិវឌ្ឍល្អប្រសើរក្នុងសង្គម ឬក្រុមរបស់ពួកគេ នោះការប្រើប្រាស់បច្ចេកវិទ្យាដើម្បីភ្ជាប់ទំនាក់ទំនង អាចមានប្រសិទ្ធិភាពខ្ពស់។

**ការអនុវត្តគោលការណ៍នេះ៖** ដោយផ្អែកលើគោលការណ៍ខាងលើ គ្រូបង្រៀនបែបស្ថាបនានិយម គួរតែបង្កើតបរិបទសិក្សាមួយដែលសិស្សអាចចូលរួមក្នុងសកម្មភាពដោយមានការលើកទឹកចិត្ត និងជួយសម្រួលពីលោកគ្រូ អ្នកគ្រូ។ ទោះជាយ៉ាងណា គ្រូមិនត្រូវឈរចាំមើលសិស្សសិក្សាស្វែងយល់ និងស្រាវជ្រាវមេរៀននោះទេ ផ្ទុយទៅវិញគ្រូអាចដឹកនាំសិស្ស លើកទឹកចិត្តឲ្យពួកគេធ្វើការជាក្រុម ដើម្បីគិតពីបញ្ហា និងសំណួរ។ គ្រូគួរគាំទ្រពួកគេតាមរយៈការលើកទឹកចិត្ត និងផ្តល់ប្រឹក្សាដើម្បីដោះស្រាយបញ្ហា ហានិភ័យ និងបញ្ហាប្រឈមបានចាក់ឫសនៅក្នុងស្ថានភាពជីវិតពិតរបស់ពួកគេ ជាកត្តាជំរុញឲ្យពួកគេចាប់អារម្មណ៍ និងពេញចិត្តនិងសកម្មភាពសិក្សាទាំងនេះ។



## បច្ចេកវិទ្យា និងការសិក្សាទំនាក់ទំនងសង្គមបែបស្ថាបនានិយម

បច្ចេកវិទ្យាផ្តល់ជាឧបករណ៍ដ៏សំខាន់ដើម្បីជួយសម្រេចគោលដៅនៃការសិក្សាទំនាក់ទំនងសង្គមបែបស្ថាបនានិយម។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួននៃព័ត៌មានវិទ្យាអាចជួយក្នុងការសិក្សាទំនាក់ទំនងសង្គមបែបស្ថាបនានិយម៖

- *ឧបករណ៍ទូរគមនាគមន៍៖* ដូចជាអ៊ីម៉ែល និងអ៊ីនធឺណែត ផ្តល់ជាមធ្យោបាយមួយសម្រាប់ការសន្ទនា ការពិភាក្សា ការជជែកដេញដោល និងអន្តរកម្មរវាងសិស្ស។ សិស្សអាចជជែកជាមួយសិស្សផ្សេងទៀត ជាមួយគ្រូ និងជាមួយគ្រូក្នុងសហគមន៍បាន បើទោះបីជាពួកគេនៅឆ្ងាយពីថ្នាក់រៀនរបស់ពួកគេក៏ដោយ។ ឧបករណ៍ទូរគមនាគមន៍អាចជួយផ្សាភ្ជាប់សិស្សជាមួយធនធានព័ត៌មានច្រើនប្រភេទបាន ហើយក៏អាចជួយពួកគេឲ្យយល់ទាំងវប្បធម៌របស់ខ្លួន និងវប្បធម៌របស់អ្នកដទៃ។
- *បទបង្ហាញជា PowerPoint៖* បទបង្ហាញដែលបង្កើតឡើងដោយសិស្សនៅក្នុងក្រុមរបស់ពួកគេក៏បានផ្តល់នូវបណ្តាញសង្គមដ៏មានប្រយោជន៍សម្រាប់សិស្សដើម្បីធ្វើការរួមគ្នាជាក្រុមក្នុង

ការផលិតជាផលិតផលសិក្សា ប្រកបដោយការច្នៃប្រឌិតដើម្បីចែករំលែកជាមួយសិស្សក្នុងថ្នាក់។ សាលារៀនគួរតែមានម៉ាស៊ីន LCD សម្រាប់បញ្ចាំង ដែលទាំងគ្រូនិងសិស្សអាចប្រើប្រាស់បានសម្រាប់គោលបំណងនេះ។

- ***សម្ភារបរិក្ខាភ្ជាប់អ៊ីនធឺណែតនៅក្នុងបណ្ណាល័យ៖*** ការបង្កើតសម្ភារបរិក្ខា ងាយស្រួលចូលប្រើអ៊ីនធឺណិតនៅក្នុងបណ្ណាល័យជាមធ្យោបាយមួយទៀត ដើម្បីឲ្យសិស្សអាចធ្វើការជាមួយគ្នានៅលើកិច្ចការវិភាគ។ សម្ភារបរិក្ខានេះអាចត្រូវបានប្រើដើម្បីដោះស្រាយបញ្ហាគ្រូដាក់ឲ្យ ការអភិវឌ្ឍការងារគម្រោង ប្រភពនៃរូបភាព និងដ្យាក្រាមនានា ។
- ***កម្មវិធីសរសេរតាមបណ្ដាញអ៊ីនធឺណែត៖*** ផ្ដល់នូវវេទិកាតែមួយសម្រាប់ការសរសេរតាមបែបសហការ។ សិស្សអាចសរសេរសម្រាប់ទស្សនិកជនពួកគេអាចឆ្លើយតបភ្លាមៗ និងសម្រាប់អ្នកចូលរួមក្នុងសកម្មភាពសរសេរជាក្រុម។




- ***សកម្មភាពប្រឌិតអេឡិចត្រូនិក (Electronic Simulation)៖*** អាចធ្វើឲ្យការសិក្សាមានភាពទាក់ទាញ និងរស់រវើក ដោយបង្ហាញអ្វីមួយក្នុង បរិបទនៃសកម្មភាពដូច "ពិភពពិតប្រាកដ" ដូចជាដំណើរការពោងចក្រថាមពលនុយក្លេអ៊ែរ ការសរសេររឿងថ្មីៗក្នុងសារព័ត៌មានមួយ ឬការដោះស្រាយជាមួយនឹងបញ្ហាបំពុលទឹកក្នុងតំបន់។

# ឯកសារចែក ១០៖ ភាពផ្ទុយគ្នានៃការវាយតម្លៃបែបប្រពៃណី និងការសិក្សាបែបស្ថាបនានិយម

**សេចក្ដីណែនាំ៖** ចូរអានការសន្ទនា និងចូលរួមពិភាក្សាជាក្រុមដើម្បីឆ្លើយសំណួរខាងក្រោម៖




## សំណួរពិភាក្សា

១. តើកម្រិតនៃការគិតមួយណា ត្រូវនឹងការវាយតម្លៃក្នុងរូបភាព(ក)? រូបភាព(ខ)? ចូរប្រើប្រាស់ទ្រឹស្ដីប្លូមតាក់សូណូមីដើម្បីឆ្លើយនឹងសំណួរនេះ។

២. រកគុណសម្បត្តិ និងគុណវិបត្តិនៃយុទ្ធសាស្ត្រវាយតម្លៃទាំងក្នុងរូបភាព(ក) និងរូបភាព(ខ)។

៣. ហេតុអ្វីបានជាអ្នកគិតថា គ្រូបង្រៀននៅកម្ពុជាមិនសូវប្រើយុទ្ធសាស្ត្រវាយតម្លៃក្នុងរូបភាព(ខ)?

# ឯកសារចែក ១១៖ យុទ្ធសាស្ត្រវាយតម្លៃក្នុងបរិស្ថានសិក្សាបែបស្ថាបនានិយម

## គំនិតគន្លឹះមួយចំនួន

- អំឡុងពេលវាយតម្លៃ គ្រូប្រើវិធីសាស្ត្ររៀនតាមបែបស្ថាបនានិយម ចាប់អារម្មណ៍ពី **របៀប** ដែលសិស្សរកចម្លើយ ឬធ្វើសេចក្ដីសន្និដ្ឋានជាជាងលើតែ **ចម្លើយ**។
- ដំណើរការសិក្សាមានសារៈសំខាន់ដូចគ្នានឹងផលិតផលសិក្សាដែរ។
- ការវាស់វែងបែបប្រពៃណី និងតេស្តស្តង់ដាមិនសមស្របសម្រាប់វាយតម្លៃបែបស្ថាបនានិយម។
- ខណៈពេលសាលាជាច្រើននៅអនុវត្តតាមបរិបទតេស្តផ្លូវការ គ្រូបង្រៀនត្រូវច្នៃបង្កើតបច្ចេកទេសវាស់វែងលទ្ធផលសិក្សាសិស្សបន្ថែមលើប្រព័ន្ធមានស្រាប់តែម្តង។

## បច្ចេកទេសមួយចំនួនសម្រាប់វាយតម្លៃបែបស្ថាបនានិយម



## បច្ចេកទេសសម្រាប់វាយតម្លៃ[10]

អ្នកទ្រឹស្តីសិក្សាតាមបែបការងារគម្រោង ផ្តល់នូវបច្ចេកទេស ៤ សម្រាប់វាយតម្លៃក្នុងបរិបទសិក្សាតាមរយៈការបង្កើតគម្រោង។ បច្ចេកទេសទាំងនេះ អាចមានភាពជាន់គ្នាខ្លះ តែក៏មានចំណុចពិសេសរៀងៗខ្លួនដែរ។

- **ការវាយតម្លៃបែបឌីណាមិក៖** បច្ចេកទេសនេះណែនាំគ្រូឲ្យបញ្ចូលការវាយតម្លៃលទ្ធផលសិក្សាសិស្សទៅក្នុងដំណើរបង្រៀន និងរៀនតែម្តង។ បច្ចេកវិទ្យាមួយចំនួនអាចប្រើប្រាស់សម្រាប់ការវាយតម្លៃជាប្រចាំតាមបែបឌីណាមិកនេះដូចជា បណ្តាញទំនាក់ទំនងសង្គម អ៊ីមែលជាដើម។ ការវាយតម្លៃអាចត្រូវបានរួមបញ្ចូលជាបទពិសោធន៍សិក្សា និងមិនត្រូវបានរាប់បញ្ចូលទៅក្នុងការសម្រេចចុងក្រោយទៅលើលទ្ធផលសិក្សារបស់សិស្សនោះទេ។ ការវាយតម្លៃប្រភេទនេះត្រូវការគ្រូមានអន្តរកម្មដោយផ្ទាល់ជាមួយសិស្សក្នុងដំណើរការវាយតម្លៃ។
- **ការវាយតម្លៃបែបកម្រងស្នាដៃ៖** បច្ចេកទេសនេះ គ្រូធ្វើការរិះគន់ និងពិភាក្សាពីផលិតផលសិក្សាកើតឡើងក្នុងបរិបទជាក់ស្តែងរួមមាន កម្រងស្នាដៃសិស្ស ការងារគម្រោង ការសម្តែង ការតែងនិពន្ធ និងការធ្វើតេស្តនៅផ្ទះ។ ការប្រើប្រាស់ផលិតផលសិក្សាប្រភេទនេះ អាចបំពេញបន្ថែមនូវចន្លោះប្រហោងនៃការវាយតម្លៃតាមបែបប្រពៃណីលើការសិក្សារបស់សិស្ស។
- **ការវាយតម្លៃបែបដំណើរការ៖** បច្ចេកទេសនេះ គ្រូវាយតម្លៃលើដំណើរការ និងផលិផលសិក្សា។ បច្ចេកទេសប្រភេទនេះ ខ្លះអនុវត្តដោយប្រើប្រាស់ការសួរសំណួរ ការសម្ភាស ការពិភាក្សាក្រុម បញ្ជីត្រួតពិនិត្យ ការអង្កេតរួមគ្នា ការរៀនបែបឆ្លុះបញ្ចាំង ការពិនិត្យចុងក្រោយលើសកម្មភាពដោះស្រាយបញ្ហាណាមួយ។
- **ការវាយតម្លៃបែបក្រៅផ្លូវការ៖** ការវាយតម្លៃបែបក្រៅផ្លូវការនេះ សំដៅលើការអង្កេតលើទំនាក់ទំនងតាមកែវភ្នែក ភាសាកាយវិការ ការសម្តែងទឹកមុខ និងរបៀបអនុវត្តការងារ។ ការអង្កេតបែបនេះអាចបំពេញបន្ថែមលើការវាយតម្លៃផ្លូវការផ្សេងៗ ដោយវាផ្តល់ជាមូលដ្ឋានសម្រាប់គ្រូក្នុងការកែលម្អការបង្រៀន។

**តើគេវាយតម្លៃដោយរបៀបណា?**

**ស្ថាបនានិយម** ទាមទារឲ្យមានការកាត់បន្ថយការដាក់ចំណាត់ថ្នាក់សិស្ស និងការប្រឡងដោយប្រើតេស្តស្តង់ដា។



[10] https://etad.usask.ca/802papers/Skaalid/eval.html

# ឯកសារចែក ១២៖ ឧទាហរណ៍ជាក់ស្តែងពីបច្ចេកទេសផ្សេងៗ នៃការវាយតម្លៃបែបស្ថាបនានិយម

| បច្ចេកទេសវាយតម្លៃ | ឧទាហរណ៍ & សេចក្តីពន្យល់ |
|---|---|
| ការវាយតម្លៃបែបឌីណាមិក<br><br> | ឧទាហរណ៍៖ ការងារក្រុមវិទ្យាសាស្ត្រមួយ សិស្សត្រូវរៀបចំពិសោធបង្ហាញគោលការណ៍បានរៀននៅក្នុងថ្នាក់។ គ្រូបង្រៀនវាយតម្លៃតាមរយៈអន្តរកម្មជាមួយសិស្សដោយផ្ទាល់ពេលអនុវត្តការងារ ដើម្បីជំរុញការយល់ដឹងរបស់សិស្ស និងការធ្វើការជាជីម។<br>**តួនាទីគ្រូបង្រៀន៖**<br>○ ធ្វើអន្តរកម្មជាមួយសិស្សដើម្បីកំណត់ថាតើពួកគេធ្វើការជាមួយគ្នាជាជីមបានល្អប៉ុណ្ណា។<br>○ ស្វែងយល់ថាតើសិស្សអាចធ្វើការស្រាវជ្រាវបានឬទេ ?<br>○ សម្ភាសសិស្សដើម្បីកំណត់ពីរបៀបពួកគេសម្រេចបានផលិតផលចុងក្រោយ។<br>○ ពិនិត្យមើលទំនាក់ទំនងតាមបណ្តាញសង្គម ឬតាមអ៊ីមែលដើម្បីកំណត់ការយល់ដឹងសិស្សក្នុងក្រុម។<br>○ គ្រូបង្រៀនគួរកត់ចំណាំរាល់អន្តរកម្មទាំងអស់របស់សិស្ស ហើយប្រើលក្ខណៈទាំងនេះដើម្បីជួយពួកគេនៅពេលក្រោយ។ |
| ការវាយតម្លៃបែបកម្រងស្នាដៃ<br><br> | ឧ. សិស្សម្នាក់ៗត្រូវនិពន្ធកំណាព្យជាភាសាខ្មែរដោយប្រើក្បួនតែងកាព្យផ្សេងៗ។ គ្រូបង្រៀនវាយតម្លៃដោយពិនិត្យមើលផលិតផល និងនិយាយជាមួយសិស្ស បន្ទាប់ពីផលិតផលកម្រងស្នាដៃរបស់ពួកគេត្រូវបានបញ្ចប់។<br>**តួនាទីគ្រូបង្រៀន៖**<br>○ ផ្តល់សម្ភារសម្រាប់សិស្សរក្សាទុក/ចងក្រងកំណាព្យ<br>○ អនុញ្ញាតឲ្យសិស្សធ្វើការងារគម្រោងក្រៅថ្នាក់រៀន<br>○ ណែនាំសម្ភារផ្សេងៗដើម្បីជួយសិស្សធ្វើគម្រោង |

| បច្ចេកទេសវាយតម្លៃ | ឧទាហរណ៍ & សេចក្ដីពន្យល់ |
|---|---|
| | ○ ពិនិត្យមើលផលិតផល និងសួរសំណួរអំពីរបៀបដែលសិស្សកំណត់ខ្លឹមសារ ចំណុចងាយស្រួល ចំណុចលំបាកជាដើម។ ល។<br>○ កំណត់កម្រិតពិន្ទុផ្អែកលើផលិតផល និងការសម្ភាសជាមួយសិស្ស។ |
| ការវាយតម្លៃបែបដំណើរការ<br> | ✚ ឧទាហរណ៍៖ សិស្សបង្កើតគម្រោងគណិតវិទ្យាមួយបង្ហាញពីគោលការណ៍ក្នុងជំពូកណាមួយ។ គម្រោងនេះនឹងត្រូវបានបង្ហាញនៅលើក្ដារខៀនពិព័រណ៍ក្នុងថ្នាក់។ គ្រូបង្រៀនជួបសិស្សជាទៀងទាត់ដើម្បីពិភាក្សាពីគម្រោង និងធ្វើការវាយតម្លៃក្នុងពេលជាមួយគ្នានោះ។<br>✚ **តួនាទីគ្រូបង្រៀន៖**<br>○ គ្រូបង្រៀនផ្ដល់ប៉ារ៉ាម៉ែត្រគម្រោងដល់សិស្សប៉ុន្តែផ្ដល់ឱកាសឲ្យពួកគេកំណត់ពីទម្រង់ខ្លឹមសារត្រូវអនុវត្ត។<br>○ គ្រូបង្រៀនធ្វើការប្រជុំពិភាក្សាជាទៀងទាត់ជាមួយសិស្សដើម្បីមើលថាតើពួកគេមានការវិវត្តអ្វីខ្លះ អំឡុងពេលអនុវត្តគម្រោង?<br>○ គ្រូបង្រៀនប្រើតារាងត្រួតពិនិត្យសកម្មភាពដើម្បីត្រួតពិនិត្យការវិវត្ត និងបញ្ហាប្រឈម ហើយប្រើប្រាស់ការអង្កេតនេះសម្រាប់វាយតម្លៃគម្រោងចុងក្រោយ។ |
| ការវាយតម្លៃក្រៅផ្លូវការ | ✚ ឧទាហរណ៍៖ គ្រូបង្រៀនឲ្យសិស្សធ្វើការជជែកដេញដោលជាភាសាអង់គ្លេសលើប្រធានបទណាមួយ។ បន្ថែមពីលើការសង្កេតមើលពីការតស៊ូការពារគំនិតរបស់ក្រុមនីមួយៗ គ្រូបង្រៀនធ្វើការសង្កេតទឹកមុខ កម្រិតថាមពល និងការចូលរួមរបស់សិស្សផងដែរ។<br>✚ **តួនាទីគ្រូបង្រៀន៖**<br>○ គ្រូបង្រៀនអង្កេតមើលការជជែកដេញដោល។ |

| បច្ចេកទេសវាយតម្លៃ | ឧទាហរណ៍ & សេចក្ដីពន្យល់ |
| --- | --- |
|  | ○ បន្ថែមលើបញ្ជីត្រួតពិនិត្យវាយតម្លៃលើបច្ចេកទេសជជែកដេញដោយរបស់សិស្ស គ្រូបង្រៀនក៏អាចអង្កេតពីទឹកមុខ កម្រិតថាមពល និងការចូលរួមផងដែរ។<br>○ បន្ទាប់មក គេផ្តួបលទ្ធផលពីការអង្កេតក្រៅផ្លូវការ និងលក្ខណៈវិនិច្ឆ័យការវាយតម្លៃបែបដំណើរការ ( ឧ. ពិន្ទុបញ្ជីផ្ទៀងផ្ទាត់ ) ដើម្បីធ្វើការវាយតម្លៃរួមពីលទ្ធផលសិក្សារបស់សិស្ស។ |

## ការពិភាក្សាជាក្រុមតូច

នៅក្នុងក្រុមតូច សូមពិភាក្សាគ្នាអំពីភាពដូចគ្នា និងភាពខុសគ្នារវាងយុទ្ធសាស្ត្រវាយតម្លៃផ្សេងៗបានពណ៌នានៅក្នុងតារាងខាងលើ។ បន្ទាប់មកសូមបំពេញតារាងខាងក្រោមសង្ខេបថាតើបច្ចេក ទេសទាំងនេះមានលក្ខណៈដូចគ្នា និងខុសគ្នាបែបណាខ្លះ?

| លក្ខណៈពិសេស | ការវាយតម្លៃបែបឌីណាមិក | ការវាយតម្លៃបែបកម្រងស្នាដៃ | ការវាយតម្លៃបែបដំណើរការ | ការវាយតម្លៃបែបក្រៅផ្លូវការ |
|---|---|---|---|---|
| ពេលវេលា<br>(ឧ.មុនពេល កំឡុងពេល ក្រោយពេលបញ្ចប់កិច្ចការ) | | | | |
| ការផ្តោតលើគុណភាពផលិតផល<br>(ឧ. ទាប មធ្យម ខ្ពស់) | | | | |
| ការផ្តោតលើដំណើរការ<br>(ឧ. ទាប មធ្យម ខ្ពស់) | | | | |
| អន្តរកម្មជាមួយគ្រូ<br>(ឧ. ទាប មធ្យម ខ្ពស់) | | | | |
| ការប្រើប្រាស់ការវាយតម្លៃបែបប្រពៃណី(ឧ.ទាប មធ្យម ខ្ពស់) | | | | |

## ឯកសារចែកទី១៣៖ ការកំណត់និយមន័យនៃ ការគិតបែបគណនា និងការយល់ដឹងពីប្រភពដើមរបស់វា[11]

**និយមន័យសាមញ្ញនៃការគិតបែបគណនា៖**

ការគិតបែបគណនា ជាដំណើរការនៃការកំណត់របៀបរកដំណោះស្រាយដែលច្បាស់លាស់ និងជាជំហានៗចំពោះបញ្ហាស្មុគស្មាញ។ នេះរួមបញ្ចូលនូវការបំបែកបញ្ហាទៅជាផ្នែកតូចៗ (ការបំបែក) ការស្គាល់លំនាំគំរូ (ការកត់សម្គាល់លំនាំគំរូ) និងការកាត់បន្ថយទិន្នន័យមិនចាំបាច់ (ការសម្រាំងលំនាំគំរូ) ដូច្នេះដំណោះស្រាយជាជំហានៗ អាចត្រូវបានអនុវត្តតាមទៅបានដោយអ្នកដទៃ (ការបង្កើតក្បួនដោះស្រាយ)។

ការគិតបែបគណនាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការគិតបែបស៊ីជម្រៅ ការអប់រំបែប STEM និងការសិក្សាអាស្រ័យលើគម្រោង។

## មូលដ្ឋានគ្រឹះទាំងបួននៃការគិតបែបគណនារួមមាន៖




**ការបំបែកបញ្ហា**- បំបែកបញ្ហា ឬប្រព័ន្ធស្មុគស្មាញទៅជាផ្នែកតូចៗ និងអាចគ្រប់គ្រងបាន។

**ការសម្គាល់លំនាំគំរូ** - រកមើលភាពស្រដៀងគ្នាក្នុងចំនោមបញ្ហាទាំងអស់។

**ការសម្រាំងលំនាំគំរូ** - ផ្តោតលើតែព័ត៌មាន ឬទិន្នន័យសំខាន់ៗ ដោយកាត់ចោលព័ត៌មាន ឬទិន្នន័យមិនចាំបាច់។ ទាញយកទិន្នន័យសំខាន់បំផុតពីការបំបែកបញ្ហា។

**ការបង្កើតក្បួនដោះស្រាយ** - ល្បះទាក់ទងនឹងដំណោះស្រាយតាមជំហានៗ ដែលអាចត្រូវបានអនុវត្តតាមដោយអ្នកដទៃ។

[11]ដកស្រង់ពី៖ https://www.learning.com/blog/defining-computational-thinking/

ពាក្យ '**ការគិតបែបគណនា**' ត្រូវបានប្រើជាទូទៅលើកដំបូងក្នុងឆ្នាំ ២០០៦ នៅសហរដ្ឋអាមេរិក ហើយបានក្លាយទៅជាប្រធានបទដ៏សំខាន់មួយក្នុងកំណែទម្រង់កម្មវិធីសិក្សានៅទូទាំងពិភពលោក . . .




ថ្វីត្បិតតែដំបូងឡើយ គំនិតនេះបានកើតចេញពីវិធីដែល**អ្នកវិទ្យាសាស្ត្រកុំព្យូទ័រ**ដោះស្រាយបញ្ហាក៏ដោយ ក៏គេដឹងភ្លាមៗថា ការគិតបែបគណនាអាចអនុវត្តចំពោះស្ថានភាពជាច្រើន ទាំងសាមញ្ញ និងស្មុគស្មាញ ក្នុងមុខវិជ្ជាផ្សេងៗ និងក្នុងជីវិតពិត។

ឧទាហរណ៍នៃការគិតបែបគណនាក្នុងជីវិតពិត៖

**បញ្ហា៖ តើអ្វីជាវិធីល្អបំផុតដើម្បីរៀបចំវ៉ាលី?**



| ការគិតបែបគណនា | អ្វីដែលខ្ញុំគិត | គំនិតចុងក្រោយ |
|---|---|---|
| ការបំបែកបញ្ហា | • ខ្ញុំចង់រៀបខោអាវឱ្យបានច្រើនតាមតែអាចធ្វើទៅបាន<br>• ខ្ញុំចង់ការពារកុំឱ្យជ្រួញ<br>• ខ្ញុំមិនចង់ឱ្យមានអ្វីបែកបាក់ ឬខូចខាតទេ | ខ្ញុំត្រូវការដំណើរការមួយដែល៖<br>• អាចឱ្យចំណុះវ៉ាលីអតិបរមា<br>• គ្មានស្នាមជ្រួញ<br>• មិនធ្វើឱ្យខូចខាត/បែកបាក់ |
| ការសម្គាល់លំនាំគំរូ | • ប្រអប់ និងស្បែកជើង និងរបស់របរធំៗដាក់នៅខាងក្រោម<br>• គ្រឿងកញ្ចក់ និងឧបករណ៍ដែលងាយបែកដាក់នៅកណ្ដាល<br>• អាវធំ អាវ និងខោ និងរបស់របរផ្សេងទៀតដែលងាយជ្រួញដាក់នៅលើ<br>• ខោក្នុង និងស្រោមជើងនៅសងខាង ព្រោះខ្ញុំមិនខ្វល់ថាវាជ្រួញឬអត់នោះទេ | |
| ការសម្រាំងលំនាំគំរូ | • ខ្ញុំត្រូវផ្លាស់ប្ដូរពីរបស់ជាក់លាក់ទៅជាគោលការណ៍ទូទៅ . . . | • វត្ថុរឹងធំៗដាក់នៅខាងក្រោម<br>• វត្ថុងាយបែកបាក់ដាក់នៅកណ្ដាល<br>• វត្ថុងាយមានស្នាមជ្រីវជ្រួញដាក់នៅលើ<br>• វត្ថុតូចៗអាចបត់បែនបានដាក់នៅសងខាង |
| ការបង្កើតក្បួនដោះស្រាយ | • ដូច្នេះ ដំណោះស្រាយរបស់ខ្ញុំគឺធ្វើតាមគោលការណ៍ងាយៗចំនួន ៤ នៅពេលរៀបចំវ៉ាលី៖ | |

# ឯកសារចែកទី១៤ក៖ ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ

## លំហាត់

**ការណែនាំ៖** សូមជ្រើសរើសបញ្ហាមួយក្នុងចំណោមបញ្ហាខាងក្រោមដែលមនុស្សតែងតែជួបប្រទះក្នុងជីវិតប្រចាំថ្ងៃ ហើយប្រើដំណើរការគិតបែបគណនាដើម្បីស្វែងរកដំណោះស្រាយ។ ប្រសិនបើអ្នកមិនចូលចិត្តជម្រើសណាមួយបានផ្តល់ឱ្យ អ្នកអាចជ្រើសរើសដោយខ្លួនអ្នកផ្ទាល់។ សូមប្រើតារាងបានផ្តល់ឱ្យខាងក្រោមដើម្បីរៀបចំគំនិតរបស់អ្នកដោយប្រើជំហានសំខាន់ៗទាំង ៤ នៃការគិតបែបគណនា។

*បញ្ហាសម្រាប់ជ្រើសរើស៖*

- *តើអ្វីជាវិធីល្អបំផុតដើម្បីសម្អាតបន្ទប់?*
- *តើអ្វីជាវិធីល្អបំផុតដើម្បីប្រឡងជាប់?*
- *តើខ្ញុំធ្វើយ៉ាងណាដើម្បីអាចបញ្ចប់ការងារបានច្រើនបំផុតក្នុងរយៈពេលតែមួយថ្ងៃ?*



<table>
<tr><th>ការគិតបែបគណនា</th><th>អ្វីដែលខ្ញុំគិត៖</th><th>គំនិតចុងក្រោយ</th></tr>
<tr><td>ការបំបែកបញ្ហា</td><td>•<br>•<br>•</td><td>•<br>•<br>•</td></tr>
<tr><td>ការសម្គាល់លំនាំគំរូ</td><td colspan="2">•<br>•<br>•</td></tr>
<tr><td>ការសម្រាំងលំនាំគំរូ</td><td>•<br>•<br>•</td><td rowspan="2">•<br>•<br>•<br>•</td></tr>
<tr><td>ការបង្កើតក្បួនដោះស្រាយ</td><td>•</td></tr>
</table>

# ឯកសារចែកទី១៤ខ៖ ការអនុវត្តការគិតបែបគណនាក្នុងជីវិតប្រចាំថ្ងៃ (ដំណោះស្រាយណែនាំ)

- *បញ្ហា៖ តើអ្វីជាវិធីល្អបំផុតដើម្បីសម្អាតបន្ទប់?*

| ការគិតបែបគណនា | អ្វីដែលខ្ញុំគិត | គំនិតចុងក្រោយ |
|---|---|---|
| ការបំបែកបញ្ហា | ខ្ញុំត្រូវរៀបចំកិច្ចការខាងក្រោមឱ្យមានប្រសិទ្ធភាព៖<br>• ប្រមូលសម្ភារៈសម្រាប់សម្អាតទាំងអស់ដែលខ្ញុំត្រូវការ(ឧ. អំបោស ក្រណាត់ជូតកញ្ចក់ ។ល។)<br>• សម្អាត បោសធូលី និងជូត<br>• ដាក់វត្ថុទាំងអស់នៅកន្លែងត្រឹមត្រូវ / បោះចោលវត្ថុដែលគ្មានប្រយោជន៍<br>• រើសសម្លៀកបំពាក់ និងបោកគក់<br>• យកសម្រាមក្នុងធុងសម្រាមទៅចោល | • ខ្ញុំត្រូវការដំណើរការមួយដែលកិច្ចការផ្សេងៗត្រូវធ្វើតាម**លំដាប់លំដោយ** ដើម្បីឱ្យកិច្ចការមួយជួយសម្រួលដល់កិច្ចការផ្សេងទៀត។ |
| ការសម្គាល់លំនាំគំរូ | • ជំហានទី ១៖ ប្រមូលសម្ភារៈសម្អាតទាំងអស់ដែលខ្ញុំត្រូវការ (ឧ. អំបោស ក្រណាត់ឧបករណ៍ជូតកញ្ចក់ ។ល។)<br>• ជំហានទី ២៖ ដាក់វត្ថុទាំងអស់នៅក្នុងកន្លែងត្រឹមត្រូវ/បោះចោលរបស់ដែលគ្មានប្រយោជន៍<br>• ជំហានទី ៣៖ រើសសម្លៀកបំពាក់ និងបោកគក់<br>• ជំហានទី ៤៖ បន្ទាប់ពីសម្អាតកម្រាល កៅអី និងតុរួច ចាប់ផ្ដើមបោសសម្អាត ធូលី និងជូត<br>• ជំហានទី ៥៖ សម្អាតធុងសំរាម | |
| ការសម្រាំងលំនាំគំរូ | • មិនចង់ធ្វើកិច្ចការដដែល ២ ដងទេ (ឧ. ប្រសិនបើខ្ញុំសម្អាតធុងសំរាមនៅពេលចាប់ផ្ដើម ប៉ុន្តែបន្ទាប់មកបំពេញវាក្នុងកំឡុងដំណើរការសម្អាត ខ្ញុំត្រូវសម្អាតធុងសំរាមម្ដងទៀត) |  |

| | | |
|---|---|---|
| ការបង្កើតក្បួនដោះស្រាយ | • អនុវត្តតាមលំដាប់លំដោយនៃជំហានសម្មាតបានកំណត់ក្នុងលំនាំបានធ្វើដូច្នេះកិច្ចការនីមួយៗត្រូវធ្វើតែម្តងប៉ុណ្ណោះ។ | |

*ការវិភាគខាងលើគឺជាដំណោះស្រាយមួយដែលបានណែនាំសម្រាប់ការសម្មាតបន្ទប់។ វិធីសាស្ត្រផ្សេងទៀតក៏អាចធ្វើទៅបានដែរ។ សូមប្រៀបធៀបរបៀបអ្នកដោះស្រាយបញ្ហាជាមួយនឹងដំណោះស្រាយខាងលើ។ តើវាដូចគ្នាយ៉ាងដូចម្តេច? តើវាខុសគ្នាយ៉ាងដូចម្តេច? តើអ្នកចូលចិត្តដំណោះស្រាយខាងលើជាងដំណោះស្រាយខ្លួនឯងដែរឬទេ? ហេតុអ្វី?*

***បញ្ហា៖ តើអ្វីជាវិធីល្អបំផុតដើម្បីប្រឡងជាប់?***

| ការគិតបែបគណនា | អ្វីដែលខ្ញុំគិត | គំនិតចុងក្រោយ |
|---|---|---|
| ការបំបែកបញ្ហា | • តើខ្ញុំធ្វើយ៉ាងណាដើម្បីអាចយល់ច្រើនអំពីខ្លឹមសារនឹងត្រូវចេញប្រឡង?<br>• តើខ្ញុំធ្វើយ៉ាងណាដើម្បីឱ្យខ្លួនឯងស៊ាំជាមួយនឹងទម្រង់តេស្តប្រឡង?<br>• តើអ្នកផ្សេងទៀតដែលខ្ញុំស្គាល់អាចជួយខ្ញុំដោយរបៀបណាក្នុងត្រៀមខ្លួនសម្រាប់ការប្រឡង? | • ត្រូវការដំណើរការរៀបចំដែលជួយខ្ញុំឱ្យយល់កាន់តែច្បាស់អំពីខ្លឹមសារ។ ឱ្យខ្លួនស៊ាំជាមួយនឹងទម្រង់តេស្ត ហើយអនុញ្ញាតឱ្យខ្ញុំធ្វើការជាមួយអ្នកដទៃ ក្នុងករណីខ្ញុំខកខានមេរៀនណាមួយដែលអ្នកផ្សេងទៀតចេះ។ |
| ការសម្គាល់លំនាំគំរូ | • រំឭកកំណត់ចំណាំក្នុងសៀវភៅសិក្សា និងអត្ថបទបានហាយឡាយ។<br>• រំឭកកំណត់ចំណាំបានកត់ត្រាក្នុងថ្នាក់អំឡុងពេលគ្រូបង្រៀន។<br>• ពិនិត្យមើលផ្នែកនៃខ្លឹមសារមិនត្រូវបានពន្យល់ច្បាស់នៅក្នុងសៀវភៅសិក្សាតាមអនឡាញ<br>• ស្វែងរកតេស្តសាកល្បងបង្ហាញទម្រង់តេស្តផ្សេងៗគ្នា និងជួយខ្ញុំឱ្យស៊ាំជាមួយនឹងសំណួរ។<br>• ធ្វើការជាក្រុមសិក្សាដើម្បីសួរសំណួរគ្នាទៅវិញទៅមក | |

| | | |
|---|---|---|
| **ការសម្រាំងលំនាំគំរូ** | • ផ្ដោតលើខ្លឹមសារ ទម្រង់តេស្ត និងសំណួរមានអត្រាខ្ពស់បំផុតក្នុងការត្រៀមខ្លួនប្រឡង។ | |
| **ការបង្កើតក្បួនដោះស្រាយ** | • ត្រៀមខ្លួនសម្រាប់ការធ្វើតេស្តដោយរំឭកខ្លឹមសារពីប្រភពទាំងអស់ ស្គាល់ទម្រង់តេស្តផ្សេងៗគ្នា និងសួរមិត្តភក្តិឱ្យសួរសំណួរដែលមិននឹកស្មានថានឹងចេញ។ |  |

*ការវិភាគខាងលើ គឺជាដំណោះស្រាយមួយបានណែនាំដើម្បីប្រឡងជាប់។ វិធីសាស្ត្រផ្សេងទៀតក៏អាចធ្វើទៅបានដែរ។ សូមប្រៀបធៀបរបៀបដែលអ្នកដោះស្រាយបញ្ហាជាមួយនឹងដំណោះស្រាយខាងលើ។ តើវាដូចគ្នាយ៉ាងដូចម្ដេច? តើវាខុសគ្នាយ៉ាងដូចម្ដេច? តើអ្នកចូលចិត្តដំណោះស្រាយខាងលើជាងដំណោះស្រាយខ្លួនឯងដែរឬទេ? ហេតុអ្វី?*

*បញ្ហា៖ តើខ្ញុំធ្វើយ៉ាងណាដើម្បីអាចបញ្ចប់ការងារបានច្រើនបំផុតក្នុងរយៈពេលតែមួយថ្ងៃ?*

| ការគិតបែបគណនា | អ្វីដែលខ្ញុំគិត | គំនិតចុងក្រោយ |
|---|---|---|
| **ការបំបែកបញ្ហា** | • តើខ្ញុំធ្វើយ៉ាងណាដើម្បីអាចផ្ទេរភារកិច្ចឱ្យកាន់តែប្រសើរ?<br>• តើខ្ញុំអាចកំណត់អាទិភាពកិច្ចការរបស់ខ្ញុំបានកាន់តែប្រសើរដោយរបៀបណា?<br>• តើខ្ញុំអាចគ្រប់គ្រងពេលវេលារបស់ខ្ញុំឱ្យកាន់តែមានប្រសិទ្ធភាពដោយរបៀបណា? | • ខ្ញុំត្រូវការដំណើរការដែលជួយខ្ញុំក្នុងការផ្ទេរភារកិច្ចកាន់តែប្រសើរ កំណត់អាទិភាពកាន់តែប្រសើរ និងគ្រប់គ្រងពេលវេលារបស់ខ្ញុំឱ្យកាន់តែមានប្រសិទ្ធភាព។ |
| **ការសម្គាល់លំនាំគំរូ** | • កុំធ្វើអ្វីគ្រប់យ៉ាងតែម្នាក់ឯង<br>• កំណត់បុគ្គលិកមានសមត្ថភាពបំផុត ហើយប្រគល់កិច្ចការដែលគាត់អាចធ្វើបានទៅឱ្យគាត់<br>• ធ្វើបញ្ជីនៃកិច្ចការសំខាន់បំផុតត្រូវធ្វើជារៀងរាល់ថ្ងៃ<br>• ធ្វើកិច្ចការប្រើពេលតិចបំផុតជាមុន ដើម្បីឱ្យវាចប់សព្វគ្រប់ | |

| | | |
|---|---|---|
| | • មានកាលវិភាគប្រជុំ និងការគ្រប់គ្រងការងារច្បាស់លាស់ ដើម្បីឱ្យពេលវេលាត្រូវបានរៀបចំឡើងយ៉ាងល្អ | |
| ការសម្រាំងលំនាំគំរូ | • ផ្ដោតលើការធ្វើប្រតិភូកម្ម ផ្ដល់អាទិភាពការងារ និងការកំណត់កាលវិភាគច្បាស់លាស់ | |
| ការបង្កើតក្បួនដោះស្រាយ | • ដើម្បីសម្រេចកិច្ចការបានច្រើនបំផុតជារៀងរាល់ថ្ងៃ យើងត្រូវមានឆន្ទៈក្នុងការផ្ទេរការងារឱ្យកាន់តែមានប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។ មានអាទិភាពការងារ និងកាលវិភាគច្បាស់លាស់ ដូច្នេះពេលវេលាត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ |  |

*ការវិភាគខាងលើគឺជាដំណោះស្រាយមួយបានណែនាំដើម្បីធ្វើការងារឱ្យកាន់តែមានប្រសិទ្ធភាព។ វិធីសាស្ត្រផ្សេងទៀតក៏អាចធ្វើទៅបានដែរ។ សូមប្រៀបធៀបរបៀបដែលអ្នកដោះស្រាយបញ្ហាជាមួយនឹងដំណោះស្រាយខាងលើ។ តើវាដូចគ្នាយ៉ាងដូចម្ដេច? តើវាខុសគ្នាយ៉ាងដូចម្ដេច? តើអ្នកចូលចិត្តដំណោះស្រាយខាងលើជាងដំណោះស្រាយខ្លួនឯងដែរឬទេ? ហេតុអ្វី?*

# ឯកសារចែកទី១៥៖ តើបុគ្គលគ្រប់គ្នាចូលចិត្តការគិតបែបគណនាដែរឬទេ? (ជម្រើស)

## ការរិះគន់ទូទៅ

ទោះបីជាការគិតបែបគណនាមានអ្នកគាំទ្រច្រើនក៏ដោយ ក៏នៅតែមានអ្នករិះគន់ខ្លះៗអំពីវិធីសាស្ត្រក្នុងការសិក្សាបែបនេះដែរ។ អ្នកអប់រំខ្លះយល់ថា ការគិតបែបគណនាគ្រាន់តែជា 'ស្រាចាស់ក្នុងដបថ្មី' ប៉ុណ្ណោះ មានន័យថា ជំហានប្រើក្នុងការដោះស្រាយបញ្ហា គឺមិនខុសពីវិធីវិទ្យាសាស្ត្រ ឬវិធីសាស្ត្រមានស្រាប់ផ្សេងទៀតនៃការដោះស្រាយបញ្ហានោះទេ។




## ការរិះគន់ជាក់លាក់

- **កង្វះភាពច្បាស់លាស់អំពីរបៀបដែលវាខុសពីវិធីសាស្ត្រផ្សេងទៀត៖** អ្នកអប់រំខ្លះរិះគន់ថា ការគិតបែបគណនា ជាវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាមិនមានភាពខុសគ្នាខ្លាំងពីប្រភេទនៃវិធីសាស្ត្រដោះស្រាយបញ្ហាផ្សេងទៀតនោះទេ។
- **មិនសូវស័ក្តិសមសម្រាប់មុខវិជ្ជាដែលមិនមែនជា STEM៖** ទោះបីជាអ្នកគាំទ្រការគិតបែបគណនាបានអះអាងថាវាអាចត្រូវបានប្រើសម្រាប់ការដោះស្រាយបញ្ហាក្នុងមុខវិជ្ជាផ្សេងៗក៏ដោយ ការពិតគឺថាវាល្អបំផុតសម្រាប់មុខវិជ្ជា STEM និងជាពិសេសវិទ្យាសាស្ត្រកុំព្យូទ័រ។ វាពិបាកប្រើជាមួយមុខវិជ្ជាដែលមិនមែនជា STEM។
- **ការផ្តោតតូចចង្អៀត៖** អ្នកផ្សេងទៀតរិះគន់ទៅលើ ការគិតបែបគណនា ព្រោះវាផ្តោតចង្អៀតពេកលើ 'ការដោះស្រាយបញ្ហា' និងមិនគ្រប់គ្រាន់លើទិដ្ឋភាពផ្សេងទៀតនៃការគិត ដូចជាការច្នៃប្រឌិត និងការបង្កើតចំណេះដឹង។

## សំណួរពិភាក្សា

១. តើអ្នកយល់ស្របនឹងមតិរិះគន់ទៅលើការគិតបែបគណនាដែរឬទេ? ហេតុអ្វី?

២. តើការរិះគន់ទាំងនេះធ្វើឱ្យប៉ះពាល់ដល់សុទិដ្ឋិនិយមរបស់អ្នកដែលថាការគិតបែបគណនាអាចប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនៅក្នុងសាលារៀននៅកម្ពុជាដែរឬទេ? សូមពន្យល់ចម្លើយរបស់អ្នក។

# ឯកសារចែកទី១៦ក៖ ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា

ការគិតបែបគណនាបង្កប់នូវទម្រង់នៃការគិតបែបសមហេតុផលជាច្រើនដែលអ្នកប្រហែលជាធ្លាប់ប្រើរួចហើយ ដូចជានៅក្នុងបញ្ជីដែលបានផ្តល់ជូនខាងក្រោម។ សូមពិនិត្យមើលបញ្ជីជាមួយគ្នានៅក្នុងក្រុមរបស់អ្នក ឬជាមួយអ្នកសម្របសម្រួល ហើយបន្ទាប់មកធ្វើលំហាត់ខាងក្រោម។

## លំហាត់ទី១

ការណែនាំ៖ សូមពិនិត្យមើលជំនាញនៃការគិតនីមួយៗខាងក្រោម ហើយចាត់ថ្នាក់វាទៅតាមជំហានទាំង ៤ នៃការគិតបែបគណនាបានពិភាក្សាពីមុន។ បំពេញតារាងខាងក្រោមដើម្បីបញ្ចប់លំហាត់នេះ។ បន្ទាប់ពីពិនិត្យមើលជំនាញគិតនីមួយៗ សូមសរសេរលេខរៀងជំនាញក្នុងតារាងតាមជំហាន។ ជំនាញមួយអាចអនុវត្តទៅបានជាមួយជំហានច្រើន។ ជំនាញលេខ ១ ត្រូវបានធ្វើជាឧទាហរណ៍សម្រាប់អ្នក។

*១. ការប្រើប្រាស់ការសម្រាំងលំនាំគំរូ និងការស្គាល់លំនាំគំរូ ដើម្បីបង្ហាញបញ្ហាតាមរបៀបផ្សេងទៀត។*

*២. ការវិភាគកិច្ចការ៖ បំបែកកិច្ចការធំមួយទៅជាផ្នែកតូចៗ។ ឧទាហរណ៍ ការសម្អាតបន្ទប់គេង. ទាក់ទងនឹងការបោសសម្អាតកម្រាលឥដ្ឋ រៀបចំគ្រែ ការទុកដាក់សម្លៀកបំពាក់។ល។*

*៣. រៀបចំ និងវិភាគទិន្នន័យដោយសមហេតុផល។ ឧទាហរណ៍ ប្រសិនបើអ្នកកំពុងព្យាយាមសន្សំប្រាក់លើថ្លៃអគ្គិសនី អ្នកប្រហែលត្រូវបង្ហាញពីការចំណាយប្រចាំខែជាក្រាហ្វ ឬបញ្ជី ហើយកំណត់ថាតើខែណាអ្នកចំណាយច្រើនបំផុត? បន្ទាប់មក ផ្តោតលើសកម្មភាពរបស់អ្នកនៅលើខែទាំងនោះ។*

*៤. រៀបចំ ឬរៀបចំទិន្នន័យឡើងវិញតាមរបៀបមួយ ដើម្បីងាយស្រួលក្នុងការមើលឃើញនិន្នាការ។*

*៥. ការបំបែកបញ្ហាទៅជាផ្នែកតូចៗ។*

*៦. ការដោះស្រាយបញ្ហាដោយប្រើបច្ចេកទេស 'ការគិតបែបកម្មវិធីកុំព្យូទ័រ' ដូចជាការនិយាយឡើងវិញ (ឧ. ការធ្វើកំណែប្រែកម្មវិធី ដូចជាសុសវែរមានច្រើនជំនាន់) ការតាងជានិមិត្តសញ្ញា (ឧ. ការតាងទិន្នន័យជាក្រាហ្វ) និងប្រតិបត្តិការតក្ក (ឧ. លំដាប់លំដោយនៃសកម្មភាព)។ ការគិតបែបកម្មវិធីកុំព្យូទ័រ សំដៅលើការប្រើប្រាស់រូបមន្តច្បាស់លាស់ផ្អែកលើទិន្នន័យជាក់លាក់ដើម្បីធ្វើការសម្រេចចិត្ត។*

*៧. ការដោះស្រាយបញ្ហាដោយបង្កើតដំណោះស្រាយជាជំហានៗតាមលំដាប់។*

*៨. ការបង្កើត វិភាគ និងអនុវត្តដំណោះស្រាយ ដើម្បីសម្រេចបាននូវការរួមបញ្ចូលគ្នានៃជំហាន និងធនធានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់បំផុត។*

*៩. ប្រើប្រាស់ការសាកល្បង និងកំហុស ដើម្បីឈានទៅដល់ដំណោះស្រាយ។*

*១០. ធ្វើទូទៅកម្មទៅលើដំណើរការដោះស្រាយបញ្ហា ចំពោះបញ្ហាជាច្រើនប្រភេទ។*

សូមសរសេរលេខរៀងនៃជំនាញខាងលើក្នុងប្រអប់ជំហាននៃការគិតបែបគណនា។ ឧទាហរណ៍មួយត្រូវបានធ្វើសម្រាប់អ្នក។

| | |
|---|---|
| ការបំបែកបញ្ហា | |
| ការសម្គាល់លំនាំគំរូ | (១) |
| ការសម្រាំងលំនាំគំរូ | (១) |
| ការបង្កើតក្បួនដោះស្រាយ | |

# ឯកសារចែកទី១៦ខ៖ ឧទាហរណ៍ពាក់ព័ន្ធនឹងជំនាញគិតបែបគណនា

## លំហាត់ទី២

***ការណែនាំ៖*** *សូមអានករណីសិក្សាខ្លីៗខាងក្រោម ក្នុងក្រុមរបស់អ្នក សូមពិពណ៌នាអំពីរបៀបដែលអ្នកជំនួញប្រើគោលការណ៍នៃការគិតបែបគណនា ស្វែងរកដំណោះស្រាយបញ្ហា។ ត្រូវប្រាកដថាអ្នកលើកឡើង (២) អ្វីជាបញ្ហា ឬបញ្ហាប្រឈម (២) អ្វីជាបញ្ហារង (៣) តើទិន្នន័យអ្វីខ្លះត្រូវបានប្រើដើម្បីស្វែងរកដំណោះស្រាយ (៤) លំនាំគំរូអ្វីត្រូវបានគេសង្កេតឃើញ និង (៥) របៀបដែលការបង្កើតក្បួនដោះស្រាយត្រូវបានកំណត់ក្នុងលក្ខខណ្ឌជាក់ស្តែង។*

**ករណីសិក្សាទី១៖** អាជីវករលក់ស្រូវបានព្យាយាមបង្កើនប្រាក់ចំណេញដោយវិនិយោគយ៉ាងច្រើនក្នុងការទិញ និងស្តុកស្រូវក្នុងរដូវប្រមូលផលពេលតម្លៃទាប ប៉ុន្តែលក់ស្រូវស្តុកទុកក្នុងរដូវដាំដុះពេលតម្លៃឡើងខ្ពស់។



**ករណីសិក្សាទី ២៖** ឈ្មួញកណ្តាលភាគហ៊ុនបានកត់សម្គាល់ឃើញថា តាមប្រវត្តិសាស្ត្រ ទីផ្សារភាគហ៊ុនតែងតែធ្លាក់ចុះក្នុងខែឧសភា និងកញ្ញា។ ដូច្នេះគាត់តែងលក់ភាគហ៊ុនសំខាន់ៗក្នុងខែមេសា និងសីហា នៃឆ្នាំនីមួយៗ បន្ទាប់មកទិញម្តងទៀតយ៉ាងច្រើនពេលតម្លៃភាគហ៊ុនធ្លាក់ចុះក្នុងខែឧសភា និងកញ្ញា។




**ករណីសិក្សាទី៣៖** វិស័យទេសចរណ៍គឺជាឧស្សាហកម្មមួយមានបញ្ហាប្រឈមជាច្រើន។ ម្ចាស់សណ្ឋាគារដឹងថាមានភ្ញៀវទេសចរណ៍ច្រើនក្នុងរដូវប្រាំង (ខែវិច្ឆិកា ដល់មេសា) ហើយមានភ្ញៀវតិចក្នុងរដូវវស្សា (ខែឧសភា ដល់តុលា)។ ដូច្នេះជាធម្មតា ពួកគេដំឡើងថ្លៃបន្ទប់នៅរដូវប្រាំង ប៉ុន្តែបញ្ចុះតម្លៃនៅរដូវវស្សា ដើម្បីទាក់ទាញអតិថិជនស្របពេលបញ្ឈប់បុគ្គលិកខ្លះ។ នេះជាវិធីនៃការបង្កើនប្រាក់ចំណេញអតិបរមា ដោយមានការខាតបង់តិចបំផុត។



## ចម្លើយ

| | សំណួរ | ការវិភាគរបស់អ្នក |
|---|---|---|
| ករណីសិក្សាទី១ | (១) តើអ្វីជាបញ្ហា ឬបញ្ហាប្រឈម? | |
| | (២) តើអ្វីទៅជាបញ្ហារង? | |
| | (៣) តើទិន្នន័យអ្វីខ្លះត្រូវបានប្រើដើម្បីស្វែងរកដំណោះស្រាយ? | |
| | (៤) តើលំនាំគំរូអ្វីត្រូវបានគេសង្កេតឃើញ? | |
| | (៥) តើការបង្កើតក្បួនដោះស្រាយត្រូវបានកំណត់ដោយរបៀបណាក្នុងលក្ខខណ្ឌជាក់ស្តែង? | |
| ករណីសិក្សាទី២ | (១) តើអ្វីជាបញ្ហា ឬបញ្ហាប្រឈម? | |
| | (២) តើអ្វីទៅជាបញ្ហារង? | |
| | (៣) តើទិន្នន័យអ្វីខ្លះត្រូវបានប្រើដើម្បីស្វែងរកដំណោះស្រាយ? | |
| | (៤) តើលំនាំគំរូអ្វីត្រូវបានគេសង្កេតឃើញ? | |
| | (៥) តើការបង្កើតក្បួនដោះស្រាយត្រូវបានកំណត់ដោយរបៀបណាក្នុងលក្ខខណ្ឌជាក់ស្តែង? | |
| ករណីសិក្សាទី៣ | (១) តើអ្វីជាបញ្ហា ឬបញ្ហាប្រឈម? | |
| | (២) តើអ្វីទៅជាបញ្ហារង? | |
| | (៣) តើទិន្នន័យអ្វីខ្លះត្រូវបានប្រើដើម្បីស្វែងរកដំណោះស្រាយ? | |
| | (៤) តើលំនាំគំរូអ្វីត្រូវបានគេសង្កេតឃើញ? | |
| | (៥) តើការបង្កើតក្បួនដោះស្រាយត្រូវបានកំណត់ដោយរបៀបណាក្នុងលក្ខខណ្ឌជាក់ស្តែង? | |

# ឯកសារចែកទី១៧៖ បច្ចេកទេសទូទៅមួយចំនួនដើម្បីអនុវត្តការគិតបែបគណនាទៅក្នុងមុខវិជ្ជាផ្សេងៗ

គោលដៅចម្បងនៃការបង្រៀនការគិតបែបគណនា គឺដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការដោះស្រាយបញ្ហា ហើយបង្ហាញដំណោះស្រាយក្នុងទម្រង់ជាក្បួនដោះស្រាយ (ឧទាហរណ៍ លំដាប់នៃជំហាន ឬ រូបមន្ត) ច្បាស់លាស់អាចឱ្យអ្នកផ្សេង និងម៉ាស៊ីនយល់បាន។ ទោះបីជាការគិតបែបគណនាត្រូវបានរចនាឡើងដំបូងសម្រាប់មុខវិជ្ជា STEM ក៏ដោយ វាអាចប្រើសម្រាប់មុខវិជ្ជាផ្សេងទៀតដែរ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួននៃរបៀបដែលការគិតបែបគណនាអាចត្រូវបានប្រើជាមួយនឹងមុខវិជ្ជាជាច្រើន។

## អក្សរសិល្ប៍[12]

ថ្នាក់អក្សរសិល្ប៍ ក៏អាចប្រើការគិតបែបគណនាក្នុងថ្នាក់ផងដែរ។ ឧទាហរណ៍ សិស្សអាចប្រើជំនាញគិតបែបគណនា ដើម្បីវិភាគអក្សរសិល្ប៍ដូចជារឿង *ទុំទាវ* និង *កុលាបប៉ៃលិន*។ សិស្សអាចបង្កើត 'ដ្យាក្រាមបណ្ដាញ' និង 'ក្រាហ្វទំនាក់ទំនង' ដើម្បីសង្ខេបទំនាក់ទំនងរវាងតួអង្គក្នុងរឿង។

ដ្យាក្រាមបណ្ដាញ
សម្រាប់រឿងទុំទាវ






បច្ចេកទេសនេះជួយ**បង្កើតបរិបទអក្សរសិល្ប៍**សម្រាប់សិស្ស ដូច្នេះពួកគេអាចបង្កើតការយល់ដឹងអំពីរឿងកាន់តែប្រសើរជាងមុនដូចជាទំនាក់ទំនងសំខាន់ៗនៅក្នុងរឿង។ ដ្យាក្រាមបង្ហាញខាងលើជួយដោះស្រាយបញ្ហាទាក់ទងនឹងថាតើនរណាជាតួអង្គសំខាន់នៅក្នុងរឿង។ ដោយផ្អែកលើការពិនិត្យឡើងវិញនៃដ្យាក្រាមនេះ ទាវ

[12] កែសម្រួលពី៖ https://equip.learning.com/examples-of-computational-thinking

ជាតួអង្គសំខាន់។ ការវិភាគបែបនេះជួយសិស្សឱ្យបង្កើនការយល់ដឹងអំពីរឿង និងតាមដានលំហូរនៃរឿង។ សម្រាប់រឿងរ៉ាវជាច្រើនទៀតដោយប្រើបច្ចេកទេសដូចគ្នា។

## វិទ្យាសាស្ត្រធម្មជាតិ[13]

**បញ្ហា៖** តើត្រូវសាងសង់ស្ពានដោយរបៀបណាដើម្បីអាចធន់នឹងការរញ្ជួយដី?

សិស្សក៏អាចអនុវត្តការគិតបែបគណនាក្នុងរូបវិទ្យា និងវិស្វកម្មផងដែរ ដើម្បី**សាងសង់ស្ពានធន់នឹងការរញ្ជួយដី**។ ឧទាហរណ៍នៃគម្រោងបែបនេះអាចផ្តោតលើការយល់ដឹងអំពីមុខងារស្ពាន និងប្រភេទផ្សេងៗនៃស្ពាន។ បន្ទាប់មក សិស្សបន្តសិក្សាអំពីការរញ្ជួយដី និងឥទ្ធិពលនៃកម្លាំងរបស់ពួកវាទៅលើរចនាសម្ព័ន្ធ។



សកម្មភាពបានខាងលើអាចធ្វើបានល្អបំផុតនៅក្នុងបរិបទនៃគម្រោងសិក្សាអាស្រ័យលើបញ្ហា។ ដើម្បីរចនាស្ពានធន់នឹងការរញ្ជួយដី សិស្សអនុវត្តទាំងការគិតបែបច្នៃប្រឌិត និងការគិតបែបគណនា។ ការគិតបែបគណនា**អាចឱ្យសិស្សវិភាគភាពខុសគ្នានៃគំរូស្ពានដើម្បីរកលំនាំគំរូក្នុងរចនាសម្ព័ន្ធ និងសង្ខេបពីធាតុសំខាន់ៗចាំបាច់ក្នុងការរចនាមុខងារ។** នៅពេលពួកគេសាកល្បងគំរូផ្សេងៗគ្នា ពួកគេប្រមូលទិន្នន័យ និងកែលម្អរចនាសម្ព័ន្ធ។

## គណិតវិទ្យា







ការគិតបែបគណនា គឺស័ក្តិសមសម្រាប់ការដោះស្រាយបញ្ហាក្នុងគណិតវិទ្យា។ ឧទាហរណ៍នេះនិយាយអំពីរបៀបបកស្រាយព័ត៌មានគណិតវិទ្យានៅក្នុង 'ពីរ៉ាមីតចំនួនប្រជាជន' និងអត្ថន័យនៃកំណើនសេដ្ឋកិច្ច។ មេរៀនចាប់ផ្តើមដោយការពន្យល់អំពីរបៀបមើលពីរ៉ាមីតចំនួនប្រជាជន អ្វីដែលរបារខាងក្រោមនៃពីរ៉ាមីតតំណាងឱ្យ (ឧទាហរណ៍ ចំនួនមនុស្សវ័យក្មេង) និងអ្វីដែលរបារខាងលើតំណាងឱ្យ (ឧទាហរណ៍ ចំនួនមនុស្សចាស់)។ ការពន្យល់នេះត្រូវបានសម្របសម្រួលដោយការបង្ហាញពីរ៉ាមីតចំនួនប្រជាជនមកពីប្រទេសមួយដូចជាប្រទេសជប៉ុន។ តាមរយៈការពិភាក្សា សិស្សអាចកត់សម្គាល់ថាពីរ៉ាមីតចំនួនប្រជាជននៅក្នុងប្រទេសជប៉ុនបង្ហាញ

[13]កែសម្រួលពី៖ https://equip.learning.com/examples-of-computational-thinking

ថាមានមនុស្សចាស់ច្រើនជាងមនុស្សវ័យក្មេង។ គ្រូអាចជួយសិស្សឱ្យ 'បំបែក' នូវកត្តាប៉ះពាល់ដល់សេដ្ឋកិច្ចប្រសិនបើមានមនុស្សវ័យក្មេងច្រើនជាងមនុស្សចាស់នៅក្នុងប្រទេស ឬផ្ទុយទៅវិញមនុស្សចាស់ច្រើនជាងមនុស្សវ័យក្មេង។ សំណួរសំខាន់ៗមួយចំនួនគួរអាចសួរក្នុងពេលបំបែក (សូមមើលតារាងខាងក្រោម)

| **បញ្ហា៖** តើរចនាសម្ព័ន្ធប្រជាជនប្រភេទណាដែលល្អបំផុតសម្រាប់កំណើនសេដ្ឋកិច្ច? | | | |
|---|---|---|---|
| **ការបំបែកបញ្ហា** | **ការសម្គាល់លំនាំគំរូ** | **ការសម្រាំងលំនាំគំរូ** | **ការបង្កើតក្បួនដោះស្រាយ** |
| • តើផ្នែកណានៃចំនួនប្រជាជនល្អជាងក្នុងការធ្វើការងារផលិតកម្មរួមចំណែកដល់សេដ្ឋកិច្ច?<br>• តើអ្នកណាជួយផ្គត់ផ្គង់មនុស្សចាស់នៅពេលពួកគាត់លែងមានលទ្ធភាពធ្វើការ?<br>• តើនឹងមានអ្វីកើតឡើងចំពោះបន្ទុកផ្គត់ផ្គង់ ប្រសិនបើមានមនុស្សចាស់ច្រើនពេក ហើយមនុស្សវ័យក្មេងមិនគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ពួកគាត់? | • របាររវែងជាងនៅខាងក្រោមមានន័យថាមនុស្សវ័យក្មេងច្រើនជាងមនុស្សចាស់<br>• របាររវែងនៅផ្នែកខាងលើមានន័យថាមនុស្សចាស់ច្រើនជាងមនុស្សវ័យក្មេង | • យើងមិនចាំបាច់មើលចំនួនជាក់លាក់នៃមនុស្សក្មេង និងមនុស្សចាស់សម្រាប់របារនីមួយៗនោះទេ ប៉ុន្តែថាតើរបារត្រូវបានប្រមូលផ្តុំយ៉ាងដូចម្តេច?<br>• បណ្តុំផ្នែកខាងលើមានន័យថាចំនួនប្រជាជន 'ចាស់'<br>• បណ្តុំច្រើននៅខាងក្រោមមានន័យថា 'ចំនួនប្រជាជនវ័យក្មេង' | • ពីរ៉ាមីតប្រជាជនមានបណ្តុំមនុស្សច្រើននៅខាងក្រោម គឺល្អសម្រាប់កំណើនសេដ្ឋកិច្ច ព្រោះមនុស្សវ័យក្មេងអាចធ្វើការងារបានច្រើនជាងមនុស្សចាស់។<br>• មនុស្សវ័យក្មេងកាន់តែច្រើនអាចធ្វើការមានផលិតភាព មានន័យថាវាកាន់តែងាយស្រួលក្នុងការជួយផ្គត់ផ្គង់ដល់មនុស្សចាស់។ |

នៅពេលសិស្សប្រៀបធៀបពីរ៉ាមីតចំនួនប្រជាជនកម្ពុជាជាមួយប្រទេសជប៉ុន ពួកគេចាប់ផ្តើមឃើញភាពខុសគ្នាយ៉ាងខ្លាំង។ ប្រទេសកម្ពុជា មានចំនួនប្រជាជនវ័យក្មេងមានសក្តានុពលផលិតភាពការងារ និងងាយស្រួលជួយដល់មនុស្សចាស់ ចំណែកប្រទេសជប៉ុនមានស្ថានភាពផ្ទុយគ្នា។ ការបង្កើត

ក្បួនដោះស្រាយ នេះអាចត្រូវបានប្រើដើម្បីវិនិច្ឆ័យសក្តានុពលសេដ្ឋកិច្ចនៃប្រទេសណាមួយដោយគ្រាន់តែមើលរចនាសម្ព័ន្ធនៃពីរ៉ាមីតចំនួនប្រជាជនប្រទេសនោះ។

## សិក្សាសង្គម

សិក្សាសង្គម អាចផ្តល់ឱកាសដល់សិស្សក្នុងការដោះស្រាយបញ្ហាសង្គម។ ឧទាហរណ៍ សិស្សក្នុងថ្នាក់មួយចង់ពិនិត្យមើលអ្នកដឹកនាំប្រវត្តិសាស្ត្រពីអតីតកាល ដើម្បីកំណត់ថាតើលក្ខណៈមេដឹកនាំ 'ល្អ' មានអ្វីខ្លះ? មធ្យោបាយមួយក្នុងការឆ្លើយសំណួរនេះ គឺពិនិត្យមើលលក្ខណៈអ្នកដឹកនាំក្នុងប្រវត្តិសាស្ត្រគេចាត់ទុកថាជាមេដឹកនាំ "អាក្រក់" ដូចជាហ៊ីត្លែរ យ៉ូសែប ស្តាលីន និងម៉ៅសេទុង។ បន្ទាប់មកសិស្សស្រាវជ្រាវអំពីលក្ខណៈនៃអ្នកដឹកនាំទាំងនេះ ហើយធ្វើបញ្ជីអ្នកដឹកនាំ និងបុគ្គលិកលក្ខណៈរបស់ពួកគេ(ការបំបែកបញ្ហា)។ តាមរយៈដំណើរការនៃ 'ការសម្រាំងលំនាំគំរូ' ពួកគេលុបចោលលក្ខណៈទាំងឡាយណាមិនពាក់ព័ន្ធនឹងការក្លាយជាអ្នកដឹកនាំល្អ ឬមិនល្អ (ឧ. ស្រលាញ់សិល្បៈ អនាម័យមិនល្អ ។ល។)។ បន្ទាប់មកសិស្សស្វែងរកលក្ខណៈផ្ទុយគ្នានៃអ្នកដឹកនាំ 'មិនល្អ' ហើយរកមើលគំរូនៃអ្នកដឹកនាំ 'ល្អ' ដោយបង្កើត 'ការបង្កើតក្បួនដោះស្រាយ' សម្រាប់អ្នកដឹកនាំល្អ(សូមមើលដ្យាក្រាមខាងក្រោម)។

| **បញ្ហា៖** តើអ្វីទៅជាលក្ខណៈសម្បត្តិរបស់អ្នកដឹកនាំ 'ល្អ'? | | | | |
|---|---|---|---|---|
| **ការបំបែកបញ្ហារកលក្ខណៈអ្នកដឹកនាំ "មិនល្អ"** | | **ការសម្រាំងលំនាំគំរូលក្ខណៈសំខាន់ៗ / ការសម្គាល់លំនាំគំរូ** | **លក្ខណៈសម្បត្តិផ្ទុយគ្នា ដើម្បីក្លាយជា 'អ្នកដឹកនាំល្អ'** | **ការបង្កើតក្បួនដោះស្រាយដើម្បីក្លាយជាអ្នកដឹកនាំល្អ** |
| **អាដុលហ្វ៍ ហ៊ីត្លែរ**<br> | • ឃាតកម្ម<br>• ផ្តាច់ការ<br>• រើសអើង<br>• កុហក<br>• អសីលធម៌<br>• ប្រជាភិថុតិ<br>• មិនគោរពសន្យា<br>• ឃោរឃៅ<br>• ស្រឡាញ់សិល្បៈ<br>• គ្មានកូន | • ឃាតកម្ម<br>• ផ្តាច់ការ<br>• រើសអើង<br>• កុហក<br>• អសីលធម៌<br>• ប្រជាភិថុតិ<br>• មិនគោរពសន្យា<br>• ឃោរឃៅ | • គោរពជីវិតអ្នកដទៃ<br>• ប្រជាធិបតេយ្យ<br>• អ្នករួបរួម<br>• មានសីលធម៌<br>• អ្នកសម្របសម្រួល<br>• គួរឱ្យទុកចិត្ត<br>• មានមេត្តា<br>• គំនិតបើកចំហ<br>• មានមេត្តា | |
| **យ៉ូសែប ស្តាលីន** | • ឃាតកម្ម<br>• ផ្តាច់ការ<br>• លាក់ពុត<br>• កុហក | • ឃាតកម្ម<br>• ផ្តាច់ការ<br>• លាក់ពុត<br>• កុហក | | |

| **បញ្ហា៖** តើអ្វីទៅជាលក្ខណៈសម្បត្តិរបស់អ្នកដឹកនាំ 'ល្អ'? | | | | |
|---|---|---|---|---|
| **ការបំបែកបញ្ហារកលក្ខណៈអ្នកដឹកនាំ "មិនល្អ"** | | **ការសម្រាំងលំនាំគំរូលក្ខណៈសំខាន់ៗ / ការសម្គាល់លំនាំគំរូ** | **លក្ខណៈសម្បត្តិផ្ទុយគ្នា ដើម្បីក្លាយជា 'អ្នកដឹកនាំល្អ'** | **ការបង្កើតក្បួនដោះស្រាយដើម្បីក្លាយជាអ្នកដឹកនាំល្អ** |
|  | • មិនគោរពសន្យា<br>• ឃោរឃៅ<br>• ចិត្តចង្អៀត<br>• គ្មានមេត្តា<br>• ជាស្វាមីដែលមិនស្មោះត្រង់ | • មិនគោរពសន្យា<br>• ឃោរឃៅ<br>• ចិត្តចង្អៀត<br>• គ្មានមេត្តា | | |
| **ម៉ៅសេទុង**<br> | • ឃាតកម្ម<br>• ផ្តាច់ការ<br>• កុហក<br>• អសីលធម៌<br>• មិនគោរពសន្យា<br>• ឃោរឃៅ<br>• ចិត្តចង្អៀត<br>• គ្មានមេត្តា<br>• អនាម័យមិនល្អ<br>• ជាស្វាមីដែលមិនស្មោះត្រង់ | • ឃាតកម្ម<br>• ផ្តាច់ការ<br>• កុហក<br>• អសីលធម៌<br>• មិនគោរពសន្យា<br>• ឃោរឃៅ<br>• ចិត្តចង្អៀត<br>• គ្មានមេត្តា | | |

# លំហាត់

*ការណែនាំ៖ ដោយផ្អែកលើឧទាហរណ៍នៃការអនុវត្ត ការគិតបែបគណនា ខាងលើ បង្កើតមេរៀនមួយប្រើដំណើរការគិតតាមបែបគណនាដែលអ្នកចង់ឱ្យសិស្សអនុវត្តផងដែរ។ ប្រើតារាងខាងក្រោមដើម្បីសង្ខេបដំណើរការនៃការគិតបែបគណនា ដើម្បីដោះស្រាយបញ្ហាចាប់ផ្តើមពី ការបំបែកបញ្ហានិងបញ្ចប់ដោយការបង្កើតក្បួនដោះស្រាយអាចប្រើដើម្បីដោះស្រាយបញ្ហាស្រដៀងគ្នា។ អ្នកអាចប្រើឧទាហរណ៍ពីប្រធានបទណាមួយអ្នកចង់បាន។ សួរសមាជិកផ្សេងទៀតថាតើឧទាហរណ៍មួយណាល្អបំផុតសម្រាប់ពួកគេ?*

| បញ្ហា៖ ________________________________________________? | | | |
|---|---|---|---|
| ការបំបែកបញ្ហា | ការសម្គាល់លំនាំគំរូ | ការសម្រាំងលំនាំគំរូ | ការបង្កើតក្បួនដោះស្រាយ |
| • | • | • | • |